ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី**
**និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)**

# របាយការណ៍

# ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផល នៃការបំពេញ/អនុវត្តន៍ គោលនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១








រាជរដ្ឋាភិបាលកម្ពុជា

«កម្មវិធីនយោបាយ»

របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា

រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៣

- វាយតម្លៃលើការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់
- ផ្តល់ពិន្ទុលើលើការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់

**ខែកុម្ភៈ ឆ្នាំ២០១៥**

**ផលិតដោយ៖**

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)**

http://www.comfrel.org/

ខ្លឹមសារក្នុងរបាយការណ៍ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ។

រូបថតក្របមុខ៖ ដកស្រង់ពីគេហទំព័រ

**ឧបត្ថម្ភដោយ៖**

diakonia PEOPLE CHANGING THE WORLD

NORWEGIAN PEOPLE'S AID

Oxfam

OPEN SOCIETY FOUNDATIONS

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ទស្សនវិស័យ ៖ សង្គមប្រជាធិបតេយ្យដែលការធ្វើប្រជាធិបតេយ្យភាវូបនីយកម្ម ជាពិសេសការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ត្រូវបានលើកកម្ពស់ និងមានគុណភាពផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១

រាជរដ្ឋាភិបាលនីតិកាលទី៥ បានដាក់ចេញ និងប្រកាសគោលនយោបាយរបស់ខ្លួនដោយបានបែងចែងជា០៤ វិស័យធំៗ រួមមាន៖១. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,២. ការពង្រឹងរដ្ឋបាលសាធារណៈ,វិមជ្ឈការ និងវិសហមជ្ឈការ, ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ, ៣.ការអភិវឌ្ឍសេដ្ឋកិច្ច និង ៤, ការអភិវឌ្ឍវិស័យអប់រំ, សុខាភិបាល, ការងារ, វប្បធម៌ និង សង្គមកិច្ច។ ក្នុងវិស័យទាំងបួន(០៤)នេះ គេឃើញមានចំណុចតូចៗជាច្រើនដែលរាជរដ្ឋាភិបាលបានសន្យាថានឹងសម្រេចឲ្យបាន ឬបន្តអនុវត្តក្នុងនីតិកាលទី៥នេះ ប៉ុន្តែចំណុចនៃការសន្យាទាំងនោះមិនត្រូវបានកំណត់ជាចំនួនជាក់លាក់នោះទេ។ មានតែគោលនយោបាយ១៦ចំណុចតែប៉ុណ្ណោះមានសូចនាករច្បាស់លាស់គឺនៅក្នុងវិស័យទី០៣ និងទី០៤ ។សម្រាប់គោលនយោបាយដែលគ្មានសូចនាករច្បាស់លាស់ មាន៣៣ចំនុច ខុមហ្វ្រែលបានធ្វើការប្រមូលទិន្នន័យ និងព័ត៌មានទាំងនោះ ដើម្បីឲ្យប្រជាពលរដ្ឋជាម្ចាស់ឆ្នោតបោះឆ្នោតផ្តល់ពិន្ទុ។

ក្នុងរយៈពេលមួយ (០១) ឆ្នាំដំបូងនៃរដ្ឋសភានីតិកាលទី៥ រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចពេញលេញនូវការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%)នៃ១៦ ចំណុចនៃគោលនយោបាយដែលមានសូនាករច្បាស់លាស់ រួមមានដូចជា៖ កំណើនកំណើនសេដ្ឋកិច្ច ៧%ក្នុងមួយឆ្នាំ, ការកាត់បន្ថយភាពក្រីក្រក្នុង អត្រា ០១%ក្នុងមួយឆ្នាំ, ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច, ការកែលម្អផ្លូវលំជនបទជាជំហានៗពីផ្លូវក្រាល គ្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង, ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស។

ចំណែកគោលនយោបាយចំនួន០៧រួមមាន ការរក្សាផ្ទៃនេសាទទឹកសាប, ការចុះបញ្ជីដីធ្លី, ការកសាងគោលនយោបាយជាតិស្តីពីសិទ្ធិលំនៅស្ថាន, ប្រជាជនទទួលសេវាទឹកស្អាត, ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ, បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានរាជរដ្ឋាភិបាលបានអនុវត្តន៍ ឬ/និងសម្រេចបានខ្លះ។ ឯគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រចបានតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងបីនោះមានដូចជា គោលនយោបាយនាំចេញអង្ករឲ្យបាន ១លានតោន នៅឆ្នាំ២០១៥, ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធន៍និវត្តន៍សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន។

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

ចំពោះការផ្តល់ពិន្ទុសម្រាប់ឆ្នាំទី១(ករណីសិក្សា នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប) មានប្រជាពលរដ្ឋចំនួនភាគច្រើននៃ ៤៤,៤% ពេញចិត្តខ្លះចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយ៣៣ចំណុចដែលមិនមានសូចនាកររបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់ ៥៥,៦% មិនពេញចិត្តនឹងការអនុវត្តគោលនយោបាយទាំងនោះក្នុងរយៈពេលមួយឆ្នាំកន្លងមក។

ក្នុងចំណោមគោលនយោបាយទាំង០៤វិស័យ ការបំពេញ/អនុវត្តន៍គោលនយោបាយការអភិវឌ្ឍនវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច ត្រូវបានប្រជាពលរដ្ឋនៅខេត្តសៀមរាប និងរាជធានីភ្នំពេញ ពេញចិត្ត[1]ច្រើនជាងគេ (៥០,៧%) ប៉ុន្តែចំនួនប្រជាជន ភាគច្រើនបានផ្តល់ពិន្ទុពេញចិត្តខ្លះតែប៉ុណ្ណោះ ខណៈដែលការផ្តល់ពិន្ទុមិនពេញចិត្ត មានប្រជាពលរដ្ឋរហូតដល់ជាង៤៩% បានផ្តល់ពិន្ទុមិនពេញចិត្តទាំងស្រុង ឬពេញចិត្តតិចតួច។ បើមើលថវិកាជាតិដែលគ្រោងចំណាយឆ្នាំ២០១៤ចំនួន៣៤០០លានដុល្លាសហរដ្ឋអាមេរិកវិញ រាជរដ្ឋាភិបាលគ្រោងចំណាយលើវិស័យសង្គមកិច្ច ចំនួន ២៣,៣%, វិស័យការពារជាតិ និងសន្តិសុខ ចំនួន ១៣,៨%, វិស័យសេដ្ឋកិច្ច ចំនួន ៨,៩% និងវិស័យរដ្ឋបាលទូទៅចំនួន ៨,២% នៃថវិកាជាតិសរុបដែលរួមបញ្ចូលទាំងថវិកាមិនទាន់បែងចែង។ ហើយការចំណាយលើវិស័យសង្គមកិច្ចគឺច្រើនជាងគេ បើធៀបនឹងវិស័យបីផ្សេងទៀត។

ចំណែកការអនុវត្តន៍គោលនយោបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈត្រូវបានប្រជាពលរដ្ឋក្នុងខេត្តទាំងពីរមិនពេញចិត្តច្រើនជាងគេវិញ (៦១,៤%) ក្នុងចំណោមគោលនយោបាយទាំងអស់។ រាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាជាតិមានចំនួន១៣,៨% ច្រើនលំដាប់ទី២ ចំពោះការអនុវត្តន៍គោយោបាយវិស័យនេះ។ លទ្ធផលនៃការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តន៍គោលនយបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈគឺមិនល្អប្រសើរឡើយ បើធៀបនឹងការចំណាយថវិកាលើវិស័យនេះ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា គឺស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាតែមួយគត់ ខុសពីអាណត្តិមុនៗដែលរាជរដ្ឋាភិបាលសម្ព័នភាពកើតចេញពីការដឹកនាំរបស់គណបក្សកាន់ អំណាចគឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច។ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះខ្វះនីត្យានុកូលភាព ដោយសារតែការបង្កើតរាជរដ្ឋាភិបាលមិនស្របតាមនីតិវិធីរដ្ឋធម្មនុញ្ញ ព្រោះថា ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលធ្វើតាមនីតិវិធីបោះឆ្នោតជាកញ្ចប់ ជាមួយការបោះឆ្នោតជ្រើសតាំងប្រធាន, អនុប្រធានរដ្ឋសភា និងប្រធាន, អនុប្រធាន និងសមាជិកគណៈកម្មាការនានានៃរដ្ឋសភា កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងសម័យប្រជុំលើកទី១ ដោយអនុវត្តតាម មាត្រា ៤[2] នៃច្បាប់ធម្មនុញ្ញបន្ថែម ឆ្នាំ២០០៤។ ច្បាប់ធម្មនុញ្ញបន្ថែម ត្រង់មាត្រា ៣ បានចែងយ៉ាង

---

[1] តម្លៃនៃការពេញចិត្ត គឺផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញតទី២(ពេញចិត្តខ្លះ), ទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល), ទី៤(ពេញចិត្តច្រើន) និងទី៥ (ពេញចិត្តស្ទើទាំងស្រុង ឬទាំងស្រុង)

[2] ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង(ប្រធាន អនុប្រធាន ក៏ដូចជាប្រធាននិងអនុប្រធានគណៈកម្មការ) និងផ្តល់សេចក្តីទុកចិត្ត(ចំពោះសមាជិករដ្ឋាភិបាល)ត្រូវអនុវត្តដូចខាងក្រោម៖

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំ និងស្នើដោយគណបក្សនយោបាយ ដែលព្រមព្រៀងគ្នាបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវធ្វើជូនព្រឹទ្ធសមាជិករដ្ឋសភា។
- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិកសភា ព្រះមហាក្សត្រទ្រង់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជដែលត្រូវបាចាតតាំងនេះត្រូវរៀបចំផ្គូរផ្គងដំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលរួចធ្វើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។
- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូច ជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់ នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។

ច្បាស់ថា ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ថ្មី និង ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន ទើបច្បាប់ធម្មនុញ្ញបន្ថែមមាត្រា៤ត្រូវបានគេអនុវត្ត។

រាជរដ្ឋាភិបាលនីតិកាលទី៥ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបានបង្កើនក្រសួងដល់ចំនួន២៨ ដោយលុបអាជ្ញាធរជាតិមួយ។ ហើយរាជរដ្ឋាភិបាលនេះ នៅតែមានចំនួនច្រើនរហូតដល់ប្រមាណ ៦០០នាក់ ក្នុងនោះសមាជិករាជរដ្ឋាភិបាលមានចំនួន ២៤៤រូប និង អនុរដ្ឋលេខាធិការមានចំនួន២៣៨ រូប ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាលចំនួនប្រមាណជា ១០០រូប និងមន្ត្រីនយោបាយជាន់ខ្ពស់ច្រើនរូបទៀតផង ដោយសារតែគ្មានបទបញ្ញត្តិនៃ ច្បាប់ចែងកំណត់អំពីចំនួនក្រសួង សមាជិកគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ឬ/និងនាយករដ្ឋមន្ត្រី។ អ្វីគួរកត់សម្គាល់នោះ គឺចំនួនស្ត្រីក្នុងសមាសភាពគណៈរដ្ឋមន្ត្រីបានកើនឡើងដល់ ១៧% នៃនីតិកាលទី៥។

ប្រៀបធៀបជាមួយប្រទេសជិតខាង ជាពិសេសប្រទេសនៅក្នុងតំបន់ជាមួយគ្នា រចនាសម្ព័នដឹកនាំរាជរដ្ឋាភិបាលប្រទេសកម្ពុជានាពេលបច្ចុប្បន្នពិតជាមានចំនួនច្រើន ខណៈដែលចំនួនសមាជិកសភា នានីតិកាលទី៥ មិនសមាមាត្រនឹងប្រជាសាស្ត្រ ទំហំភូមិសាស្ត្រ និងសេដ្ឋកិច្ច។ ផលទុនសរុបប្រចាំឆ្នាំ២០១៣ របស់ប្រជាពលរដ្ឋកម្ពុជាគឺ $១០០៧ សម្រាប់ប្រជាពលរដ្ឋម្នាក់ៗ ខណៈដែលប្រទេសបង់ក្លាដេសមានចំនួន $៩៥៨។ ទិន្នន័យឆ្នាំ២០១៣បង្ហាញថា បង់ក្លាដេសជាប្រទេសមានប្រជាជនចំនួន ១៥៨.៥១៣.០០០ នាក់[3] មានសមាជិកគណៈរដ្ឋមន្ត្រីចំនួនតែ ៥៥ រូបប៉ុណ្ណោះ។ លើសពីនេះទៀត ឥណ្ឌា ប្រទេសដែលមានប្រជាជនចំនួន ១,២៦៧,៤០២,០០០ និងផលទុនសរុបសម្រាប់ម្នាក់ចំនួន $១,៤៩៩ មានសមាសជិកគណៈរដ្ឋមន្ត្រីត្រឹមតែ ៦៦ រូបប៉ុណ្ណោះ។ចំនួនប្រជាជននៃប្រទេសទាំងពីរ ច្រើនជាងប្រទេសកម្ពុជាដល់ទៅជាងរាប់សិបដង ប៉ុន្តែកម្ពុជាមានសមាជិកគណៈរដ្ឋមន្ត្រីរហូតចំនួន ២៤៤ នាក់[4] ដោយមិនទាន់រាប់បញ្ចូលអនុរដ្ឋលេខាធិការដែលមានចំនួន២៣៨រូបនោះទេ។

ខុមហ្វ្រែល បានរៀបចំរបាយការណ៍ស្តីពី ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១ ផ្អែកលើការវិភាគព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេង ដើម្បី វាយតម្លៃលើការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់។ សម្រាប់មួយផ្នែកផ្សេងទៀតគឺការផ្តល់ពិន្ទុដោយប្រជាពលរដ្ឋតាមរយៈ វេទិកាម្ចាស់ឆ្នោតត្រូវបានរៀបចំឡើង នៅក្នុងខេត្តសៀមរាប និងរាជធានីភ្នំពេញ ដែលមានប្រជាពលរដ្ឋចូលរួម ប្រមាណជា ២៥០នាក់ កាលពីចុងឆ្នាំ២០១៤។ ប្រជាពលរដ្ឋផ្តល់ពិន្ទុចំនួនពីរលើក[5] លើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយដែលមិនមានសូចនាករច្បាស់លាស់ចំនួន៣៣ ចំណុចរបស់រាជរដ្ឋាភិបាល។

---

[3] http://data.worldbank.org/indicator/SP.POP.TOTL

[4] នាយរដ្ឋមន្ត្រី១រូប, ឧបនាយករដ្ឋមន្ត្រី ០៩ រូប, ទេសរដ្ឋមន្ត្រី ១៥រូប, រដ្ឋមន្ត្រី ៣៣ រូប (រដ្ឋមន្ត្រីអមគណៈប្រតិភូ ១៤), រដ្ឋលេខាធិការ ១៨៧រូប

[5] លើកទី១ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋផ្ទាល់, លើកទីពីរផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋ រួមទាំងព័ត៌មានដែលបានផ្តល់ជូនដោយវាគ្មិន

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

| | | |
|---|---|---|
| ១. លោក **យង់ គឹមអេង** | សមាជិកគណៈកម្មាធិការនាយក | ០១៦ ៨២ ៨២ ១១ |
| ២.លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ | ០១២៩៤ ២០ ១៧ |
| ៣. លោក **គឹម ឈន** | អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធី | ០១២ ៩៤ ២០ ១៩ |
| ៤. លោក **សៀន ប៊ុនរិទ្ធ** | មន្ត្រីផ្នែកអង្កេត | ០៨៩ ២១ ២១ ១០ |
| ៥. លោក **យឿង សុធារ៉ា** | មន្ត្រីផ្នែកអង្កេត និងច្បាប់ | ០៩២ ៦៥ ៨៣ ១៨ |

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

Phnom Penh 23 February 2015

# Press Release

## 'Assessment and Voters' Score Card on the First Year Fulfillment of Political Platform of the Fifth Mandate of Government'

The Royal Government of Cambodia (RGC) declared and launched its political platform incorporating four main sectors: 1: National defence, security and public order, 2: Improvement of public administration, decentralization and deconcentralization, law and justice, and anti-corruption activities, 3: Development of economics and 4: Development of education, health, labor, culture and social affairs. Many points of political platform that the RGC promises to fulfill are found in these four sections, but only 16 points in the 3rd and 4thr are considered as precise indicators. Another 33 points without precise indicators are also scored based upon whether they have been fulfilled or not.

In the year since the beginning of the fifth legislature of the National Assembly (NA), the RGC has fully fulfilled 6 (37.5%) of 16 political platforms with precise indicators They are: annual 7% economic growth, annual 1% poverty reduction, halting of economic land concessions , improvement of rural roads, transportation policy creation and an increase in foreign tourist numbers .

While another seven political platforms related to water for family fishing, land title registration, national housing policy design, people's access to running water, village electricity supplies, secondary school construction in all communes and national career and labor policy design, have only been partly fulfilled or/and implemented by the RGC. Three political platform promises have been implemented but when compared to the previous performance the RGC is unlikely fulfill them. For example, one million tons of rice exports in 2015, maintenance of existing forest cover, and implementation of -retirement allowance in the private sector.

For the first year, voters' score card on the fulfillment of political platform with imprecise indicator in Phnom Penh and Siem Reap, 44.4%[1] of participants are partly satisfied, while 55.6% are not satisfied.

On the fulfillment of the Development of Education, Health, Labor, Culture and Social Affairs, 50.7%[2] of participants are partly satisfied, while 49% are less or completely dissatisfied.

---

[1] An average of partly satisfying, averagely satisfying, quite satisfying and strongly or completely satisfying
[2] An average of partly satisfying, averagely satisfying, quite satisfying and strongly or completely satisfying

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

Looking at the 2014 national budget, the RGC planned to spend US$3,400 million including in the budget which was not allocated. It may have spent 23.3% on social affairs, 13.8% on national defence and security, 8.9% on the economic sector, and 8.2% on general administration. The expenditure on social affair is the highest of the four sectors

61.4% of people are dissatisfied with the fulfillment of national defense security and public order commitments. This sector received the most dissatisfaction while the government may have spent 13.8 % of the total national budget which second largest. The result of satisfaction on the fulfillment of this sector is not better if compared with the amount of expenditure.

The RGC of the fifth legislature of the National Assembly (NA) is led by the Cambodian People's Party (CPP). In the previous mandate the RGC was considered to be a coalition government as it consisted of two parties, CPP and FUNCINPEC. The RCG's currently lacks legitimacy because it was formed after having not followed constitutional procedure. . The vote of confidence in the proposed government and the vote for the leadership of NA were conducted with package vote on 24 December 2013 in the first plenary session. It was preceded with article 4[3] of the extra constitutional law, while it says in article 3 that if the objectives of procedures stipulated in aticles 82 and 119 New of the Constitution cannot be achieved, article 4 of the extra constitutional law will be practised.

The RGC led by the CPP has increased the number of ministries to 28 as a result of the cancellation of public service department the government currently consists of about 600 officials including 244 members of cabinet, 238 under general secretaries of state, about one hundred governmental advisors and other high raking political offials. The number of governmental members has increased as there is no law or provision that stipulate how many ministries, members of carbinet, under general secretaries of state and governmental members elected by the government and the prime minister are. It is noted that for the fifth legislature, the number of female members of cabinet has increased by 17%.

Compared with neighboring countries, the fifth legislature government is made up with a large number of cabinet members that is not proportional to the number of National Assembly members, the general population or the geographic and economic situation. According to Cambodia's Gross Domestic Product (GDP) in 2013, per capita income was US $ 1,007 US. Bangladesh, a country with a population of 158, 518,000 with a GDP of US$958 in 2013, has only 55 members of carbinet. Moverover, India with 1, 267, 402,000 people and US$1,499 US GDP had only 66 member of cabinet. The population of these two countries is many times more than Cambodia, but Cambodia has 244 cabinet members and 238 under general secretaries of state.

[3] The list of candidates for package vote on the election and vote of confidence is prepared as follows:

- The list of candidates for President and vice-president of the National Assembly, as well as the chairpersons and vice-chair person of the commissions of the National Assembly shall be prepared and proposed by the political party that agree to form a coalition government, and shall be sent to the oldest member of the National Assembly.
- Upon the request by the political party that won the most seats in the National Assembly, made through the oldest member of the National Assembly, the King shall appoint a dignitary from among National Assembly Member of the winning party to propose the Royal Government. The appointed dignitary shall prepare and send to the oldest Member of the National Assembly a list of propose member of the Royal Government.

The report on an Assessment and Voters' Score Card on the First Year Fulfillment of the Political Platform of the Fifth Mandate Government compiled by COMFREL is based on analysis of existing primary data from NGO, INGO, press agencies and national institutions for making an assessment on the fulfillment of political platforms with precise indicator. For an assessment on fulfillment of the political platform with imprecise indicators, some voters' score card forums were conducted in Phnom Penh and Siem Reap with about 250 participants in December 2014. Thirty three points of political platform with imprecise indicator were scored two times[4].

***For further information, contact:***

| | | | |
|---|---|---|---|
| 1. | Mr.Yong Kim Eng | Board Director Member | 016 82 82 21 |
| 2. | Koul Panha | Executive Director | 012 94 20 17 |
| 3. | Mr.Kim chhorn | Senior Program Coordinator | 012 94 20 19 |
| 4. | Mr.Sean Bunrith | Monitoring Officer | 089 21 21 10 |
| 5. | Mr.Yoeung Sotheara | Monitoring and legal officer | 092 65 83 18 |

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

[4] Political platforms with imprecise indicator is first scored with participant's knowledge and second scored with not only their knowledge but also information of fulfillment of them from the speaker.

# របាយការណ៍

## ស្តីពី

## ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផល
## នៃការបំពេញ/អនុវត្តន៍គោលនយោបាយ
## របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១

ខែ កុម្ភៈ ឆ្នាំ ២០១៥

មាតិកា


I. ខ្លឹមសារសង្ខេប.....1

II. សេចក្តីផ្តើម.....1

III. វិធីសាស្ត្រ និងទំហំនៃរបាយការណ៍.....2

IV. ការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី៥.....3

V. ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសមាជិក នៃរាជរដ្ឋាភិបាល.....4

1. សមាជិករាជរដ្ឋាភិបាល.....4

2. ការបង្កើត ឬកែសម្រួលក្រសួងថ្មី.....6

ក. ក្រសួងមុខងារសាធារណៈ.....6

ខ. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល.....6

VI. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥.....7

VII. ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយសម្រាប់ឆ្នាំទី១.....8

1. ការបំពេញអនុវត្តគោលនយោបាយមានសូចនាករច្បាស់លាស់.....8

2. ការផ្តល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាកច្បាស់លាស់ (ករណីសិក្សា៖ រាជធានីភ្នំពេញ និងខេត្តសៀមរាប).....27

វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ.....27

វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ.....27

វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច.....28

វិស័យទី4៖ ការអភិវឌ្ឍនវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច.....28

លទ្ធផលការផ្តល់ពិន្ទុលើកាអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងបួនវិស័យ នៅរាជធានីភ្នំពេញ និង ខេត្តសៀមរាប.....29

លទ្ធផលជាមធ្យមនៃការពេញចិត្ត និងមិនពេញចិត្តចំពោះការអនុវត្ត/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាល៖.....30

VIII. សេចក្តីសន្និដ្ឋាន.....31

ឧបសម្ព័ន្ធ.....32

## I. ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ដោយការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជាកញ្ចប់ ដោយតំណាងរាស្ត្រនៃរដ្ឋសភាគណបក្សប្រជាជនកម្ពុជា ព្រោះតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមិនបានចូលប្រជុំសភាដំបូង ដែលច្បាប់រដ្ឋធម្មនុញ្ញបានចែងថា ជាការប្រជុំបង្កើតសភានីតិកាលថ្មី។ ក្រោយបង្កើតរាជរដ្ឋាភិបាល លោកនាយករដ្ឋមន្ត្រីបានប្រកាសដាក់ចេញជាផ្លូវការនូវកម្មវិធីនយោបាយរបស់ខ្លួនដែលមាន០៤វិស័យធំៗ។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។

ក្នុងគោលបំណងបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវខ្ពស់ ខុមហ្វ្រែលបានធ្វើការអង្កេត និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោត វាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដោយសិក្សា និងវិភាគលើរបាយការណ៍ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ និងផ្តល់ឱកាសឲ្យប្រជាពលរដ្ឋ ផ្តល់ពិន្ទុលើការអនុវត្តន៍គោលនយោបាយនោះ។

មុនការចូលសភារបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ រាជរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា ត្រូវបានអ្នកខ្លះយល់ថា ជារាជរដ្ឋាភិបាលខ្វះនីត្យានុកូលភាព ព្រោះកើតចេញពីរដ្ឋសភាឯកបក្ស។ សម្រាប់រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥នេះ ចំនួនក្រសួងចំនួនកើនឡើងដល់២៨ និងរដ្ឋលេខាធិការដ្ឋានចំនួន០១។ សមាសភាពគណៈរដ្ឋមន្ត្រីមានចំនួន២៤៨រូបធ្លាក់ចុះចំនួន៥% បើធៀបនឹងនីតិកាលទី៤។ ចំណែកឯសមាសភាពស្ត្រីក្នុងគណៈរដ្ឋមន្ត្រីបានកើនឡើងដល់ទៅប្រមាណ១៧%។ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទៅជាក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពលយ៉ាងប្រញាប់ប្រញាល់ហាក់ដូចជាមិនមានការគ្រោងទុក។

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយតាមវិស័យចំនួន០៤ គឺ១.ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ៣. ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង៤. ការអភិវឌ្ឍន៍វិស័យអប់រំសុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។ ក្នុងគោលនយោបាយទាំងនោះ មានតែ១៦ចំណុចតែប៉ុណ្ណោះមានសូចនាករច្បាស់លាស់ នៅក្នុងវិស័យទី០៣ ទី០៤ និង៣៣ចំណុច គ្មានសូចនាករច្បាស់លាស់។

ក្នុងរយៈពេលមួយ (០១) ឆ្នាំដំបូង រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ចំណុច(៣៧,៥%) និងសម្រេចបានខ្លះចំនួន៧ចំណុច។ ខណៈដែលគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្តតែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ ចំពោះលទ្ធផលការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់វិញ ត្រូវបានប្រជាពលរដ្ឋចំនួន៤៤,៤% ពេញចិត្តចំពោះលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយទាំងនោះ ដែលភាគច្រើននៃប្រជាពលរដ្ឋទាំងនោះពេញចិត្តខ្លះតែប៉ុណ្ណោះ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់ ៥៥,៦% មិនពេញចិត្តនឹងលទ្ធផលនការបំពេញ/អនុវត្តគោលនយោបាយទាំងនោះ។

## II. សេចក្តីផ្តើម

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានអនុវត្តគម្រោងឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិបាល តាំងពីនីតិកាលទី៣នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ រហូតដល់នីតិកាលទី០៥នៃរដ្ឋសភា។ របាយការណ៍ឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិបាល ត្រូវបានបង្កើត

ឡើងជារៀងរាល់ឆ្នាំ ដើម្បីធ្វើការវាយតម្លៃចំពោះការអនុវត្តន៍ការសន្យា ផ្អែកតាមគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញនៅដើមនីតិកាលនីមួយ។ រាជរដ្ឋាភិបាលនីតិកាលទី៥នេះ ត្រូវបានរដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្តថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ដោយសម្លេងគាំទ្រ៦៨/៦៨នៃតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដោយអវត្តមានតំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិចំនួន៥៥រូប ក្នុងដំណើរការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ។

រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា គឺស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាតែមួយគត់ ខុសពីអាណត្តិមុនៗដែលរាជរដ្ឋាភិបាលសម្ព័ន្ធភាពកើតចេញពីការដឹកនាំរបស់គណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច។

ក្រោយពីចូលកាន់តំណែងនាយករដ្ឋមន្ត្រី បានប្រកាសដាក់ចេញជាផ្លូវការនូវកម្មវិធីនយោបាយរបស់ខ្លួនដែលមាន០៤វិស័យធំៗ ដែលមានការសន្យាជាច្រើនទៀតនៅក្នុងវិស័យនីមួយៗនៃកម្មវិធីនយោបាយ។ លោកនាយករដ្ឋមន្ត្រីបានចំណាយពេលជាច្រើនម៉ោង បង្ហាញសមាជិកគណៈរដ្ឋមន្ត្រី ពីគោលនយោបាយសម្រាប់នីតិកាលទី៥ និងការអនុវត្តន៍កំណែទម្រង់វិស័យធំៗឱ្យស៊ីជម្រៅទៀតផង។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។

ដើម្បីបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវនូវអ្វីដែលបានសន្យា ខុមហ្វ្រែលបានធ្វើការអង្កេត និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោតវាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

សម្រាប់ការសង្កេត ខុមហ្វ្រែលបានសិក្សាលើរបាយការណ៍ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ និងគោលនយោបាយ ដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល។ ដោយឡែក ការផ្តល់ពិន្ទុវិញ ខុមហ្វ្រែលរៀបចំទម្រង់វាយតម្លៃដាក់ពិន្ទុដោយ ម្ចាស់ឆ្នោតទៅលើចំណុចនៃកម្មវិធីនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់ និងផ្តល់ឲ្យវាគ្មិនចែករំលែក វិភាគលើទិន្នន័យបឋមរបស់ស្ថាប័ន ឬអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងវិស័យទាំងនោះ។

## III. វិធីសាស្ត្រ និងទំហំនៃរបាយការណ៍

របាយការណ៍នេះកើតចេញពីការវិភាគលើទិន្នន័យ និងព័ត៌មាន និងការផ្តល់ពិន្ទុ។ ផ្នែកទី១នៃរបាយការណ៍នេះ ផ្អែកលើព័ត៌មាន ឬទិន្នន័យដែលមានស្រាប់ មកពីប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥។ គោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី០៥ ដែលមានសូចនាករច្បាស់លាស់ត្រូវបានវិភាគ និងវាយតម្លៃ។

សម្រាប់មួយផ្នែកផ្សេងទៀតនៃរបាយការណ៍ វេទិកាម្ចាស់ឆ្នោតចំនួនពីរ ត្រូវបានរៀបចំឡើងនៅក្នុងខេត្តសៀមរាប មានប្រជាពលរដ្ឋចូលរួមចំនួនប្រមាណជា១០០នាក់ និងនៅរាជធានីភ្នំពេញមានប្រជាពលរដ្ឋចូលរួមប្រមាណ១៥០នាក់ កាលពីចុងឆ្នាំ២០១៤ ដើម្បីឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាលក្នុងឆ្នាំទី១។ ការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន៣៣ផ្នែក ដែលមិនមានសូចនាករច្បាស់លាស់ ត្រូវបានឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុដោយប្រើប្រាស់ម៉ាស៊ីនផ្តល់ពិន្ទុ តាមអញ្ញត្តិដូចខាងក្រោម៖

| អញ្ញត្តិ | តម្លៃ | ភាគរយនៃការពេញចិត្ត |
|---|---|---|
| ១ | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | ០-២០% |
| ២ | ពេញចិត្តខ្លះ | ២១%-៤០% |
| ៣ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | ៤១%-៦០% |
| ៤ | ពេញចិត្តច្រើន | ៦១%-៨០% |
| ៥ | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | ៨១%-១០០% |

ប្រជាពលរដ្ឋបានធ្វើការផ្តល់ពិន្ទុចំនួនពីរលើក ចំពោះការលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ។ ការផ្តល់ពិន្ទុលើកទី១ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋផ្ទាល់ ចំណែកឯការផ្តល់ពិន្ទុលើកទី២ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋ រួមទាំងព័ត៌មានដែលបានផ្តល់ជូនដោយវាគ្មិនរួមមាន៖ តំណាងរាជរដ្ឋាភិបាល តំណាងរាស្ត្រ តំណាងអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យដែលធ្វើការពាក់ព័ន្ធនឹងការតាមដានការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

## IV. ការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី៥

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥នៃរដ្ឋសភានេះខ្វះនីត្យានុកូលភាព ដោយសារតែការបង្កើតរាជរដ្ឋាភិបាល មិនស្របតាមនីតិវិធីរដ្ឋមន្ត្រី។

ក្រោយពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានបញ្ចប់ទៅ និងត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសលទ្ធផលជាផ្លូវការរួចមក នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ រដ្ឋសភាជាតិបានបើកកិច្ចប្រជុំដំបូង ក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ **នរោត្តម សីហមុនី**។ នៅក្នុងកិច្ចប្រជុំនេះ មានតែបេក្ខជនជាប់ឆ្នោតចំនួន៦៨រូប មកពីគណបក្សប្រជាជនកម្ពុជា ក្នុងចំណោមបេក្ខជនជាប់ឆ្នោតទាំង១២៣រូប ដោយបេក្ខជនជាប់ឆ្នោតចំនួន៥៥រូប ទៀតនៃគណបក្សសង្គ្រោះជាតិបានធ្វើពហិការមិនព្រមចូលរួម ដោយពួកគេបានបដិសេធ មិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោតដែលប្រកាសគ.ជ.ប នោះទេ។

ដំណើការនីតិវិធីរៀបចំបោះឆ្នោតជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានានៃរដ្ឋសភា និងមានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលនីតិកាលទី៥នេះ គឺធ្វើឡើងដោយបោះឆ្នោតជាកញ្ចប់ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងសម័យប្រជុំលើកទី១ ដោយយកមាត្រា៤[1] នៃច្បាប់ធម្មនុញ្ញបន្ថែម ឆ្នាំ២០០៤ មកអនុវត្ត។

---

[1] ការរៀបចំបញ្ជីរាយនាយបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង (ប្រធាន អនុប្រធាន ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការ) និងផ្តល់សេចក្តីទុកចិត្ត (ចំពោះសមាជិករដ្ឋាភិបាល) ត្រូវអនុវត្តដូចខាងក្រោម៖

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំ និងស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នាបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។
- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិកសភា ព្រះមហាក្សត្រទ្រង់ តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សនយោបាយ ដែលឈ្នះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងដំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។

ប៉ុន្តែបើពិនិត្យមើលទៅលើច្បាប់ធម្មនុញ្ញបន្ថែមនៃច្បាប់នេះ ត្រង់មាត្រា៣ បានចែងយ៉ាងច្បាស់ថា ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា៨២ថ្មី និង១១៩ថ្មីនៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភាតាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះសមាជិករដ្ឋាភិបាល។ ចំណែកមាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី២បានចែងថា មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់គណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ដោយឡែក វាក្យខណ្ឌទី១ មាត្រា១១៩ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលបោះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្គូរផ្គងឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ផ្អែកលើនីតិវិធីដែលបានរៀបរាប់ ដើម្បីបង្កើតរាជរដ្ឋភិបាល យោងតាមបទបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជាធរមាន ដំបូងគេត្រូវបង្កើតថ្នាក់ដឹកនាំរដ្ឋសភាតាម មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញជាមុនសិន រួចទើបអនុវត្តមាត្រា១១៩ថ្មី រដ្ឋធម្មនុញ្ញ។

យោងលើមាត្រា៨២ថ្មី គេត្រូវការសំឡេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល គឺ៦២សម្លេងតែប៉ុណ្ណោះ ដើម្បីបោះឆ្នោតបង្កើតថ្នាក់ដឹកនាំរដ្ឋសភា ខណៈដែលកូរ៉ុមសម្រាប់សម័យប្រជុំលើកទី១នោះមានចំនួនដល់ទៅ៦៨ ដែលសមាសភាពទាំងអស់នោះមកពីគណបក្សប្រជាជនកម្ពុជា។ ដូច្នេះពិតប្រាកដណាស់ដែលយើងអាចសន្និដ្ឋានថា មាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញត្រូវសម្រេចបាន ដោយមិនចាំបាច់ប្រើប្រាស់មាត្រា៤នៃច្បាប់ធម្មនុញ្ញបន្ថែម ដែលនាំឲ្យផ្ទុយពីស្មារតីមាត្រា៨២ថ្មី និងមាត្រា១១៩ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា៣នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម។

## V. ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសមាជិក នៃរាជរដ្ឋាភិបាល

### 1. សមាជិករាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី៥ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបង្កើនក្រសួងដល់ចំនួន២៨ ដោយលុបអាជ្ញាធរជាតិមួយចំនួន។ ហើយរាជរដ្ឋាភិបាលនេះ នៅតែមានចំនួនច្រើនរហូតដល់ប្រមាណ៦០០នាក់ ក្នុងនោះសមាជិករាជរដ្ឋាភិបាលមានចំនួន២៤៤រូប និងអនុរដ្ឋលេខាធិការមានចំនួន២៣៨រូប ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាលចំនួនប្រមាណជា១០០រូប និងមន្ត្រីនយោបាយជាន់ខ្ពស់ច្រើនរូបទៀតផង ដោយសារតែគ្មានបទបញ្ញត្តិនៃច្បាប់ចែងកំណត់អំពីចំនួនក្រសួង សមាជិកគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ឬ/និងនាយករដ្ឋមន្ត្រី។

រាជរដ្ឋាភិបាលនៃនីតិកាលទី៥ ខណៈដែលចំនួនក្រសួងមានការកើនឡើងគេអាចសន្និដ្ឋានបានថា រាជរដ្ឋាភិបាលមិនទាន់ចាត់ចែង ឬបង្កើតតួនាទីសមាជិករដ្ឋាភិបាលដូចជា រដ្ឋលេខាធិការជាដើម ផ្អែកលើតម្រូវការពិតប្រាកដ ឬចាំបាច់នៃការងារនោះទេ។ ចំនួនសមាជិក និងតួនាទីទាំងនោះហាក់ដូចជា ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមហេតុផលនយោបាយចែកអំណាចច្រើនជាង ដូចគ្នានឹងរាជរដ្ឋាភិបាលសម្ព័ន្ធភាពនីតិកាលទី៤ មាន

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជននាយករដ្ឋមន្ត្រី និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។

សមាជិករាជរដ្ឋាភិបាល រហូតដល់ទៅ៣២នាក់ ស្មើនឹងជាង១២% មកពីគណបក្សហ៊្វុនស៊ិនប៉ិច ដែលស្ទើរតែទាំងអស់នៃសមាជិកទាំងនោះមានតួនាទីជារដ្ឋលេខធិការ។

រាជរដ្ឋាភិបាលនិតីកាលទី៥នេះ មានក្រសួងចំនួន២៨ និងរដ្ឋលេខាដ្ឋានចំនួន០១ ក្នុងនោះក្រសួងរ៉ែ និងថាមពលត្រូវបានបំបែកពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំណែកឯរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវបានតម្លើងជាក្រសួងមុខងារសាធារណៈ។ ប្រៀបធៀបជាមួយរាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជានីតិកាលទី៤ ចំនួនក្រសួងមានការកើនឡើងពីចំនួន២៦ ទៅ២៨ក្រសួង ខណៈដែលរដ្ឋលេខាធិការដ្ឋានថយចុះចំនួន០១។

មាត្រា៤ វាក្យលក្ខ័ណទី១ មាត្រា៤នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចែងថា សមាជិករាជរដ្ឋាភិបាលរួមមាន នាយករដ្ឋមន្ត្រី ឧបនាយរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ សម្រាប់នីតិកាលទី៥ ចំនួនសមាជិករាជរដ្ឋាភិបាល រួមទាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីមានចំនួនសរុប244នាក់ ស្រី41នាក់។ បើប្រៀបធៀបនឹងសមាជិកគណៈរដ្ឋមន្ត្រី នៅដើមនីតិកាលទី០៤[2] សមាជិករាជរដ្ឋាភិបាលនីតិកាលទី៥នេះមានការប្រែប្រួលដូចខាងក្រោម៖

| **ប្រភេទ** | **នីតិកាលទី៤ (ចំនួនតួនាទី)** | **នីតិកាលទី៥ (ចំនួនតួនាទី)** |
|---|---|---|
| ➢ នាយរដ្ឋមន្ត្រី | 01 (ស្រី 0នាក់) | 01 (ស្រី 0 នាក់) |
| ➢ ឧបនាយករដ្ឋមន្ត្រី | 09 (ស្រី 01នាក់) | 09 (ស្រី 01 នាក់) |
| ➢ ទេសរដ្ឋមន្ត្រី | 16 (ស្រី 0នាក់) | 15 (ស្រី 0 នាក់) |
| ➢ រដ្ឋមន្ត្រី | 26 (ស្រី 02នាក់)[3] | 28 (ស្រី 03 នាក់)[4] |
| ➢ រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី | 08 (ស្រី 0នាក់ ) | 14 (ស្រី 0 នាក់) |
| ➢ រដ្ឋលេខាធិការ | 206 (ស្រី 15នាក់) | 187 (ស្រី 38 នាក់)[5] |
| សរុបចំនួនតួនាទីនៃគណៈរដ្ឋមន្ត្រី | 266 | 254 |
| សរុបចំនួនសមាជិកនៃគណៈរដ្ឋមន្ត្រី (នាក់) | 257 នាក់ (ស្រី18នាក់) | 244 នាក់ (ស្រី 41នាក់) |

ផ្អែកលើទិន្នន័យខាងលើ ចំនួនសមាជិកនៃរាជរដ្ឋាភិបាលនីតិកាលទី៥ ថយចុះចំនួន១៣នាក់ ខណៈដែលចំនួនក្រសួងមានការកើនឡើងចំនួន០២ ប្រៀបធៀបនឹងនីតិកាលនីតិកាលទី៤។ សម្រាប់នីតិកាលនេះ រដ្ឋលេខាធិការថយចុះចំនួន១៩រូប និងរដ្ឋមន្ត្រីអមគណៈប្រតិភូថយចុះចំនួន០៦រូប។ សមាជិករាជរដ្ឋភិបាលនីតិកាលទី៥នេះ គឺមកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់ ខុសពីសមាជិករាជរដ្ឋាភិបាលនីតិកាលទី៤ ដែលមានសមាសភាពមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ព្រោះរាជរដ្ឋាភិបាលនីតិកាលទី៤ គឺជារាជរដ្ឋាភិបាលសម្ព័នភាពរវាងគណបក្សទាំងពីរ (គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច)។ អ្វីគួរកត់សម្គាល់នោះ គឺចំនួនស្ត្រីក្នុងសមាសភាពគណរដ្ឋមន្ត្រីបានកើនឡើងពី៧%នៃនីតិកាលទី៤ ដល់១៧%នៃនីតិកាលទី៥។ ប៉ុន្តែការកើនឡើងនេះ មិនទាន់ឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរបស់អង្គការសហប្រជាជាតិដែលកម្ពុ

[2] បញ្ជីរាយនាមសមាជិករាជរដ្ឋាភិបាលនីតិកាលទី៤ ចុះហត្ថលេខាថ្ងៃទី ២៥ ខែកញ្ញា ២០០៨ ដោយអគ្គលេខាធិការដ្ឋានរង រាជរដ្ឋាភិបាល។

[3] ស្ទួនជាមួយ ឧបនាយករដ្ឋមន្ត្រីចំនួន 05 នាក់ និងទេសរដ្ឋមន្ត្រី 04 នាក់ (នីតិកាលទី៤)។

[4] ស្ទួនជាមួយ ឧបនាយករដ្ឋមន្ត្រីចំនួន 05 នាក់ និងទេសរដ្ឋមន្ត្រី 04 នាក់ (នីតិកាលទី៥)។

[5] ស្ទួនជាមួយ រដ្ឋមន្ត្រីអមគណៈប្រតិភូចំនួន 01រូប។

ជាបានសន្យាថា សម្រេចឲ្យបាននូវចំនួន៣០%នៃសមាសភាពស្ត្រីនៅថ្នាក់ជាតិ ត្រឹមឆ្នាំ២០១៥នេះ។

2. **ការបង្កើត ឬកែសម្រួលក្រសួងថ្មី**

យោងមាត្រា៣៣នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីចែងថា ការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវកំណត់ដោយច្បាប់។ នៅដើមនីតិកាលទី៥នេះ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួល ឬបង្កើតក្រសួង ដែលមានក្រសួងចំនួនពីរបន្ថែមទៀត ។

**ក. ក្រសួងមុខងារសាធារណៈ**

អង្គការរដ្ឋទទួលបន្ទុកវិស័យមុខងារសាធារណៈ ដែលមានកម្រិតត្រឹម រដ្ឋលេខាធិការដ្ឋានយោងតាមព្រះរាជក្រមលេខនស/រកម/០១៩៦/២៤ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ត្រូវបានដំឡើងទៅជាក្រសួងមុខងារសាធារណៈ ដើម្បីចូលរួមក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គោលនយោបាយស្តីពីសេវាសាធារណៈ និងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។[6] អង្គការរដ្ឋមួយនេះ ត្រូវបានតម្លើងជាក្រសួងមុខងារសាធារណៈ ដោយរដ្ឋសភាបានអនុម័តច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្នុងសម័យប្រជុំទី១នៃរដ្ឋសភានីតិកាលទី៥ ហើយត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ប្រកាសឲ្យប្រើកាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ជាការប្រញាប់។

**ខ. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល**

អតីតក្រសួងឧស្សាហកម្មរ៉ែ និងថាមពល នៅដើមនីតិកាលទី៥ ត្រូវបានកែសម្រួលទៅជាពីក្រសួង៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរ៉ែ និងថាមពល។ ក្នុងលិខិតលេខ៣០ សជណ.កបច របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល បានលើកឡើងថា រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឧស្សាហកម្ម វិស័យរ៉ែ និងវិស័យថាមពល គឺជាមូលដ្ឋានសេដ្ឋកិច្ចដែលមានវិសាលភាពកាន់តែធំទូលាយ និងមានសក្តានុពលកាន់តែខ្ពស់ឡើងជាលំដាប់សម្រាប់ជម្រុញភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចជាតិ។ វិស័យទាំងនោះ ត្រូវបានកំណត់ជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។ ដើម្បីសម្រេចបាននូវគោលដៅកែប្រែប្រទេសកម្ពុជា ទៅជាប្រទេសឧស្សាហកម្ម តាមរយៈ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា** និងដើម្បីអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម តាមរយៈគោលនយោបាយលើកទឹកចិត្តផ្សេងៗ និងការធ្វើបច្ចុប្បន្នកម្មនៃគោលនយោបាយ **ក្របខណ្ឌនៃការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម** រាជរដ្ឋាភិបាលបានបង្កើត/កែសម្រួល អង្គការរដ្ឋមួយដែលមានសមត្ថកិច្ចគ្រប់គ្រងវិស័យឧស្សាហកម្ម និងសិប្បកម្ម គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម (អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល) តាមរយៈព្រះរាជក្រមប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួង ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខនស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣។ ស្របពេលជាមួយគ្នានេះ វិស័យរ៉ែ និងថាមពល ស្ថិតក្រោមការគ្រប់គ្រង់របស់ក្រសួងថ្មីមួយ គឺក្រសួងរ៉ែ និងថាមពលដែលត្រូវបានបង្កើត តាមរយៈព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣។

ការកែសម្រួលក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនាពេលនេះ គឺធ្វើឡើងដោយប្រញាប់ប្រញាល់ ដូចជាមិនមានផែនការទុកជាមុន។ បញ្ជីរាយនាមសមាសភាពរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥ ដែលដាក់ជូនអង្គសភាអនុម័ត គឺមិនមានការបំបែកក្រសួងនេះទេ ពោលគឺមានតែការកែសម្រួលរដ្ឋលេខាធិដ្ឋានមុខងារសាធារណៈ ទៅជាក្រសួងមុខងារសាធារណៈ តែក្រោយពីរាជរដ្ឋាភិបាលថ្មីនេះបានចាប់ផ្តើមដំណើការមិនទាន់បាន រយៈពេល

[6] លិខិតរាជរដ្ឋាភិបាលលេខ ២៦.សជណ.កបច សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ។

មួយឆមាសនៃឆ្នាំទីមួយផង រាជរដ្ឋាភិបាលក៏បានសម្រេចបំបែកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយដាក់ជូនអង្គសភាអនុម័តជាថ្មីម្តងទៀត ទៅជាពីរក្រសួង ទី១ ឧស្សាហកម្ម និងសិប្បកម្ម និងទី២ ក្រសួងរ៉ែ និងថាមពល ដែលមានរចនាសម្ព័ន្ធដឹកនាំដាច់ពីគ្នា។ **លោក ចម ប្រសិទ្ធ** និងរដ្ឋលេខាធិការចំនួន០៦រូប ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ចំណែកឯ ក្រសួងរ៉ែ និងថាមពល ស្ថិតក្រោមការដឹកនាំរបស់ **លោក ស៊ុយ សែម** ព្រមទាំងរដ្ឋលេខាធិការចំនួន០៦រូប ដោយលោកត្រូវបានផ្លាស់ប្តូរតួនាទីពីតំណាងរាស្ត្រ ឬសមាជិករដ្ឋសភានៃមណ្ឌលខេត្តពោធិសាត់មកពីគណបក្សប្រជាជនកម្ពុជា។ ជំនួសឲ្យតំណាងរាស្ត្រ ដែលភរិយាមានជម្លោះដីធ្លីជាមួយប្រជាពលរដ្ឋនោះ **លោក សារី កោសៈ** ត្រូវបានរដ្ឋសភាផ្តល់សុពលភាពជាតំណាងរាស្ត្រ ឬសមាជិករដ្ឋសភានៃមណ្ឌលពោធិសាត់វិញ។

ប្រៀបធៀបជាមួយប្រទេសជិតខាង ជាពិសេសប្រទេសនៅក្នុងតំបន់ជាមួយគ្នា រចនាសម្ព័ន្ធដឹកនាំរាជរដ្ឋាភិបាលប្រទេសកម្ពុជានាពេលបច្ចុប្បន្នពិតជាមានចំនួនច្រើន ខណៈដែលចំនួនសមាជិកសភានានីតិកាលទី៥ មិនសមាមាត្រនឹងប្រជាសាស្ត្រ ទំហំភូមិសាស្ត្រ និងសេដ្ឋកិច្ច។ រដ្ឋសភាគួរមានសមាជិកចំនួន១៣៣នាក់ សម្រាប់នីតិកាលទី៥នេះ បើប្រៀបធៀបជាមួយកំណើនប្រជាពលរដ្ឋឆ្នាំ២០១៣។[7]

ផលទុនសរុបប្រចាំឆ្នាំ២០១៣របស់ប្រជាពលជនកម្ពុជា គឺ$១,០០៧សម្រាប់ប្រជាជនម្នាក់ៗ ខណៈដែលប្រទេសបង់ក្លាដេសមានចំនួន$៩៥៨។ ទិន្នន័យឆ្នាំ២០១៣បង្ហាញថា បង់ក្លាដេសជាប្រទេសមានប្រជាជនចំនួន ១៥៨.៥១៣.០០០នាក់[8] មានសមាជិកគណៈរដ្ឋមន្ត្រីចំនួនតែ៥៥រូបប៉ុណ្ណោះ។ លើសពីនេះទៀត ឥណ្ឌាជាប្រទេសដែលមានប្រជាជនចំនួន១,២៦៧,៤០២,០០០ និងផលទុនសរុបសម្រាប់ម្នាក់ចំនួន$១,៤៩៩ មានសមាសភាពគណៈរដ្ឋមន្ត្រីត្រឹមតែ៦៦រូបប៉ុណ្ណោះ។ ចំនួនប្រជាជននៃប្រទេសទាំងពីរច្រើនជា ប្រទេសកម្ពុជាដល់ទៅជាងរាប់សិបដង ប៉ុន្តែកម្ពុជាមានសមាជិកគណៈរដ្ឋមន្ត្រីរហូតចំនួន២៤៤នាក់ (ស្ត្រី៤១នាក់)[9] ដោយមិនទាន់រាប់បញ្ចូលអនុរដ្ឋលេខាធិការដែលមានចំនួន២៣៨រូបនោះទេ។

## VI. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥

សម្រាប់នីតិកាលទី៥នេះ រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដែលបានបង្កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៤ បានដាក់ចេញ និងប្រកាសគោលនយោបាយរបស់ខ្លួន ដោយបានបែងចែងជា០៤វិស័យធំៗ រួមមាន៖

1. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
2. ការពង្រឹងរដ្ឋាបាលសាធារណៈវិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ
3. ការអភិវឌ្ឍន៍សេដ្ឋកិច្ច
4. ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។

ក្នុងវិស័យទាំងបួន(០៤)នោះ គេឃើញមានចំណុចតូចៗជាច្រើន ដែលរាជរដ្ឋាភិបាលបានសន្យាថា នឹងសម្រេចឲ្យបាន ឬបន្តអនុវត្តក្នុងនីតិកាលទី៥នេះ ប៉ុន្តែចំណុចការសន្យាទាំងនោះ មិនត្រូវបានកំណត់ជាចំនួនជាក់លាក់នោះទេ ផ្ទុយពីកម្មវិធីនយោបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ ដែលគេសង្កេតឃើញថា ប្រជា

---

[7] ក្នុងឆ្នាំ២០០៨ រដ្ឋសភាសភាជាតិមាន ១២៣អាសនៈនៃប្រជាជនចំនួន១៣,៩៤០,៥១៨ ខណៈដែលឆ្នាំ២០១៣ ប្រជាជន ចំនួន១៥,១៣៥,១៦៩។ http://data.worldbank.org/indicator/SP.POP.TOTL, ចូលមើលនៅថ្ងៃទី៣០ ខែធ្នូ ២០១៤។

[8] *Ibid.*

[9] នាយរដ្ឋមន្ត្រី១រូប ឧបនាយករដ្ឋមន្ត្រី០៩រូប ទេសរដ្ឋមន្ត្រី១៥រូប រដ្ឋមន្ត្រី៣៣រូប (រដ្ឋមន្ត្រីអមគណៈប្រតិភូ ១៤) រដ្ឋលេខាធិការ១៨៧រូប។

ពលរដ្ឋ ជាពិសេសម្ចាស់ឆ្នោតងាយស្រួលក្នុងស្វែងយល់ និងដឹងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះកម្មវិធីនយោបាយនោះបានកំណត់ពីចំនួនគោលនយោបាយច្បាស់លាស់។

ក្នុងកម្មវិធីនយោរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលមានបួន (០៤) វិស័យ គេឃើញមានគោលនយោបាយច្រើនចំណុច ដែលរាជរដ្ឋាភិបាលអាណត្តិទី៥នេះបានសន្យាក្នុងការអនុវត្តន៍ ប៉ុន្តែភាគច្រើននៃគោលនយោបាយទាំងនោះ គ្មានសូចនាករច្បាស់លាស់នោះទេ ពោលគឺគោលនយោបាយទាំងនោះ មិនបានបង្ហាញពីសកម្មភាពការអនុវត្តន៍អ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់នោះទេ។ គោលនយោបាយនីតិកាលទី៥នេះ មិនមានបង្ហាញចំណុចច្បាស់លាស់នោះទេ ខុសពីគោលនយោបាយក្នុងនីតិកាលទី៤ ដែលខុមហ្វ្រែលរកឃើញថា គោលនយោបាយនោះ បានបង្ហាញចំណុចច្បាស់លាស់ ធ្វើឲ្យមានភាពងាយស្រួលក្នុងការវាស់វែង និងផ្តល់ពិន្ទុ។ មានតែគោលនយោបាយ១៦ចំណុចតែប៉ុណ្ណោះ មានសូចនាករច្បាស់លាស់នៅក្នុងវិស័យទី០៣ និងទី០៤តែប៉ុណ្ណោះ។ សម្រាប់គោលនយោបាយដែលគ្មានសូចនាករច្បាស់លាស់៣៣ចំណុច ខុមហ្វ្រែលបានធ្វើការប្រមូលទិន្នន័យ និងព័ត៌មានទាំងនោះ ដើម្បីឲ្យប្រជាពលរដ្ឋជាម្ចាស់ឆ្នោតបោះឆ្នោតផ្តល់ពិន្ទុ។ សេចក្តីសង្ខេបនៃគោលនយោ បាយនីតិកាលទី៥ សូមមើលឧបសម្ព័ន្ធ០១។

## VII. ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយសម្រាប់ឆ្នាំទី១

សម្រាប់ឆ្នាំទី១នៃនីតិកាលទី៥ រដ្ឋសភាគណបក្សប្រជាជនកម្ពុជាបានអនុម័តថវិកាជាតិ ចំនួន៣៤០០ ពាន់លានដុល្លារ ដើម្បីឲ្យរាជរដ្ឋាភិបាលអនុវត្តគោលនយោបាយរបស់ខ្លួន ខណៈពេលដែលបេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ មិនទាន់ចូលក្នុងកាន់តំណែងជាតំណាងរាស្ត្រក្នុងរដ្ឋសភា។ ថវិកាជាតិប្រមាណ៤៦៨ លានដុល្លារសហរដ្ឋអាមេរិក ដាក់បញ្ចូលក្នុងការចំណាយលើវិស័យការពារជាតិ និងសន្តិសុខជាតិដែលចំនួនថវិកានេះកើនឡើង៦៨លានដុល្លារសហរដ្ឋអាមេរិក បើប្រៀបធៀបថវិកាបច្ចុប្បន្ន។ វិស័យអប់រំទទួលបានថវិកាប្រហែល៣៣៥លានដុល្លារសហរដ្ឋអាមេរិក ខណៈដែលឆ្នាំ២០១៣ មានត្រឹមតែ២៨០លានដុល្លារសហរដ្ឋអាមេរិក។ ចំណែកថវិកា២២៤លានដុល្លារសហរដ្ឋអាមេរិក ដាក់បញ្ចូលក្នុងការចំណាយលើវិស័យសុខាភិបាល។ ខាងក្រោមនេះខ្ទង់ថវិកាគ្រោងចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០១៤៖

| ល.រ | វិស័យចំណាយថវិកា | គម្រោងថវិកា (ឯកត្តាលានរៀល) | ជាដុល្លាសហរដ្ឋអាមេរិក (1$= 4000៛) | គិតជាភាគរយ(%) |
|---|---|---|---|---|
| ០១ | វិស័យការពារជាតិ និងសន្តិសុខ | 1,872,699.5 | 468174875.00 | 13.8% |
| ០២ | វិស័យរដ្ឋបាលទូទៅ | 1,121,255.5 | 280313875.00 | 8.2% |
| ០៣ | វិស័យសេដ្ឋកិច្ច | 1,211,624.7 | 302906175.00 | 8.9% |
| ០៤ | វិស័យសង្គមកិច្ច | 3,165,870.5 | 791467625.00 | 23.3% |
| ០៥ | ចំណាយមិនទាន់បែងចែក | 6,224,177.0 | 1556044250.00 | 45.8% |
| ០៦ | ចំណាយសរុបរួម | 13,595,627.0 | 3398906750.00 | 100.0% |

### 1. ការបំពេញអនុវត្តគោលនយោបាយមានសូចនាករច្បាស់លាស់

*០១. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយ*

*ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។*[10]

ដោយផ្អែកលើការប្រមើលទុករបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (អង្គការអន្តរជាតិធ្វើការលើម៉ាក្រូ ហិរញ្ញវត្ថុ) ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) ហៅកាត់ថា ADB បានប៉ាន់ប្រមាណថា កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា អាចរក្សាបានត្រឹម៧%នៃផលទុន សរុបក្នុងស្រុក (GDP) សម្រាប់ឆ្នាំ ២០១៤ និងឆ្នាំ២០១៥ នឹងកើនដល់៧,៣% រួមជាមួយអតិផរណាប្រហែល៣,៥%។ កំណើនឆ្នាំ២០១៤ ហាក់ដូចជាយឺតជាងអត្រាកំណើននៃឆ្នាំ២០១៣ ដែលមានរហូតដល់៧,៣% ឬ៧.៤នៃផលទុនសរុបក្នុងស្រុក (GDP)។[11] មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ហ៊ានព្យាករថា កំណើនសេដ្ឋកិច្ចកម្ពុជាអាចហក់ដល់៧,២% នៃGDP សម្រាប់ឆ្នាំ២០១៤នេះ និង៧,៣% សម្រាប់ឆ្នាំ២០១៥។[12] ដូចគ្នានេះដែរ ធនាគារពិភពលោក (World Bank) ក៏បានព្យាករទុកផងដែរថា កំណើនសេដ្ឋកិច្ចកម្ពុជាអាចកើនត្រឹម៧,២% គឺធ្លាក់ចុះបន្តិចជាងឆ្នាំ២០១៣ ដែលមានរហូតដល់កំណើន៧,៤%។[13] លើសពីនេះទៅទៀត នៅខែតុលាឆ្នាំ២០១៤ ធនាគារពិភពលោក បានព្យាករថា កម្ពុជាអាចនឹងមានកំណើនសេដ្ឋកិច្ចរហូតដល់៧.៥ភាគរយសម្រាប់ឆ្នាំ២០១៥។ ការប៉ាន់ប្រមាណរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗទាំងបីខាងលើនេះ គឺវាស៊ីសង្វាក់គ្នា និងស្ទើរតែដូចគ្នាតែម្តង។ ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចជាងឆ្នាំមុននេះ ដោយសារបញ្ហាអស្ថេរភាពនយោបាយ និងការជាប់គាំងនយោបាយកើតឡើង នៅក្រោយថ្ងៃបោះឆ្នោតនាខែកក្កដា ឆ្នាំ២០១៣ ដែលបានអូសបន្លាយអស់រយៈពេលជិតមួយឆ្នាំកន្លងមកនេះ។ ការអូសបន្លាយការជាប់គាំងផ្នែកនយោបាយនេះ ក្នុងរយៈពេលជិតមួយឆ្នាំនេះ បានធ្វើឲ្យវិនិយោគិនជាតិ និងអន្តរជាតិ មានចិត្តរារែក អល់អែក បាត់បង់ទំនុកចិត្ត ស្ទាក់ស្ទើរ និងព្រួយបារម្ភយ៉ាងខ្លាំងលើគម្រោងផែនការវិនិយោគនៅកម្ពុជា។

បើទោះជាកំណើនសេដ្ឋកិច្ចកម្ពុជា អាចរក្សាបានកំរិតវិជ្ជមានក្នុងកំរិត រវាង៧ភាគរយបែបនេះក្តី ស្ថានភាពពិតនៃសង្គមកម្ពុជាពិតប្រាកដ មិនទាន់ឆ្លុះបញ្ចាំងពីផលវិជ្ជមាននៃកំណើនសេដ្ឋកិច្ច និងការធ្លាក់ចុះអត្រាភាពក្រីក្រនៅឡើយទេ។ មានបញ្ហាជាច្រើនដែលប្រឈមក្នុងសង្គមកម្ពុជា ក្នុងពេលដំណាលគ្នានៃកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ។ ការបែងចែកកំណើនផលចំណេញ ដែលបានមកពីកំណើនសេដ្ឋកិច្ច គឺមិនត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌប្រកបដោយសមធម៌ ឥម្ពាភាពនៅឡើយទេ ដោយហេតុថា គម្លាតខ្ពស់រវាងអ្នកមាន និងអ្នកក្រនៅក្នុងសង្គមកម្ពុជា គឺនៅជាបញ្ហាចោទនៅឡើយ ឬអាចនិយាយបានថា គម្លាតនេះអាចកាន់តែរីកធំឡើងៗជាងមុនទៅទៀត។

ដោយផ្អែកលើការរកឃើញរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗខាងលើ យើងអាចសន្និដ្ឋានបានថា ការរក្សាកំណើនសេដ្ឋកិច្ចឲ្យនៅត្រឹម រវាង៧ភាគរយក្នុងមួយឆ្នាំ គឺរាជរដ្ឋាភិបាលកម្ពុជាប្រាកដជាអាចសម្រេចបាន។

---

[10] "*Political Platforms of the Royal Government of Cambodia of the Fifth Legislature of the National Assembly*", Royal Government of Cambodia, (Sept 2013), at 15.

[11] Asian Development Outlook 2014: Fiscal Policy for Inclusive Growth, Asian Development Bank (ADB), (2014), at 197; The World Bank, "Coping with the Domestic Pressures and Gaining from a Strengthened Global Economy", Cambodia Economy Update, *Selective Issue*, April 2014 at 1; ADB.2014.; Asia Economic Outlook, "Cambodia, China, Japan and Singapore", *Deloitte University Press*, (March 2014) at 2; available at http://d2mtr37y39tpbu.cloudfront.net/wp-content/uploads/2014/02/APAC_March14_FINAL.pdf; World Bank Press Release, "*Cambodia's Economy Remains Strong at 7.4% in 2013*", April 07, 2014, available at http://www.worldbank.org/en/news/press-release/2014/04/07/cambodia-s-economy-remains-strong-in-2013, cited on 19 Sept 2014; Simon Lewis, "*IMF Says Cambodia's Economic 'Takeoff' Not Yet Sustainable*", The Cambodia Daily, 18 April 2013, at A1 or available at http://www.cambodiadaily.com/archives/imf-says-cambodias-economic-takeoff-not-yet-sustainable-18880/

[12] International Monetary Fund, "*World Economic Outlook*", (April 2014) at 184; or available at file:///D:/Cambodian%20Govts/Economy/IMF....pdf, cited on 19 September 2014; *See id*, World Bank, at 2.

[13] The World Bank, East Asia and the Pacific, "*Global Economic Prospects*", (June 2014) at 42 and available at http://www.worldbank.org/content/dam/Worldbank/GEP/GEP2014b/GEP2014b_EAP.pdf.

## ០២. *សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។*[14]

កម្ពុជាជាប្រទេសក្រីក្រមួយ ក្នុងចំណោមប្រទេសក្រីក្រជាច្រើនក្នុងពិភពលោក ដែលបានសម្រេចគោលដៅអភិវឌ្ឍន៍សម្រាប់សហស្សវត្សរបស់អង្គការសហប្រជាជាតិលើចំណុចទី១ ៤ ៥ និងទី៦ ហើយអត្រានៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ក៏បានធ្លាក់ចុះមកនៅតិចជាង២០ភាគរយផងដែរ ក្នុងឆ្នាំ២០១៤នេះ។ ការរំកិលធ្លាក់ចុះអត្រាភាពក្រីក្រនេះ ដោយសារសន្ទុះនៃកំណើនសេដ្ឋកិច្ច ដែលកម្ពុជាអាចរក្សាបានត្រឹមរវាង៧ភាគរយក្នុងមួយឆ្នាំ។ អត្រានៃភាពក្រីនៅកម្ពុជាបានធ្លាក់ចុះគួរឲ្យកត់សំគាល់ គឺពី៤៧,៨ភាគរយ ក្នុងឆ្នាំ២០០៧ មកនៅត្រឹម១៨,៦ភាគរយ ក្នុងឆ្នាំ២០១២។[15]

បើយោងតាមការចេញផ្សាយរបស់ធនាគារពិភពលោក (World Bank) នៅចុងឆ្នាំ២០១៣ អត្រាប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនៅកម្ពុជាមាន២០,៥ ភាគរយ ក្នុងឆ្នាំ២០១១ មានន័យថា ចំនួន២.៨ លាននាក់នៃប្រជាជនសរុបកំពុងស្ថិតនៅលើបន្ទាត់នៃភាពក្រីក្រ។ ស្ថាប័នខ្លះបានរកឃើញថា ប្រជាជនកម្ពុជាប្រមាណ៤៩,៥ភាគរយកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បើគិតតាមអត្រាប្រាក់ចំណូលប្រចាំថ្ងៃចំនួន២ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយថ្ងៃ (2$/day of PPP)។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានគណនានិយមន័យប្រជាជន ដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ គឺសំដៅទៅលើក្រុមប្រជាជន ដែលអាចរកប្រាក់ចំណូលបានតិចជាង១,២៥ដុល្លារអាមេរិកក្នុងមួយថ្ងៃ (1.25 UDS/Day)។[16] ផ្អែកតាមការគណនានេះ អត្រាប្រជាជនស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនៅកម្ពុជា គឺមានតិចជាង២០ភាគរយ។ យោងតាមរបាយការណ៍ ធនាគារពិភពលោកនៅក្នុងឆ្នាំ២០១២ កម្ពុជាមានអត្រាប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ ប្រមាណ១៨,៦ភាគរយ។ បើវិភាគទៅលើទិន្នន័យរបស់ស្ថាប័ននេះដដែល យើងឃើញថា នៅក្នុងរវាងឆ្នាំ២០០៩ និង២០១០ កម្ពុជាអាចកាត់បន្ថយភាព ក្រីក្របាន ១,៨ ភាគរយ (រយៈពេល មួយឆ្នាំ) ដោយក្នុងឆ្នាំ២០០៩ អត្រាភាពក្រីក្រនៅកម្ពុជាគឺ មានចំនួន ២៣,៩ ភាគរយ និងនៅឆ្នាំ២០១០ មាន២២,១ភាគរយ។ នៅរវាងឆ្នាំ២០១០ និងឆ្នាំ២០១១ កម្ពុជាអាចកាត់បន្ថយភាពក្រីក្របាន១,៦ភាគរយ (រយៈពេលមួយឆ្នាំ) ដោយនៅឆ្នាំ២០១០ អត្រាប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ គឺ២២,១ភាគរយ និងឆ្នាំ២០១១ មាន២០,៥ភាគរយ។ នៅរវាងឆ្នាំ២០១១ និងឆ្នាំ២០១២ កម្ពុជាអាចកាត់បន្ថយភាពក្រីក្របាន១,៩ភាគរយ (រយៈពេលមួយឆ្នាំ) ដោយនៅឆ្នាំ២០១២ អត្រាប្រជាជនស្ថិតនៅក្រោមភាពក្រីក្រមានប្រមាណ១៨,៦ភាគរយ។ ដូច្នេះជាមធ្យមភាគក្នុងរយៈពេលបួនឆ្នាំនេះ គឺស្ថិតក្នុងរវាង១,៧ ទៅជិត១,៨ភាគរយក្នុងមួយឆ្នាំ។

យោងទៅតាមកំណត់ត្រានៃភាពជោគជ័យរបស់រដ្ឋាភិបាល ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្រក្នុងរវាងប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានការកាត់បន្ថយភាពក្រីក្របានក្នុងអត្រា១%ក្នុងមួយឆ្នាំ ប៉ុន្តែលក្ខខណ្ឌជីវភាព និងការរស់នៅរបស់ប្រជាជនខ្មែរ នៅមិនទាន់ឆ្លើយតាមទៅនឹងការធ្លាក់ចុះនៃអត្រានៃភាពក្រីក្រនេះនៅឡើយទេ។

## ០៣. *បន្តខិតខំសម្រេចនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។*[17]

---

[14] *Supra* note 10, at 17.

[15] *Cambodia: Country Poverty Analysis 2014*, Asian Development Bank (ADB), 2014, at 4-5.

[16] *Id.*, at 5. See also *Basic Statistics 2014,* Economics and Research Department, The Asian Development Bank (ADB), April 2014, at 2-6.

[17] *Supra* note 10, at 21.

ប្រទេសកម្ពុជា មានសក្តានុពលខ្ពស់ក្នុងវិស័យកសិកម្ម។ កត្តាសីតុណ្ហភាព និងដីសម្រាប់បង្កបង្កើនផល គឺជាសក្តានុពលដ៏សំខាន់ ដែលជាអំណោយទានដ៏ល្អបំផុតសម្រាប់ការផលិតផលិតផលនៃដំណាំកសិកម្ម។ ដីសណ្តរនៅតាមបណ្តោយដងទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប គឺជាដីដែលមានជីវជាតិខ្ពស់ និងមានសក្តានុពលខ្លាំងសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា។ ដំណាំស្រូវ គឺជាដំណាំកសិផលដែលសំខាន់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែប្រទេសកម្ពុជាមិនទាន់ប្រើប្រាស់ដី ដែលពោរពេញដោយសក្តានុពលផ្នែកកសិកម្មនេះឲ្យអស់លទ្ធភាពនៅឡើយទេ។

យោងតាមទិន្នន័យទទួលបានពី របាយការណ៍របស់សម្ព័ន្ធអ្នកនាំចេញអង្ករកម្ពុជា នៅក្នុងឆ្នាំ២០១៣ កម្ពុជាបាននាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិបានចំនួន៣៧៨.៨៥៦តោន កើនឡើងជិត២០ម៉ឺនតោន បើធៀបនឹងចំនួននៃការនាំចេញក្នុងឆ្នាំ២០១២។ ក្នុងរយៈពេល១២ខែនៃឆ្នាំ២០១៤ ប្រទេសកម្ពុជាបាននាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិបានចំនួន៣៨៧.១០០តោន គឺកើនឡើង២ភាគរយ បើធៀបនឹងទិន្នន័យកំណើនឆ្នាំ២០១៣។[18] សន្ទស្សន៍នៃការនាំចេញអង្កររបស់កម្ពុជានៅឆ្នាំ២០១៤នេះ ហាក់ដូចជាមិនសូវល្អប៉ុន្មានឡើយ បើធៀបនឹងសន្ទស្សន៍នៃឆ្នាំ២០១៣។

កម្ពុជាបានបរាជ័យរួចទៅហើយ លើគោលដៅនាំចេញអង្ករឲ្យបានកន្លះលានតោន (៥០០.០០០តោន) សម្រាប់ឆ្នាំ២០១៣។[19] អ្វីដែលកាន់តែច្បាស់ជាងនេះទៅទៀតនោះ គឺលោកនាយករដ្ឋមន្ត្រី ***ហ៊ុន សែន*** បានទទួលស្គាល់នូវបរាជ័យនេះរួចទៅហើយថា ទិសដៅនាំចេញអង្កររបស់កម្ពុជាឲ្យបាន១លានតោន ក្នុងឆ្នាំ២០១៥ គឺប្រហែលជាមិនអាចទៅរួចឡើយ។[20] មានកត្តាជាច្រើនដែលជាឧបសគ្គសម្រាប់កម្ពុជាក្នុងការផលិតទិន្នផលស្រូវ ឬអង្ករសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ។ កត្តាទាំងនោះរួមមាន កម្ពុជាខ្វះខាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតស្រូវអង្ករ ដូចជាប្រព័ន្ធធារាសាស្ត្រ ឬប្រព័ន្ធស្រោចស្រព បច្ចេកទេសនៃការដាំដុះ និងការបង្កបង្កើនផលខ្វះខាតកម្លាំងពលកម្ម ខ្វះខាតឃ្លាំងផ្ទុកស្រូវអង្ករ និងម៉ាស៊ីនរោងចក្រ រោងចក្រកែឆ្នៃ ប្រជាពលរដ្ឋជាច្រើនខ្វះដីធ្វើកសិកម្មជាដើម។ ក្រៅពីនេះ នៅមានបញ្ហាជាច្រើនទៀតដូចជា បញ្ហាតំលៃជីកសិកម្ម តំលៃប្រេងសាំង ទីផ្សារ។ល។ បញ្ហាប្រឈមនេះទាមទារឲ្យរដ្ឋាភិបាលពិនិត្យឡើងវិញនូវបញ្ហាចំបងៗខាងលើ និងព្យាយាមរកដំណោះស្រាយ ក្នុងទិសដៅបង្កើនការនាំចេញអង្ករទៅទីអន្តរជាតិ។

ជារួម ពិតណាស់រាជរដ្ឋាភិបាលកម្ពុជាមិនសម្រេចគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥។

## *០៤. រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រីងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។*[21]

រាជរដ្ឋាភិបាលបានអនុវត្តកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល ដោយសម្រេចលុបឡូត៍នេសាទទាំងអស់សម្រាប់ទុកឲ្យប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សធនធានជលផល។ សម្រាប់ឆ្នាំ២០១៣ ឡូត៍នេសាទចំនួន១៥៨ឡូត៍ (៩៥៣.៨៦១ហិតា) ក្នុងនោះផ្ទៃនេសាទប្រមាណជា៩០% ត្រូវបានផ្ត

[18] See detail at http://oryza.com/cambodia-exports-387100-tons-rice-2014-2-previous-year, accessed on 23 January 2015.

[19] See *Cambodia's rice exports forecast to decrease*, the Vietnamplus, 23 September 2014; available at http://en.vietnamplus.vn/Home/Cambodias-rice-exports-forecast-to-decrease/20149/55693.vnplus . See also Eddie Morton, *Cambodia misses out on rice bid,* The Phnom Penh Post, 19 September 2014, at A1.

[20] Chan Muyhong, *Prime Minister admits 1 million tonne goal is unlikely for rice sector*, The Phnom Penh Post, 19 December 2014.

[21] 21 *Supra* note 10, at 21.

ល់ជូនប្រជាពលរដ្ឋប្រើប្រាស់តាមរយៈសហគមន៍ ចំណែកប្រហែលជា១០%ទៀត ត្រូវបានរក្សាទុកជាកន្លែងអភិរក្សជលផល។ ជាមួយគ្នានោះដែរ សហគមន៍នេសាទទឹកសាបចំនួន៤៧៧សហគមន៍ ត្រូវបានបង្កើត និងចងក្រងឡើង ដោយមួយចំនួនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ និងបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលនៅកម្ពុជា។[22]

កំណែទម្រង់នេសាទដែលមានលក្ខណៈស៊ីជម្រៅ និងមានទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងក្នុងឆ្នាំនីតិកាលទី៤នៃរដ្ឋសភាក្នុងឆ្នាំ២០១២ ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាជាមួយប្រជាពលរដ្ឋកម្ពុជាថាលោកនឹងលុបចោលប្រព័ន្ធឡូត៍នេសាទអាជីវកម្មឯកជនឲ្យអស់ និងរៀបចំដាក់ផ្ទៃទឹកសាបសម្រាប់សហគមន៍ប្រជានេសាទទូទៅជុំវិញបឹងទន្លេសាប ដើម្បីទទួលផលដោយផ្ទាល់ចំនួន៦៥ភាគរយ និងចំនួន៣៥ភាគរយ រក្សាទុកសម្រាប់ជាតំបន់អភិរក្សវិស័យជលផលក្នុងបឹងទន្លេសាប។[23] ជាលទ្ធផល ឡូត៍នេសាទឯកជនទាំង៣៧ឡូត៍ក្នុងបឹងទន្លេសាប និង៨០ឡូត៍នេសាទនៅទូទាំងប្រទេស ត្រូវបានលុបចោលដោយអនុក្រឹត្យក្នុងឆ្នាំ២០១២ ដោយក្នុងទូទាំងប្រទេសមានផ្ទៃទឹកសម្រាប់ប្រជាសមគន៍នេសាទចំនួន៧៦ភាគរយ និង២៤ភាគរយសម្រាប់រក្សាទុកជាផ្ទៃសម្រាប់ធ្វើការអភិរក្សវិស័យជលផល។[24] បច្ចុប្បន្ននេះ គ្មានឡូត៍នេសាទឯកជនណាមួយនៅសេសសល់ដើម្បីប្រកបអាជីវកម្មឡើយ។[25]

ក្នុងគោលនយោបាយនីតិកាលទី៥ រាជរដ្ឋាភិបាលបានសន្យាថា នឹងរក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។ ទោះបីជារាជរដ្ឋាភិបាលបានរំសាយឡូត៍នេសាទទូរទាំងប្រទេស ដើម្បីឲ្យប្រជាពលរដ្ឋធ្វើនេសាទក៏ដោយ ក៏ប៉ុន្តែគេនៅតែឃើញមានបទល្មើសនេសាទ ដែលប្រព្រឹត្តដោយឈ្មួញមានលុយ និងអំណាចកើតមានជារឿយៗដដែលៗ។ ជាក់ស្តែងនៅខែមេសា ដើមឆ្នាំ ២០១៤ ប្រជាពលរដ្ឋរស់នៅភូមិកំព្រីងសង្កាត់ភ្នៀត ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានលើកគ្នាតវ៉ាជំទាស់នឹងសហគមន៍នេសាទនៅសង្កាត់ភ្នៀត ដែលបានយកតំបន់នេសាទនៅផ្នែកខាងក្រៅឡូត៍អភិរក្ស ទៅលក់ឲ្យទៅបុគ្គលម្នាក់កាន់កាប់ផ្តាច់មុខ។[26]

របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៣-២០១៤ និងទិសដៅឆ្នាំ២០១៤-២០១៥ ក៏បានលើកឡើងដែរថា ក្រសួងមិនអាចទប់ស្កាត់បទសល្មើសនេសាទបាន១០០%នៅឡើយទេ។ ការអនុវត្តន៍ច្បាប់ទប់ស្កាត់បទល្មើសនេសាទ ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ គឺនៅមានកំរិតទន់ខ្សោយនៅឡើយ។ ការប្រព្រឹត្តិអំពើពុករលួយ ដែលប្រព្រឹត្តដោយអាជ្ញាធរពាក់ព័ន្ធ គឺនៅតែមានជាហូរហែ ហើយវាបានបង្កឲ្យមានការខឹងសម្បារពីសំណាក់ប្រជានេសាទ។[27]

---

[22] *Report on the Situation of Argriculture, Forestry and Fisheries 2013-2014*, Ministry of Argriculture, Firsheries and Forest, Government of Cambodia, at 68.

[23] *Fishery Reform on the Tonle Sap Lake: risks and opportunities for innovation*, 17(2), June 2013 at 1, Cambodia Development Review, (CDRI).

[24] Sub-decree No. 35 on cancellation of fishing lots in Kandal, Kampong Cham, Prey Veng and Takeo provinces for fish sanctuaries. Phnom Penh: Royal Government of Cambodia; RGC [Royal Government of Cambodia]. (2012b). Sub-decree No. 37 on cancellation of fishing lots in six provinces surrounding Tonle Sap Lake in Battambang, Banteay Meanchey, Siem Reap, Pursat, Kampong Chhnang and Kampong Thom provinces for family-scale fishing activity and fish sanctuaries. Phnom Penh: Royal Government of Cambodia. See also Il Oeur, Mam Kosal, Kim Sour and Blake D. Ratner (2014), *Innovations to strengthen aquatic resource governance on Cambodia's Tonle Sap Lake*, Program Report, Collaborating for Resilience, at 5-6.

[25] *Id.*, Il Oeur, Mam Kosal, Kim Sour and Blake D. Ratner, at 6.

[26] សួន សុផលមុន្នី, *ពលរដ្ឋនៅបន្ទាយមានជ័យតវ៉ាបញ្ហាអាជ្ញាធរផ្តល់ឡូត៍អភិរក្សឲ្យបុគ្គលឯកជន*, វិទ្យុអាស៊ីសេរីភាសាខ្មែរ, ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៤។ អាចស្វែងរកបាននៅ: http://www.rfa.org/khmer/news/social-economy/fishing-conflict-04212014004718.html ។ ចូលមើលនៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៤។

[27] Ben Sokhean, *Angry Villagers Chase Vietnamese Fishermen Down Mekong River*, The Cambodia Daily, October 31, 2014.

សិក្ខាសាលាពិគ្រោះយោបល់ និងវេទិកាពិគ្រោះយោបល់មួយចំនួនលើកឡើងនូវបញ្ហារួម ដែលកំពុងតែប្រឈមនាពេលបច្ចុប្បន្នលើវិស័យនេះ។ *ទី១* តើធ្វើយ៉ាងណាឲ្យវិធានការច្បាប់ ស្តីពីការគ្រប់គ្រង និងប្រមូលផលនេសាទ/ជលផល និងធនធានធម្មជាតិផ្សេងទៀតក្នុងទឹក ដែលបានបង្កើតឡើងអាចឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតឡើង និងបង្កើតលក្ខខណ្ឌសមរម្យសម្រាប់ថ្នាក់មូលដ្ឋាន។ *ទី២* ការពង្រឹងសមត្ថភាពសហគមន៍ប្រជានេសាទ។ តើកំរិតនៃការពង្រឹងសមត្ថភាពអាជ្ញាធរជលផល ភ្នាក់ងារជលផល តំណាងសហគមន៍ប្រជានេសាទមានដល់កំរិតណា? *ទី៣* ការអនុវត្តន៍ច្បាប់ បទបញ្ញត្តិ និងបទបញ្ជា។ តើត្រូវធ្វើយ៉ាងណាដើម្បីឲ្យការអនុវត្តន៍ច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជាដែលពាក់ព័ន្ធនឹងនេសាទ ឲ្យមានប្រសិទ្ធភាព? តើត្រូវស្វែងរកការគាំទ្រពីភាគីពាក់ព័ន្ធណាខ្លះដើម្បីជួយពង្រឹងបញ្ហានៃការអនុវត្តន៍ច្បាប់ និងវិធានការនានាដែលដាក់ចេញដោយរាជ រដ្ឋាភិបាល? *ទី៤* ការធ្វើឲ្យមាននិរន្តរភាពសម្រាប់ប្រជាពលរដ្ឋ ដែលអាស្រ័យផលលើវិស័យជលផល។ តើគួរមានជម្រើសអ្វីខ្លះ ដើម្បីធ្វើឲ្យប្រជាសហគមន៍នេសាទនៅមូលដ្ឋានអាចបង្កើនសេដ្ឋកិច្ច ឬប្រាក់ចំណូលរបស់គាត់ ដែលកើតឡើងពីការងារនេសាទរបស់ពួកគាត់ ឲ្យកើនឡើង និងអភិវឌ្ឍន៍ឡើងជាលំដាប់? ទន្ទឹមគ្នានេះដែរ តើត្រូវមានយុទ្ធសាស្រ្ត និងវិធានការបែបណាដើម្បីធ្វើឲ្យការអាស្រ័យផលរបស់ប្រជាសហគមន៍នេសាទ មាននិរន្តរភាព និងកាត់បន្ថយការប៉ះពាល់ដល់បរិស្ថានក្នុងកំរិតសមរម្យណាមួយ។[28]

ជារួមមក រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវគោលនយោបាយ រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ព្រោះគេឃើញមាន បទល្មើសនេសាទគ្រប់រូបភាព ការកាប់ទន្រ្ទានព្រៃលិចទឹកនៅតំបន់ជុំវិញបឹងទន្លេសាប ភាពកំសោយនៃការអនុវត្តន៍ច្បាប់ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ នៅតែបន្តកើតមានឡើងយ៉ាងអានាធិបតេយ្យ។

*០៥. រក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋាធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។[29]*

ធនធានព្រៃឈើកម្ពុជា បានផ្តល់ផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ប្រមាណជា៨,៤ភាគរយនៃផ.ស.សរបស់កម្ពុជា ក្នុងរវាងពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៨។[30] សម្បត្តិព្រៃឈើកម្ពុជា បានហិនហោច ដោយសារការកាប់បំផ្លាញយ៉ាងអនាធិបតេយ្យជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ។ ភាគរយនៃគម្របព្រៃឈើកាន់តែតិចទៅៗជារៀងរាល់ឆ្នាំ។ នៅឆ្នាំ១៩៦០ កម្ពុជាមានគម្របព្រៃឈើរហូតដល់ទៅ៧៣ភាគរយនៃផ្ទៃដីសរុបទូទាំងប្រទេស។ ទំហំផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើនេះបានធ្លាក់ចុះ និងបាត់បង់មកនៅត្រឹម៥៧,៥៩ ភាគរយនៅឆ្នាំ២០១០ (តាមការអះអាងរបស់រដ្ឋាភិបាល) គឺស្មើ ឬប្រហាក់ប្រហែលនឹង៥ភាគរយក្នុងមួយឆ្នាំជាមធ្យម (FA 2011)។[31] តួលេខនេះ គឺអះអាងបញ្ជាក់ដោយភាគីរដ្ឋាភិបាល។ ប៉ុន្តែបើតាមការរកឃើញរបស់អង្គការអន្តរជាតិ និងក្រុមស្រាវជ្រាវផ្សេងទៀត កម្ពុជាបច្ចុប្បន្ននេះមានផ្ទៃក្រឡាគ្របដណ្តប់ដោយព្រៃឈើពិតប្រាកដមិនដល់៥០ភាគរយផង។ នៅពេលថ្មីៗ សាកលវិទ្យាល័យ *ម៉ារីឡែន* នៃសហរដ្ឋអាមេរិក បានបង្ហាញផែនទីរបស់ខ្លួនជាថ្មីម្តងទៀត អំពីគម្របព្រៃឈើនៅកម្ពុជា។ បើផ្អែកតាមផែនទីនេះ សម្បត្តិព្រៃឈើនៅកម្ពុជា នៅតែបន្តបំផ្លិចបំផ្លាញ

---

[28] *Supra* note 24, Il Oeur, Mam Kosal, Kim Sour and Blake D. Ratner, at 8.
[29] *Supra* note 10, at 21-22.
[30] *Community Forestry for Sustainable Forest Management and Livelihoods: A Case Study of OSOAM Community Forest Users Group*, 18(3), September, 2014 at 1, Cambodia Development Review, (CDRI).
[31] *Ibid.*

យ៉ាងធ្ងន់ធ្ងរនៅក្នុងឆ្នាំ២០១៣ ហើយនៅតែបន្តនៅក្នុងឆ្នាំ២០១៤នេះទៀត ជាពិសេសនៅក្នុងតំបន់ដែលរដ្ឋាភិបាលបានផ្តល់សិទ្ធិទៅឲ្យក្រុមហ៊ុន ក្នុងឋានៈជាដីសម្បទានសេដ្ឋកិច្ចនូវដីដែលជាតំបន់អភិរក្សព្រៃឈើ ដូចជាឧទ្យានជាតិ និងតំបន់សម្រាប់អភិរក្សសត្វព្រៃជាដើម។[32] បើផ្អែកតាមការរកឃើញនេះដដែលបានបង្ហាញថា ការកាប់បំផ្លាញព្រៃឈើខ្លាំងបំផុត និងធ្ងន់ធ្ងរបំផុតនៅកម្ពុជា គឺនៅក្នុងរយៈពេល១២ឆ្នាំចុងក្រោយនេះ (២000-២០១២) ។[33] បើតាមទិន្នន័យនៃការរកឃើញនេះដដែលបង្ហាញទៀតថា គ្រាន់តែក្នុងឆ្នាំ២០១៣តែមួយឆ្នាំគត់ កម្ពុជាបានបាត់បង់ផ្ទៃក្រឡាដែលគ្របដណ្តប់ ដោយព្រៃឈើរហូតដល់២.១២៣ គីឡូម៉ែត្រក្រឡា គឺជិតស្មើនឹង១៧ភាគរយនៃផ្ទៃក្រឡាព្រៃឈើ (១២.៥៩៤ $km^2$) ដែលបានបាត់បង់ក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ។ ផ្ទៃក្រឡាជិតពាក់កណ្តាលនៃផ្ទៃក្រឡា ដែលបានបាត់ក្នុងឆ្នាំ២០១៣ (១.០៩0គីឡូម៉ែត្រក្រឡា) ត្រូវបានគេរកឃើញថា បានបាត់បង់ក្នុងតំបន់ដីព្រៃសម្បទានសេដ្ឋកិច្ចដែលរដ្ឋាភិបាលបានផ្តល់ឲ្យក្រុមហ៊ុនជាដីសម្បទានសេដ្ឋកិច្ច។[34] លើសពីតួលេខនៃការរកឃើញខាងលើ របាយការណ៍រូបភាពផ្កាយរណបណាស្សាដែលចេញកាលពីខែធ្នូ ឆ្នាំ២០១៣ បានបង្ហាញលម្អិត អំពីការបំផ្លាញខ្លាំងក្លាទៅលើព្រៃឈើរបស់ប្រទេសកម្ពុជា ដែលជាការបំផ្លាញដែលបានកើនឡើងយ៉ាងខ្លាំង ក្នុងរយៈកាល៥ឆ្នាំចុងក្រោយនេះ[35]។ ក្នុងឆ្នាំ១៩៧៣ ប្រហែល៧២,១១ភាគរយនៃប្រទេសកម្ពុជា ត្រូវបានគ្របដណ្តប់ដោយព្រៃឈើ។ រូបភាពថ្មីៗបានបង្ហាញថា គម្របព្រៃឈើបច្ចុប្បន្នមានតិចទៅៗគឺចំនួន៤៦,៣៣ភាគរយ ដោយរួមបញ្ចូលទាំងចម្ការកៅស៊ូ។

បើតាមគោលនយោបាយលើវិស័យព្រៃឈើរបស់រដ្ឋាភិបាលកម្ពុជានៃរដ្ឋសភានីតិកាលទី៥នេះ រដ្ឋាភិបាលកម្ពុជាសន្យាថា នឹងបង្កើនចំនួនគម្របព្រៃឈើកម្ពុជាឲ្យបាន៦០ភាគរយ នៅត្រឹមឆ្នាំ២០១៥នេះ។ ជាទិដ្ឋភាពទូទៅ កម្ពុជានៅតែទទួលរងវិនាសកម្មពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារអត្រានៃការកាប់បំផ្លាញព្រៃឈើ និងបទបល្មើសមានទំហំធំធេង ដោយគ្មានការទប់ស្កាត់ និងការអនុវត្តន៍ច្បាប់គ្មានប្រសិទ្ធភាព ប៉ុន្តែការដាំដុះកូនឈើ និងការអភិរក្សព្រៃឈើ ឬការទប់ស្កាត់បទល្មើសកាប់បំផ្លាញព្រៃឈើគ្មានប្រសិទ្ធភាព ឬមានប្រសិទ្ធភាពតិចតួច។ ការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុកមួយចំនួនដែលមានទំនាក់ទំនង ឬខ្សែស្រឡាយជិតស្និទ្ធនឹងថ្នាក់ដឹកនាំកំពូលនៃរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍដីព្រៃទាំងនោះ ត្រូវគេមើលឃើញជារូបភាពទូទៅថា វាជាការបំភាន់ភ្នែកសាធារណជន អំពីការធ្វើអាជីវកម្មលើការកាប់បំផ្លាញព្រៃឈើលក់ ក្នុងរូបភាពជាការសម្បទានសេដ្ឋកិច្ច ប៉ុន្តែរូបភាពជាក់ស្តែង ការផ្តល់ដីសម្បទាននេះ បាន និងកំពុងផ្តល់ផលវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់សម្បត្តិធម្មជាតិនៅកម្ពុជា មានព្រៃឈើ រ៉ែ និងធនធានធម្មជាតិផ្សេងៗច្រើនជាដើម។

កំណើនបទល្មើសព្រៃឈើ និងភាពអនាធិបតេយ្យនៃការកាប់ទន្រ្ទានព្រៃឈើ និងកាប់ឈើធ្វើអាជីវកម្មសម្រាប់លក់ឲ្យឈ្មួញធំៗ ការផ្តល់សិទ្ធិដល់ឈ្មួញធំៗ ដើម្បីប្រមូលទិញឈើយកទៅលក់នៅក្រៅប្រទេស ការផ្តល់ព្រៃសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនធំៗ និងការរុករករ៉ែ និងធ្វើទំនប់វារីអគ្គិសនីជាដើម សុទ្ធតែជាកត្តាសំខាន់ៗដែលជម្រុញឲ្យទំហំនៃគម្របព្រៃឈើនៅកម្ពុជាកាន់តែរួមតូចទៅៗ និងថយចុះជារៀងរាល់ឆ្នាំ ហើយទិសដៅ និងផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដាក់ចេញថា នៅឆ្នាំ២០១៥ កម្ពុជានឹងមានគម្របព្រៃឈើ៦០ភាគរយនៃផ្ទៃដីសរុប ប្រាកដជាមិនអាចសម្រេចបានឡើយ។ ការគ្រប់គ្រងព្រៃឈើនៅកម្ពុជា គឺនៅមានកំរិតខ្សោយ ជាពិសេសការដោះស្រាយវិវាទនៅថ្នាក់ក្រោម និងថ្នាក់ជាតិ មានប្រព័ន្ធតុលាការជាដើម។[36] យោងតាម

---

32 Zsombor Peter, *New Maps Show Heavy Deforestation In 2013*, The Cambodia Daily, Jan 16, 2015.
33 *Id.*, Zsombor Peter, *Loss of Forest in Cambodia Among Worst in the World*, Nov 19, 2013 at A1.
34 *Id.*, at A2.
35 Open Development Cambodia, accessed on 31 December 2014. http://www.opendevelopmentcambodia.net /company-profiles/economic-land-concessions/
36 *Supra* note 30, Cambodia Development Review, at 8.

របាយការណ៍ ស្តីពីលទ្ធផលមួយឆ្នាំនៃការអនុវត្តន៍កំណែទម្រង់ក្នុងរយៈពេល១ឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បទល្មើសព្រៃឈើនៅកម្ពុជាមានចំនួន២.៤០០ករណី ក្នុងនោះបានបញ្ជូនទៅតុលាការចំនួន១.៧៧១ករណី ពិន័យអន្តរការណ៍ចំនួន៥៦៨ករណី និងឃាត់ខ្លួនជនល្មើសបានតែ៧នាក់ប៉ុណ្ណោះ។[37] ឆ្លើយតបនឹងការរកឃើញដោយអ្នកឯកទេស និងអ្នកស្រាវជ្រាវ និងអង្គការអន្តរជាតិនានា ឬអង្គការមិនមែនរដ្ឋាភិបាលជាដើម ភាគីរដ្ឋាភិបាលតែងតែច្រានចោលនូវការរកឃើញទាំងនោះ ហើយបានចោទប្រកាន់ថា ជារបាយការណ៍ ឬការរកឃើញដែលមានចរិតដើម្បីកេងចំណេញផ្នែកនយោបាយ ឬចរិតនយោបាយ ឬថាមិនបានឆ្លុះបញ្ចាំងពីការពិតនៅកម្ពុជា។ នេះជាវប្បធម៌មិនទទួលខុសត្រូវដដែលៗរបស់ភាគីរដ្ឋាភិបាលក្នុងរយៈពេលដែលខ្លួនកាន់អំណាចក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅនេះ។

ជារួម រដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា មិនសម្រេចបាននូវគោលនយោបាយរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋាន ធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។

## ០៦. *បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។*[38]

ចាប់តាំងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១២ រដ្ឋាភិបាលកម្ពុជាបានផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនក្នុងស្រុក និងបរទេសចំនួន១៦៩ក្រុមហ៊ុន ក្នុងទំហំដី១,៦៧លានហិចតា។[39] ដោយឡែក យោងតាមរយៈរបាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូកម្ពុជា ដែលចេញផ្សាយពីដើមឆ្នាំ២០១៤ បានបង្ហាញថា ទំហំ ដីជាង ២,២លានហិចតា ត្រូវបានកាត់ផ្តល់ឲ្យក្រុមហ៊ុនធំៗមួយចំនួនជាដីសម្បទានសេដ្ឋកិច្ច (ELCs)។[40] របាយការណ៍ដដែលនេះបានបញ្ជាក់ទៀតថា បើរាប់គិតចាប់ពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០១៣កន្លងទៅនេះ មានប្រជាជនកម្ពុជាប្រហែលកន្លះលាននាក់ បាន និងកំពុងរងគ្រោះដោយវិបត្តិដីធ្លីនៅកម្ពុជា។ ជាងនេះទៅទៀតក្នុងឆ្នាំ២០១៣ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ បានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនចំនួនប្រមាណ ៤២០.០០០នាក់។[41]

គិតមកត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ទៅក្រុមហ៊ុនឲ្យក្នុងស្រុក និងបរទេសសរុបចំនួន២៨៨ក្រុមហ៊ុន ជាដីសម្បទានសេដ្ឋកិច្ច (ELCs) ក្នុងទំហំដីប្រមាណ២.១១៦.០៦៧,១០ហិចតា[42]។ សម្បទានដីសេដ្ឋកិច្ច ជាមូលហេតុចំបងមួយនៃវិវាទដីធ្លីនៅកម្ពុជា ស្របពេលដែលគេមើលឃើញថាប្រសិទ្ធភាពនៃការដោះស្រាយវិបត្តិដីធ្លីនៅកម្ពុជានាពេលបច្ចុប្បន្ន នៅមានកម្រិតទន់ខ្សោយបំផុត។ ជារឿយៗគេតែងឃើញសកម្មជនទាមទារសិទ្ធិដីធ្លី អ្នករងគ្រោះដោយវិបត្តិដីធ្លី តែងស្រែកទាមទារ និងទ្រហោយំ ឥតឈប់ឈរ ដោយសារតែបញ្ហារបស់ពួកគេមិនត្រូវបានដោះស្រាយ ឬដោះស្រាយដោយប្រាសចាកគោលការណ៍ យុត្តិធម៌។ ការដោះស្រាយបណ្តឹង មិនយុត្តិធម៌ពីសំណាក់ប្រព័ន្ធតុលាការ និងអាជ្ញាធរពាក់ព័ន្ធ ធ្វើឲ្យវិបត្តិដីធ្លីចេះតែ

---

[37] ម៉ៃ ទិត្យថារ៉ា, *ក្រសួងថារយៈពេល១ឆ្នាំ បង្ក្រាបបទល្មើសព្រៃឈើជាងពីរពាន់ករណី និងផ្តន្ទាទោសជនល្មើស៧នាក់* ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤។

[38] *Supra* note 10, at 22.

[39] *Cambodia revokes land licenses from 8 companies*, The Global Post, September 29, 2014, at A1; available at http://www.globalpost.com/dispatch/news/xinhua-news-agency/140929/cambodia-revokes-land-licenses-8companies, cited on 10 October 2014.

[40] "2014 Brings a New Wave of Cambodian Land Conflicts", Licadho-Cambodia *Statement Released*, April 2014. *See also*, http://www.rfa.org/english/news/cambodia/land-04012014170055.html; cited on October 07, 2014.

[41] *Ibid.*

[42] *Supra* note 35.

កើនឡើង និងរីករាលដាល អូសបន្លាយ និងបង្កផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើងៗ។[43] បើតាមរបាយការណ៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (NGO Forum) នៅឆ្នាំ២០១៣ វិវាទដីធ្លីសរុបមានចំនួន៤០៥ករណី ហើយមានតែ៨១ករណីប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយរួចរាល់ក្នុងឆ្នាំ២០១៣ និងនៅមាន៣១១ករណី ឬស្មើនឹង ៧៧ភាគរយផ្សេងទៀតដែលមិនទាន់ត្រូវបានដោះស្រាយ និងកំពុងដោះស្រាយ។ របាយការណ៍ដដែលនេះឲ្យដឹងទៀតថា គ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លីមានចំនួន៦៥.៨៦៧គ្រួសារ ស្មើនឹង ៣០៨.៥៧៥នាក់។ បញ្ហារំលោភបំពានដីធ្លី គឺជាបញ្ហាដ៏ចាប់អារម្មណ៍ជាងគេ ហើយដែលតែងតែមាននៅលើទំព័រកាសែត និងសារព័ត៌មានស្ទើរជារៀងរាល់ថ្ងៃ។

នៅក្នុងរយៈពេលប៉ុន្មានខែនៃឆ្នាំ២០១៤កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានដកហូតដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុន ដែលបានទទួលអាជ្ញាប័ណ្ណអភិវឌ្ឍន៍ក្នុងទំហំសរុបទាំងអស់១១៥.៦៣២ហិចតា។[44] នៅចុងខែកញ្ញា ខែតុលា និងខែវិច្ឆិកា ឆ្នាំ២០១៤នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដកហូតអាជ្ញាប័ណ្ណ ឬរំលាយកិច្ចសន្យាពីក្រុមហ៊ុនមួយចំនួន២៤ក្រុមហ៊ុន ដែលបានទទួលសិទ្ធិកាន់កាប់ និងអភិវឌ្ឍន៍តំបន់ដីសម្បទានសេដ្ឋកិច្ច។ សម្រាប់ខែកញ្ញា ក្រសួងបរិស្ថានបានដកពីចំនួន៨ នៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលមានទំហំផ្ទៃដីសរុបចំនួន១២.៤៥៧ហិចតា[45] និងសម្រាប់ខែតុលា ដកហូត និងលុបចោលអាជ្ញាប័ណ្ណក្រុមហ៊ុនចំនួន៩ ព្រមទាំងកែសម្រួលទំហំដីសម្បទានសាឡើងវិញ គិតជាទំហំដីសរុប៦២.០០០ហិចតា ក្នុងខេត្តមួយចំនួន ដូចជាខេត្តកំពង់ស្ពឺ ព្រះសីហនុ មណ្ឌគិរី បន្ទាយមានជ័យ ព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ បាត់ដំបង និងខេត្តក្រចេះ និងនៅចុងខែវិច្ឆិកានេះ រាជរដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនចំនួន៧ គិតជាទំហំដីសរុប៤១.៦៣២ហិចតា ក្នុងខេត្តមួយចំនួនដូចជា មណ្ឌលគិរី (បីក្រុមហ៊ុន) កំពង់ស្ពឺ ព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ និងបាត់ដំបង ដោយអនុក្រឹត្យលេខ៣០៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា។[46] ការដកហូតអាជ្ញាប័ណ្ណ កែសម្រួល និងកំណត់កិច្ចសន្យាឡើងវិញជាមួយក្រុមហ៊ុនទាំងប៉ុន្មានខាងលើ ដែលបានទទួលសិទ្ធិសម្បទានអភិវឌ្ឍន៍ ធ្វើឡើងក្រោយពីរាជរដ្ឋាភិបាលកម្ពុជាបានតាមដាន និងរកឃើញថា ក្រុមហ៊ុនទាំងនោះមិនបានអនុវត្តកាតព្វកិច្ច ដូចដែលមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍ដីក្នុងតំបន់ទាំងនោះជាច្រើនឆ្នាំ នេះបើយោងតាមការអះអាងរបស់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា។ ជុំវិញបញ្ហាការដកហូតដីសម្បទានពីក្រុមហ៊ុនទាំងនោះ ហើយដាក់ឲ្យនៅក្រោមការត្រួតការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន សង្គមស៊ីវិលបានសាទរចំពោះចំណាត់ការនេះ ប៉ុន្តែបានថ្លែងនូវការព្រួយបារម្ភផងដែរថា វាអាចជារូបភាពបិទបាំង បំភ័នភ្នែកសាធារណជនខាងក្រៅ និងទាញចំណាប់អារម្មណ៍ពីសាធារណជនលើចំណាត់ការរបស់រដ្ឋាភិបាល។

ក្រៅពីការដកហូតអាជ្ញាប័ណ្ណដោយក្រសួងបរិស្ថាន របាយការណ៍ក្រសួងកសិកកម្មក៏បានអះអាងដែរថា តាំងពីក្រោយថ្ងៃបោះឆ្នោតឆ្នាំ២០១៣ មកទល់នឹងដំណាច់ឆ្នាំ២០១៤នេះ ក្រសួងបានដកហូតអាជ្ញាប័ណ្ណដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៨ ដែលមានផ្ទៃក្រឡាប្រមាណ៥០.០០០ហិចតា ក្រោមមូលហេតុថា ក្រុមហ៊ុនទាំងនោះ បានអនុវត្តផ្ទុយ ឬមិនបានគោរពកិច្ចកិច្ចសន្យារវាងក្រុមហ៊ុននឹងរដ្ឋាភិបាល។[47]

---

[43] See also, George Wright, *UN Envoy Critical as Tenure Draws to a Close*, the Cambodia Daily, January 24, 2015, at A3.

[44] Chhay Channyda, *Another 11 land concessions cancelled*, The Phnom Penh Post, 18 October 2014, at A1.

[45] *See* the Global Post, *Supra* note 26; *See also*, Aun Pheap, *Despite ELC Ban, Minister Talks of New Land Deals,* The Cambodia Daily, September 30, 2014 at A1; *See also* Hak Seangly, *Land concessions cancelled*, The Phnom Penh Post, 17 October 2014, at A1.

[46] Ouch Sony, *Ministry Revokes 11 More Commercial Concessions*, The Phnom Penh Post, 18 October 2014, at A1; available at http://phnompenhpost.com/post-weekend/another-11-land-concessions-cancelled. *See also* Sub decree No. 304 dated 28 November 2014.

[47] Aun Pheap, *Government Cancels More Land Concessions*, The Cambodia Daily, 22 January, 2015, at A1.

មានការលើកឡើងខ្លះថា តាមពិតក្រុមហ៊ុនដែលទទួលបានដីព្រៃសម្បទានមួយចំនួន ក្នុងចំណោមក្រុមហ៊ុនទាំងប៉ុន្មានខាងលើបានប្រមូលផលធនធានធម្មជាតិ និងកាប់ព្រៃឈើលក់ឡើងឆ្អែតឆ្អន់ ធ្វើមាន ធ្វើបានរួចទៅហើយ រដ្ឋាភិបាលទើបតែនឹកឃើញ និងដកហូតយកមកទុកជាកម្មសិទ្ធិរបស់រដ្ឋវិញ។ នៅមានក្រុមហ៊ុនមួយចំនួនដែលរដ្ឋាភិបាលបានយោគយល់ ដោយមិនបានដកហូតអាជ្ញាប័ណ្ណ ប៉ុន្តែរាជរដ្ឋាភិបាល បែរជាធ្វើការកែសម្រួល និងកំណត់សាឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចនោះ ជំនួសការផ្តល់ដីសម្បទានបន្ត បើទោះបីជាក្រុមហ៊ុនទាំងនោះបានប្រព្រឹត្តផ្ទុយ និងមិនបានអនុវត្តតាមកិច្ចសន្យារបស់ខ្លួននាពេលកន្លងមកក៏ដោយ។ អ្វីដែលជាការគួរឲ្យកត់សម្គាល់ គឺក្រុមហ៊ុនចំនួន២ ក្នុងចំណោមក្រុមហ៊ុន៣ ដែលស្ម័គ្រចិត្តប្រគល់ដីសម្បទានសេដ្ឋកិច្ចឲ្យរដ្ឋគ្រប់គ្រងវិញ ជាក្រុមហ៊ុនរបស់លោក **ទ្រី ភាព** ជាឧកញ៉ាដ៏ល្បីឈ្មោះខាងជំនួញឈើ។ ក្រុមហ៊ុនទាំងពីរនោះគឺ ទ្រីភាព អ៊ីមផត អិចផត និងក្រុមហ៊ុន DMS THMORDA S.E.Z Co.Ltd ដែលក្រុមហ៊ុនទាំង២នេះទទួលបានដីសម្រាប់វិនិយោគកសិឧស្សាហកម្មនៅតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនគិរី ជាជង្រុកព្រៃឈើនៅកម្ពុជា លើផ្ទៃដីសរុប១៨.៨៥៥ហិកតា។[48]

ជារួម យើងសង្កេតឃើញថា ការបញ្ឈប់ការផ្តល់សម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន គឺរដ្ឋាភិបាលធ្វើសម្រេច ដោយសារក្នុងរយៈពេលមួយឆ្នាំនៃការអនុវត្តន៍គោលនយោបាយនេះ រដ្ឋាភិបាលមិនទាន់ចេញអនុក្រឹត្យណាមួយ ផ្តល់ដីសម្បទានទៅឲ្យក្រុមហ៊ុនណាមួយឡើយ គឺមានតែដកយកមកវិញ។

០៧. *សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាលជិត២លានហិចតា នៅរវាងដើមឆ្នាំ២០១៤ ក្នុងក្របខណ្ឌនៃការអនុវត្ត «នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។*[49]

រាជរដ្ឋាភិបាលកម្ពុជាបានអះអាងថា ខ្លួនបានផ្តល់ប្លង់កម្មសិទ្ធិដីធ្លីបានដល់ប្រជាជន ប្រមាណជាង៤៧០.០០០គ្រួសារ លើផ្ទៃដីសរុប១,៨លានហិចតា។ របាយការណ៍ចុងក្រោយមួយទៀត ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤នេះ ក្នុងសិក្ខាសាលាអន្តរជាតិលើកទី៦ ស្តីពីគោលនយោបាយដីធ្លីទូលំទូលាយ មូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍន៍ទីក្រុង និងជនបទប្រកបដោយចីរភាព នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ លោក **អ៊ឹម ឈុនលឹម** មានប្រសាសន៍ថា មកទល់ពេលនេះ រដ្ឋាភិបាលបានចេញប័ណ្ណកម្មសិទ្ធិជាង៣,៧លានប័ណ្ណជូនប្រជាពលរដ្ឋ ដែលស្មើនឹងប្រមាណ៥០ភាគរយនៃក្បាលដីទូទាំងប្រទេស និងមានផែនការចុះបញ្ជីដីឲ្យបានចំនួន៧០ភាគរយ ក្នុងឆ្នាំ២០១៨ និងឲ្យបាន១០០ភាគរយក្នុងឆ្នាំ២០២៣។[50] លោកបន្តថា រដ្ឋាភិបាលកម្ពុជាប្តេជ្ញាសម្រេចឲ្យបាននូវការចុះបញ្ជីដីធ្លីឲ្យបាន១០០ភាគរយ ក្នុងឆ្នាំ២០២៣ ដោយអះអាងថា វាជាផ្នែកសំខាន់មួយក្នុងកំណែទម្រង់រួមរបស់រដ្ឋាភិបាលកម្ពុជា។

តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបានប្រកាសថា រហូតមកដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤នេះ ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួនសរុប៣,៨លានប័ណ្ណ ត្រូវបានចែកចាយដល់ដៃ

---

[48] ណុល ដារ៉ា *តើការដកដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនមកវិញជាការគ្រប់គ្រាន់ទេ?* វិទ្យុសំឡេងប្រជាធិបតេយ្យ ថ្ងៃទី១៩ មករា ឆ្នាំ២០១៥។ see also *The Cost of Luxury: Cambodia's illegal trade in precious wood with China*, The Global Witness, Friday 6th February 2015.

[49] *Supra* note 10, at 23.

[50] Lay Samean, *Ministry of Land Management and Urban Planning and Construction plans to complete 100% of Land Registration by 2023*, VOD News, 12 November 2014

ប្រជាពលរដ្ឋ។[51] ចំនួននេះបានកើនឡើង៤សែនប័ណ្ណ បើធៀបនឹងចំនួនដែលក្រសួងបានប្រកាស នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ដែលមានចំនួន៣,៤លានប័ណ្ណ។ ចំនួនក្បាលដីសរុប២.៩លាន ត្រូវបានបិទផ្សាយ និងចែកប័ណ្ណបានចំនួន២,៦លានប័ណ្ណដោយរដ្ឋាភិបាល។ តាមរយៈតួលេខនេះ យើងអាចសន្និដ្ឋានថា រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានសម្រេចគោលនយោបាយរបស់ខ្លួនបានប្រហែលជិត៥០ភាគរយ លើការសន្យា ឲ្យសម្រេចបានចុះបញ្ជីក្បាលដីសរុប៦ ទៅ៧លានក្បាលដី។ ដោយឡែក សន្ទុះនៃការដោះស្រាយជម្លោះដីធ្លី ហាក់ដូចជាកើនឡើង ប៉ុន្តែប្រសិទ្ធភាព និងកំរិតនៃការដោះស្រាយជម្លោះនៅមានកំរិត និងមានចរិតនយោបាយច្រើនជាងការដោះស្រាយដោយឆន្ទៈ និងតម្រូវការពិតប្រាកដរបស់ពលរដ្ឋ។

សរុបមក សម្រាប់ការអនុវត្តន៍ឆ្នាំទី១នេះ រាជរដ្ឋាភិបាលសម្រេចបានខ្លះ នូវផែនការចុះបញ្ជីដីសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដី នៅទូទាំងប្រទេស។ យោងតាមសន្ទស្សន៍នៃការកើនឡើងខាងលើ ក្នុងការអនុវត្តន៍ក្នុងឆ្នាំទី១នេះ ប្រសិនបើគ្មានការប្រែប្រួលទេនោះ រាជរដ្ឋាភិបាលនឹងសម្រេចបានតាមផែនការរបស់ខ្លួនក្នុងឆ្នាំ២០១៨ជាមិខាន។

### *០៨. កសាងគោលនយោបានជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាជនក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។[52]*

តាមទិន្នន័យជំរឿនប្រជាពលរដ្ឋឆ្នាំ២០០៨ កម្ពុជានឹងមានប្រជាជនប្រមាណ១៨លាននាក់ នៅឆ្នាំ២០៣០ គឺអាចកើនប្រមាណ៤លាននាក់បន្ថែមទៀត ហើយកំណើននេះភាគច្រើនកើនឡើងនៅតាមទីប្រជុំជនធំៗ ដែលមានសក្តានុពលវិស័យសេដ្ឋកិច្ច។ ការធ្វើជំរឿននេះ ក៏បានបង្ហាញផងដែរនូវនិន្នាការនៃការថយចុះទំហំគ្រួសារដែលអាចប៉ាន់ប្រមាណថា រហូតដល់ឆ្នាំ២០៣០កម្ពុជា អាចត្រូវការលំនៅដ្ឋានថ្មីប្រមាណ១,១ លានបន្ថែមទៀតដោយមិនរាប់បញ្ចូលលំនៅដ្ឋានបច្ចុប្បន្ន។[53]

នៅក្នុងកិច្ចប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីលំនៅស្ថានត្រូវបានយកមកប្រជុំសម្រេច។ សេចក្តីព្រាងគោលនយោបាយនេះ ត្រូវបានរៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាថ្មីម្តងទៀត ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់បានបញ្ជាក់ នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០១៤ អំពីការអនុម័តគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន។ យោងសេចក្តីជូនដំណឹងរបស់ក្រសួងខាងលើ យើងអាចសន្និដ្ឋានបានថា គោលយោបាយជាតិនេះមានគោលបំណងផ្តល់លទ្ធភាព និងមធ្យោបាយដល់ប្រជាពលរដ្ឋទូទៅនូវការទទួលបានលំនៅដ្ឋាន សមរម្យ ឬការជួសជុសកែលំនៅដ្ឋានដោយយកចិត្តទុកដាក់ ជាពិសេសដល់ក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យម និងទាប និងក្រុមជនងាយរងគ្រោះ ឬរស់នៅបណ្តោះអាសន្នមិនរៀបរយ តាមរយៈការសហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងសប្បុរសជន។

នាពេលបច្ចុប្បន្ន ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលទទួលយកគោលនយោបាយសម្របសម្រួលរបស់រាជរដ្ឋាភិបាលក្នុងផ្លាស់ប្តូរលំនៅដ្ឋានពីទីកន្លែងដែលរាជរដ្ឋាភិបាលមានគម្រោងអភិវឌ្ឍន៍ ទៅតាំងនៅក្នុងតំបន់ផ្សេងនោះមានការលំបាកយ៉ាងខ្លាំង។ ពួកគេទាំងនោះហាក់ដូចជា មិនត្រូវបានគិតគូរពីភាពសមរម្យនៃលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលជាតម្រូវការប្រចាំថ្ងៃនោះទេ។ ជាក់ស្តែង ដូចជាអតីប្រជាជនភូមិសំបុកចាប ដីក្រហម បឹងកក់ និងបុរីកីឡាជាដើម ដែលរដ្ឋាភិបាលកម្ពុជា ហាក់ដូចជាយកពួកគេទៅចាក់ចោលដូចសម្រាមនៅ

---

[51] Notification of the Ministry of Land Management, Urban Planning and Construction, 22 December 2014.
[52] *Supra* note 10, at 24.
[53] May Titthara, *Million-home dilemma* , The Phnom Penh Post, 12 May, 2014.

ជាយក្រុងភ្នំពេញ។ ប្រជាពលរដ្ឋដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅរស់នៅតំបន់ភ្នំបាតកំពុងជួបប្រទះ បង្ហាញលំបាកយ៉ាងខ្លាំងចំពោះការកសាងលំនៅដ្ឋានថ្មីរបស់ពួកគេ។ នៅចុងឆ្នាំ២០១៤នេះ សកម្មជនទាមទារសិទ្ធិលំនៅដ្ឋាន និងសិទ្ធិដីធ្លីដែលជាស្ត្រី និងបុព្វជិតត្រូវបានតុលាការកម្ពុជាកាត់ទោសឲ្យជាប់ពន្ធនាគារ ដោយគ្រាន់តែពួកគេបានប្រើសិទ្ធិ សេរីភាពក្នុងការសំដែងមតិតវ៉ា ដើម្បីឲ្យមានដំណោះស្រាយសមរម្យជូនពួកគេប៉ុណ្ណោះ។ កម្ពុជាបានជាប់ចំណាត់ថ្នាក់មិនល្អ លើការបណ្តេញចេញដោយបង្ខំរបស់រដ្ឋាភិបាល ហើយផ្តល់សំណងមិនសមរម្យទៅនឹងការខូចខាតរបស់ជនរងគ្រោះដោយការបណ្តេញចេញ។

សរុបមក រាជរដ្ឋាភិបាលសម្រេចបានខ្លះការកសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ប៉ុន្តែយើងមិនទាន់ដឹងថា ប្រជាពលរដ្ឋក្រីក្រ ជាពិសេសជនងាយរងគ្រោះពីការបណ្តេញចេញដោយបង្ខំ នឹងទទួលបានផលប្រយោជន៍ពីគោលនយោបាយនោះក្នុងកម្រិតណានោះទេ។

### *០៩. កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី ៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។*

វិស័យដឹកជញ្ជូន គឺជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ។ ក្រោយសម័យសង្គ្រាមរ៉ាំរ៉ៃបានបញ្ចប់ទៅ លទ្ធផលសង្គ្រាស៊ីវិលបន្សល់ទុកឲ្យកម្ពុជានូវរឿងអាណោចអាធ័មឲ្យប្រជាជនកម្ពុជាយ៉ាងច្រើនឥតគណនា។ បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន គឺហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវសម្រាប់វិស័យដឹកជញ្ជូនជាអាទិ។ ជាមួយនឹងជំនួយ និងប្រាក់កម្ចីដ៏ច្រើនលើសលប់ ដែលទទួលបានពីប្រទេសជាមិត្ត ក្នុងនោះមានជប៉ុន ចិន សាធារណរដ្ឋកូរ៉េ ថៃឡង់ដ៏ និងវៀតណាម និងអង្គការអន្តរជាតិរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកជាដើម ផ្លូវជាតិ និងផ្លូវលំជនបទជាច្រើនខ្សែត្រូវបានជួសជុល កែលម្អ និងកសាងសាឡើងវិញ និងបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ទន្ទឹមគ្នានឹងការរីកចំរើននៃវិស័យប្រព័ន្ធដឹកជញ្ជូន ដោយជួសជុល ស្តារស្ថាបនាសាឡើងវិញនេះដែរ បញ្ហាគុណភាពផ្លូវនៅតែជាបញ្ហា ដែលទទួលរងការរិះគន់យ៉ាងខ្លាំងពីប្រជាជនទូទៅដដែល។ អំពើពុករលួយក្នុងវិស័យនេះ ត្រូវបានគេរិះគន់យ៉ាងខ្លាំង មិនមែនត្រឹមតែប្រជាពលរដ្ឋ គណបក្សប្រឆាំង ឬក្រុមអង្គការសង្គមស៊ីវិលប៉ុណ្ណោះទេ សូម្បីតែមន្ត្រីជាន់ខ្ពស់នៃគណបក្សកាន់អំណាចមួយចំនួន ក៏បានរិះគន់ដោយចំហទៅលើអំពើពុករលួយ ដែលបាន និងកំពុងកើតមានឡើង ក្នុងកិច្ចការស្ថាបនា កែលម្អ ជួលជុល និងកសាងផ្លូវជាតិ ឬផ្លូវលំជាដើមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ។[54] លោកបានលើកឡើងថា ការកឹបកេង ឬបន្លំពីគំរោងសាងសង់ផ្លូវជាតិនីមួយៗ គឺមានកំរិតធ្ងន់ធ្ងររហូតដល់៦០ភាគរយ ប្រព្រឹត្តដោយមន្ត្រីពាក់ព័ន្ធនឹងការសាងសង់ ហើយអំពាវនាវឲ្យបញ្ចប់វប្បធម៌ប្រើប្រាស់ថវិការដ្ឋខ្ជះខ្ជាយបែបនេះ។

ក្នុងវិស័យកែលំអផ្លូវលំជនបទ រាជរដ្ឋាភិបាលកំពុងបន្តគម្រោងកែលំអ ជួសជុល និងស្ថាបនាផ្លូវជន (Rural Road Improvement Project-RRIP) ដែលមានរយៈពេលប្រាំឆ្នាំ(ឆ្នាំ២០១១ ដល់ឆ្នាំ២០១៦) និងប្រើប្រាស់ថវិកា៦៧លានដុល្លាសហរដ្ឋអាមេរិក ដែលក្នុងនោះ ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល៧,២៥លានដុល្លារអាមេរិក ជាទឹកប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន៣៥លានដុល្លារ ប្រាក់កម្ចីធនាគារ Keximbank របស់សាធារណរដ្ឋកូរ៉េចំនួន២១លានដុល្លារអាមេរិក និងជំនួយឥតសំណងរបស់មូលនិធិ NDF ៥,៤លានដុល្លារ។

របាយការណ៍វឌ្ឍនភាពការងារប្រចាំខែធ្នូឆ្នាំ២០១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទបានឲ្យដឹងថា បច្ចុប្បន្ន

[54] Phann Ana, *CPP Official Alleges Embezzlement of Roads Budgets*, The Cambodia Daily, July 11, 2014.

ក្រសួងអភិវឌ្ឍន៍ជនបទកំពុងអនុវត្តគម្រោងកែលម្អផ្លូវជនបទ (Rural Road Improvement Project-RRIP) ក្នុងខេត្តចំនួន០៨ គឺខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិសាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ លើផ្លូវលំជនបទចំនួន២២ខ្សែ ក្នុងប្រវែងសរុបប្រវែង៥៤៧,៧០គ.ម ដោយក្រាលកៅស៊ូប្រភេទពីរជាន់ (DBST) ។ ក្នុងរយៈ១ឆ្នាំនៃឆ្នាំ២០១៤នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានអនុវត្តគម្រោងសាងសង់ផ្លូវ ដែលជាហិរញ្ញប្បទាន រវាងធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកម្ពុជា ហើយសម្រេចបានប្រវែង៥០៥,៧០គីឡូម៉ែត្រ លើប្រវែងសរុបក្នុងឆ្នាំ២០១៤ និងនៅសល់តិចតួចកំពុងអនុវត្តដើម្បីបញ្ចប់ ដោយចំណាយថវិកាអស់ប្រមាណជាង២៤ លានដុល្លារសហរដ្ឋអាមេរិក។[55]

ដូចនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចគោលនយោបាយរបស់ខ្លួនលើសពីអ្វីដែលបានសន្យា ឬការគ្រោងទុកទៅហើយសម្រាប់ឆ្នាំទី១នៃការអនុវត្តន៍គោលនយោបាយក្នុងអាណត្តិទី៥នេះ។

### *១០. រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹងជញ្ជូន ដើម្បីរួមជាប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍ និងពង្រឹងសណ្តាប់ធ្នាប់ចរាចរណ៍ទីក្រុង។[56]*

សម្រាប់វិស័យដឹកជញ្ជូន នៅរាជធានីភ្នំពេញបច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ឲ្យដំណើរការសេវាកម្មដឹកជញ្ជូនសាធារណៈ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ធ្ងន់ធ្ងរ ជាពិសេសពេលព្រឹក និងពេលល្ងាច។ គម្រោងនេះបានដាក់ឲ្យដំណើរការហើយ នៅឆ្នាំ២០១៤នេះ។ រហូតមកដល់ពេលនេះ រដ្ឋាភិបាលកម្ពុជាមិនទាន់មានគោលនយោបាយដាក់ឲ្យដំណើរការមធ្យោបាយដឹកជញ្ជូនសាធារណៈ ភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ខេត្តផ្សេងៗនៅឡើយទេ។ មធ្យោបាយដឹកជញ្ជូនរដ្ឋ គឺនៅមានកំរិតខ្សោយខ្លាំង បើធៀបជាមួយប្រទេសមួយចំនួនធំនៅក្នុងតំបន់អាស៊ាន។ ឆ្នាំ២០១៤ គឺឆ្នាំដំបូងបំផុតដែលរដ្ឋាភិបាល បានចាប់ផ្តើមដាក់ឲ្យដំណើរការមធ្យោបាយសាធារណៈនៅរាជធានីភ្នំពេញ។ សម្រាប់រាជធានីភ្នំពេញ ពីមួយឆ្នាំទៅមួយឆ្នាំ ការកកស្ទះចរាចរណ៍ គឺកាន់តែមានស្ថានភាពធ្ងន់ធ្ងរទៅៗ។ នៅកន្លែងដែលមានការកកស្ទះខ្លាំង រដ្ឋាភិបាលក៏បាន និងកំពុងកសាងស្ពានឆ្លងកាត់ ដើម្បីបញ្ចៀសការកកស្ទះខ្លាំងនេះផងដែរ។ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូនសាធារណៈបានបើកឲ្យដំណើរការហើយ បន្ទាប់ពីដាក់ឲ្យដំណើរការសាកល្បង និងសិក្សាលំអិតនៅដើមឆ្នាំ២០១៤នេះ ដោយមានជំនួយបច្ចេកទេស សម្ភារៈ និងថវិកាពីរដ្ឋាភិបាលនៃប្រទេសជប៉ុន។ គម្រោងនេះដឹកនាំ និងផ្តួចផ្តើមដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន ហៅកាត់ថា (JICA) សហការជាមួយសាលារាជធានីភ្នំពេញ ដើម្បីដំណើរឲ្យមានរថយន្តដឹកជញ្ជូនសាធារណៈ ដើម្បីកាត់បន្ថយការកកស្ទះខ្លាំង ដែលជាបញ្ហាដ៏ចំបងមួយនៅរាជធានីភ្នំពេញ។ បណ្តាញរថយន្តក្រុងសាធារណៈជាច្រើន ត្រូវបានដាក់ពង្រាយដើម្បីដឹកជញ្ជូនសាធារណជននៅតាមបណ្តា មហាវិថីធំៗជាច្រើន។ ប៉ុន្តែឆ្លងតាមរយៈការសង្កេតកន្លងមកនេះ គេសង្កេតឃើញថា ចំនួនប្រជាពលរដ្ឋកម្ពុជាដែលបានផ្លាស់ប្តូរទម្លាប់មកធ្វើដំណើរតាមរថយន្តដឹកជញ្ជូនសាធារណៈ ដែលកំពុងតែដាក់ឲ្យដំណើរការនេះនៅមានកំរិតនៅឡើយទេ។ ពួកគេភាគច្រើនធ្វើដំណើរតាមទោចក្រយាន ឬរថយន្តផ្ទាល់ខ្លួន។

សរុបមក រាជរដ្ឋាភិបាលសម្រេចបានការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសសម្រាប់រាជធានីភ្នំពេញ ព្រោះគេសង្កេតឃើញមានការពង្រាយរថយន្តដឹកជញ្ជូនសាធារណៈបន្ថែមទៀត តាមបណ្តោយផ្លូវសំខាន់នៅក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែគេសង្កេតឃើញថា ចំនួនប្រជាជនដែលកំពុងតែប្រើប្រាស់សេវាកម្មដឹក

---

[55] *របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៤ របស់គម្រោងកែលម្អផ្លូវជនបទ* ក្រសួងអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលកម្ពុជាទំព័រ១។

[56] *Supra* note 10, at 27.

ជញ្ជូនរបស់រដ្ឋនេះនៅមានកំរិតតិចតួចនៅឡើយ។

***១១. ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំ បានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។[57]***

បញ្ហាកង្វះទឹកស្អាតប្រើប្រាស់នៅកម្ពុជា នៅតែជាបញ្ហាកង្វល់ និងប្រឈមនៅឡើយ បើទោះបីជាប្រទេសនេះ ជាប្រទេសសំបូរប្រភពទឹកសាបសម្រាប់ប្រើប្រាស់យ៉ាងណាក្តី។ របាយការណ៍ ស្តីពីសេចក្តីសង្ខេបផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ប្រទេសកម្ពុជាមានប្រជាជនដែលទទួលទឹកស្អាតប្រើប្រាស់មានប្រមាណ៤៧,៦៩ភាគរយ និងទឹកអនាម័យមាន៣១ភាគរយ។[58] យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការ (UNICEF) ចេញផ្សាយនៅដើមឆ្នាំ២០១៤ បានឲ្យដឹងថា ប្រជាជនកម្ពុជាប្រមាណ៦,៣លាននាក់ គឺស្មើនឹង៤២ភាគរយនៃប្រជាជនសរុប១៥លាននាក់ កំពុងខ្វះខាតទឹកស្អាតសម្រាប់ប្រើប្រាស់ ហើយចំនួនប្រជាជន៣,៩លាននាក់ ស្មើនឹង២៦ភាគរយនៃចំនួន (៦,៣ លាននាក់) ប្រជាជនអ្នកខ្វះទឹកស្អាតបរិភោគ និងប្រើប្រាស់គឺជាប្រជាជនក្រីក្រ និងរស់នៅទីជនបទ។[59] កង្វះទឹកស្អាតបរិភោគ បង្កឲ្យមានប្រភេទជំងឺរាគរូស ហើយជំងឺ រាគរូសនេះបានក្លាយជាជំងឺឈានមុខទីពីរនៅកម្ពុជា។ ប្រភេទជំងឺរាគរូសនេះ ជាទូទៅគឺបណ្តាលមកពី ការបរិភោគទឹកដែលខ្វះជាតិរ៉ែ និងវីតាមីន។ ជំងឺប្រភេទនេះ បានបណ្តាលឲ្យកុមារដែលមានអាយុតិចជាង ៥ឆ្នាំនៅកម្ពុជា បាត់បង់ជីវិតជាច្រើន និងបានធ្វើឲ្យកម្ពុជាខាតបង់ទឹកប្រាក់ប្រមាណ ១៤៦លាន ដុល្លារ ជារៀងរាល់ឆ្នាំ។ ជារួម ការប្រើប្រាស់ទឹកស្អាត និងអនាម័យក្នុងចំណោមពលរដ្ឋនៅជនបទនៅមានកម្រិតទាបនៅឡើយ។

ជាសរុប គោលនយោបាយដែលរដ្ឋាភិបាលបានសន្យាថា "ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន ៨៥ភាគរយរស់នៅរាជធានី ខេត្ត និងប្រជាជនចំនួន៦០ភាគរយ ដែលរស់នៅតាមបណ្តាឃុំ នឹងទទួល បានទឹកស្អាត ដែលមានគុណភាពល្អ និងតំលៃសមរម្យ សម្រាប់ប្រើប្រាស់" ទំនងសម្រេចបានខ្លះ។

***១២. ពីឆ្នាំ ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិចំនួន ៨០% នៃចំនួនភូមិទាំងអស់។[60]***

រហូតមកត្រឹមឆ្នាំ២០១៣ មានប្រជាជនប្រមាណត្រឹមតែ ២២,៤៧ភាគរយ នៃប្រជាជនសរុបប៉ុណ្ណោះដែលបានប្រើប្រាស់ថាមពលអគ្គិសនី (៥៤ភាគរយ នៅទីប្រជុំជន និង១៣ភាគរយ នៅតំបន់ជនបទ។[61])ទូរលេខនេះបានបង្ហាញ ប្រជាជនកម្ពុជាភាគច្រើន គឺមិនទាន់ទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ និងជាប់លាប់នៅឡើយទេ។ គម្លាតនៃការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធនៃការតភ្ជាប់បណ្តាញអគ្គិសនីរវាងទីក្រុង និងទីជនបទ គឺនៅមានគម្លាតឆ្ងាយដាច់ពីគ្នានៅឡើយ។ ទោះជាយ៉ាងនេះក្តី គេអាចរំពឹងទុកថា នៅថ្ងៃអនាគតដ៏ខ្លីខាងមុខ ប្រជាជនកម្ពុជា នឹងទទួលបានសេវាផ្គត់ផ្គង់ថាមពលអគ្គសនីបានគ្រប់គ្រាន់ និងអាចកាត់បន្ថយការពឹងផ្អែកលើការផ្គត់ផ្គង់ខាងក្រៅបានច្រើន។

ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) បានប៉ាន់ប្រមាណថា កម្ពុជាមានសក្តានុពលខ្លាំងលើការអភិវឌ្ឍវិស័យថាម

57 *Supra* note 10, at 30.
58 *National Strategy Development Plan Update 2009-2013,* Royal Government of Cambodia, Nov 2009, at vi-vii.
59 Denise Shepherd-Johnson, *World Water Day: 6.3 million Cambodians lack access to safe water*, Press Release, UNICEF, (21 March 2014), at 1
60 *Supra* note 10, at 31.
61 Cambodia Investment Guidebook, CDC, 2013, P. IV-2; http://www.cambodiainvestment.gov.kh/#fragment-3-tab, accessed on 25 November 2014.

ពលវារីអគ្គិសនី ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ កម្ពុជានឹងមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ឬអាចគ្របដណ្ដប់ភាគច្រើនលើផ្ទៃប្រទេស បន្ទាប់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីធំៗមួយចំនួនត្រូវបានបញ្ចប់ និងដាក់ឲ្យដំណើរការជាស្ថាពរ។ កំណើនប្រជាជន និងការអភិវឌ្ឍឧស្សាហកម្មកាន់តែកើនឡើង ធ្វើឲ្យតម្រូវការនៃការផ្គត់ផ្គង់ថាមពលអគ្គសនី ក៏កាន់តែកើនឡើងដែរ។ នាពេលបច្ចុប្បន្ននេះ ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជា នៅមានកម្រិតក្រោមតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ ចំណែកតំលៃវិញ ក៏តំលៃថ្លៃជាងគេ បើធៀបជាមួយប្រទេសនានាក្នុងតំបន់អាស៊ានទាំង១០ប្រទេស និងពិភពលោក។[62] នេះដោយសារតែកម្ពុជាបានពឹងផ្អែកយ៉ាងច្រើនទៅលើការទិញថាមពលអគ្គិសនីពីប្រទេសជិតខាង។ ទោះជាយ៉ាងនេះក្ដី បើផ្អែកលើសក្ដានុពលរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនីនៅថ្ងៃអនាគត គេសង្ឃឹមថា កម្ពុជានឹងអាចមានអគ្គិសនីប្រើប្រាស់ក្នុងតំលៃសមរម្យ និងគ្របដណ្ដប់ទូទាំងប្រទេស។ យោងតាម របាយការណ៍របស់ធនាគារអភិវឌ្ឍអាស៊ី ហៅកាត់ថា (ADB) បានលើកឡើងថាប្រទេសកម្ពុជា បាននាំចូលថាមពលអគ្គិសនីប្រមាណ ១.៥៤៦ ជីកាវ៉ាត់ម៉ោង នៅឆ្នាំ២០១០។[63] ការផ្គត់ផ្គង់អគ្គិសនីសរុប នៅកម្ពុជាក្នុងឆ្នាំ២០១៣ មានចំនួន៤,៣ ពាន់លានគីឡូវ៉ាត់ម៉ោង ក្នុងនោះនាំចូលពីប្រទេសវៀតណាម និងថៃ មានទំហំ៦០ភាគរយនៃការផ្គត់ផ្គង់សរុប។[64] តាមការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍអាស៊ី មកត្រឹមឆ្នាំ២០១៣នេះ កម្ពុជាអាចមានសក្ដានុពលផលិតថាមពលអគ្គិសនី ដែលដើរដោយកំលាំងវារីអគ្គិសនីបានរហូតដល់ទៅ ១០.០០០ មេកាវ៉ាត់ ប៉ុន្តែបច្ចុប្បន្ននេះ កម្ពុជាអាចមានលទ្ធភាពទាញយកផលពីសក្ដានុពលដ៏ធំនេះបានត្រឹមតែ ២២៤,៥៧មេកាវ៉ាត់ប៉ុណ្ណោះ ដើម្បីយកមកប្រើប្រាស់។ បើយោងតាមការសិក្សាស្រាវជ្រាវដដែលនេះ បានឲ្យដឹងដែរថា កម្ពុជានឹងមានកំណើនថាមពលអគ្គិសនី ដែលបានពីគម្រោងទំនប់វារីអគ្គិសនីចំនួន២៨.៩ភាគរយ ក្នុងរវាងឆ្នាំ២០១០ ដល់ឆ្នាំ២០៣៥។ ជាថ្មីម្ដងទៀត លោកនាយករដ្ឋមន្ត្រីកម្ពុជានៅដើមឆ្នាំ២០១៤ នេះបានអះអាងបញ្ជាក់ថា នៅឆ្នាំ២០២០ កម្ពុជានឹងមានបណ្ដាញអគ្គិសនីតភ្ជាប់ទៅគ្រប់ភូមិនៃប្រទេសកម្ពុជាទាំងមូល ហើយឆ្នាំ២០៣០ គ្រប់ផ្ទះទាំងអស់ទូទាំងប្រទេសនឹងមានថាមពលអគ្គិសនីប្រើប្រាស់។[65] ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានអនុម័តឲ្យក្រុមហ៊ុន Alex Corporation Co., Ltd. ធ្វើការវិនិយោគគម្រោងខ្សែបណ្ដាញបញ្ជូនអគ្គសិនី ២៣០គីឡូវ៉ុល ភ្នំពេញ-ព្រះសីហនុ។ ក្នុងកំណត់ហេតុកិច្ចប្រជុំនោះបានឲ្យដឹងថា បច្ចុប្បន្នប្រព័ន្ធបណ្ដាញជាតិបញ្ជូនអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជាបានតភ្ជាប់ខេត្ត-រាជធានីចំនួន១៣។[66]

យោងតាមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ត្រឹមខែមេសា ឆ្នាំ២០១៣ កម្ពុជាមានភូមិចំនួន ១៤.១០៥។ ផ្អែកលើគោលនយោបាយដែលបានសន្យាខាងលើ និងទិន្នន័យនេះ ត្រឹមឆ្នាំ២០១៨ រាជរដ្ឋាភិបាលត្រូវផ្គត់ផ្គង់អគ្គិសនីឲ្យប្រជាពលរដ្ឋប្រើប្រាស់តាមចំនួនប្រមាណ ១១.៣០០ភូមិ។ ជាទិដ្ឋភាពទូទៅ គេឃើញមានតែការផ្គត់ផ្គង់សេវាបណ្ដាញអគ្គិសនីរដ្ឋមានតែនៅតាមបណ្ដាលទីប្រជុំជនធំៗតែប៉ុណ្ណោះ ចំណែកនៅទីជនបទមានភាគរយនៃប្រជាជនតិចបំផុតដែលមានលទ្ធិភាពប្រើប្រាស់អគ្គិសនី និងគ្មានប្រព័ន្ធបណ្ដាញអគ្គិសនីរដ្ឋទៅដល់លំដ្ឋានរបស់ពួកគេឡើយ។ លើសពីនេះទៅទៀត តំលៃអគ្គិសនី

---

62 Karen Ellis, Jodie Keane, *et.al.*, *Alberto Lemma and Lonn Pichdara, Low carbon competitiveness in Cambodia*, The Overseas Development Institute (ODI), (2013), at 9. See also Eddie Morton, *Energy reform needed in emerging markets*, The Phnom Penh Post, 11 December 2014, A1.

63 Aiming Zhou, "Energy Outlook for Asia and the Pacific", Asian Development Bank, 25-29 Nov, 2013. See also Nathan Green, *Cambodia energy demand set to beat regional average*, The Phnom Penh Post, 6 November 2009, at A1.

64 Open Development Cambodia, "Hydro Power"; available link at http://www.opendevelopmentcambodia.net/briefing/hydropower/, cited on 09 October, 2014.

65 *Hun Sen says all villages to have electricity by 2020*, The Khmer Herald, A1.

66 Hor Kimsay, *Power line investment approved*, The Phnom Penh Post, 28 October 2013.

ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជន គឺមានតំលៃខ្ពស់ ធ្វើឲ្យប្រជាជនមួយចំនួនដែលមានប្រាក់ចំណូលតិចតួច ឬមធ្យមមិនអាចមានលទ្ធភាពប្រើប្រាស់សេវាកម្មបណ្តាញអគ្គិសនីរបស់ក្រុមហ៊ុនឯកជនទាំងនោះឡើយ។ អ្វីដែលគេត្រូវបានគេកត់សំគាល់ជាទូទៅគឺ ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីទាំងនោះ នៅតែកំណត់តំលៃទៅតាមអំពើចិត្តរបស់ខ្លួន។ នៅក្នុងរយៈកាលដើមឆ្នាំ២០១៥នេះ គេសង្កេតឃើញការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ទៅលើជីវភាពកម្មករ និងអ្នកជួលផ្ទះនៅទីក្រុងភ្នំពេញ ដែលរងគ្រោះដោយសារការយកតំលៃអគ្គិសនីហួសហេតុ របស់ម្ចាស់ផ្ទះជួល ឬម្ចាស់បន្ទប់ជួល ប៉ុន្តែម្ចាស់ផ្ទះ ឬបន្ទប់ជួលបានចោទប្រកាន់រដ្ឋាភិបាលថា ជាអ្នកកំណត់ថ្លៃខ្ពស់ ពីពួកគេទើបគេតំឡើងថ្លៃខ្លះដើម្បីទប់ទល់នឹងការខាតបង់។ ក្នុងខែមករានេះ រដ្ឋាភិបាលបានសន្យា នឹងតបណ្តាញអគ្គិសនីយ៍ឲ្យកម្មករ ឬអ្នកជួលបន្ទប់ផ្ទាល់តែម្តងក្នុងតំលៃត្រឹមតែ ៦១០រៀល សម្រាប់អ្នកប្រើតិចជាង៥០គីឡូវ៉ាត់ និងតំលៃសេវាកម្មខ្សែមួយចំនួនទៀត។ ការប្រកាសអនុវត្តគោលនយោបាយនេះ ធ្វើឲ្យកម្មករ និងអ្នកជួលផ្ទះឬបន្ទប់ ត្រេកអរ និងសាទរ ប៉ុន្តែបានបង្កើតការថ្នាំងថ្នាក់ដល់ម្ចាស់ផ្ទះឬបន្ទប់ជួល។ ក្រៅពីបញ្ហាខាងលើ នៅមានបញ្ហាមួយទៀតដែលសំខាន់ គឺការបាត់បង់ថាមពលអគ្គិសនីរដ្ឋ ដោយមានការលួចតបណ្តាញ ដោយខុសច្បាប់។ ទឹកប្រាក់មិនក្រោម១០លានដុល្លារអាមរិក ត្រូវបានអគ្គិសនីកម្ពុជារកឃើញថា បានបាត់បង់ដោយការមានការលួចតបណ្តាញខុសច្បាប់។

បេសសកម្មនេះទំនងជាសម្រេចបានក្នុងកំរិតតិចតួចប៉ុណ្ណោះ ព្រោះថាក្រៅពីទំហំនៃការផលិតថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ ការរៀបចំប្រព័ន្ធបណ្តាញចែកចាយ ឬហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ក៏ជាឧបសគ្គចំបងដើម្បីបំពេញគោលនយោបាយនេះផងដែរ។ រាជរដ្ឋាភិបាល សម្រេចបានខ្លះសម្រាប់គោលនយោបាយ ពង្រីកការផ្គត់ផ្គង់ថាមពលអគ្គិសនីពីបណ្តាញជាតិ ដើម្បីចែកចាយឲ្យដល់ភូមិទូទាំងប្រទេសក្នុងកំរិត៨០ភាគរយ នៃភូមិទាំងអស់ក្នុងឆ្នាំ២០១៨ ។

### *១៣. ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ឆ្នាំ២០១៨ កើនដល់ ៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់។*[67]

យោងតាមរបាយការណ៍ ដែលចេញផ្សាយដោយក្រសួងទេសចរណ៍កម្ពុជា កំណើនភ្ញៀវទេសចរបរទេសនៅឆ្នាំ២០១៣ មានចំនួន ១៧,៥ ភាគរយ ស្មើនឹង៤.២១០.១៦៥ នាក់ ហើយបានផ្តល់ប្រាក់ចំណូលឲ្យកម្ពុជាប្រមាណជាង ២.៥០០ លានដុល្លារអាមេរិច ឬស្មើនឹង១៦ភាគរយ នៃផលទុនសរុបក្នុងស្រុករបស់កម្ពុជា (GDP)។[68] វិស័យទេសចរណ៍បានផ្តល់ការងារដល់ប្រជាជនកម្ពុជាដោយផ្ទាល់ ប្រមាណជា៥០ម៉ឺននាក់ និងដោយប្រយោលរាប់សិបម៉ឺននាក់ថែមទៀត។ កំណើនភ្ញៀវទេសចរបរទេសក្នុងឆ្នាំ២០១៣ បានធ្លាក់ចុះជិតពាក់កណ្តាល នៃអត្រាកំណើនភ្ញៀវទេសចរក្នុងឆ្នាំ២០១២ ដែលមានចំនួន២៤,៤ ភាគរយ ឬស្មើនឹងចំនួន៣.៥៨៤.៣០៧នាក់ និងទទួលបានប្រាក់ចំណូលពីវិស័យនេះបានប្រមាណជា ២.២១០លានដុល្លារអាមេរិក។[69] ដោយមានអត្រាកំណើនខ្ពស់នេះហើយ បានជាធ្វើឱ្យរដ្ឋាភិបាលកម្ពុជា កំណត់ការរំពឹងទុកថា ចំនួនភ្ញៀវទេសចរបរទេសនឹងកើនឡើងដល់ ៤,៥ លាននាក់ នៅឆ្នាំ ២០១៥ ហើយអាចនឹងបន្តកើនឡើងឈានដល់ ៦,១ លាននាក់ នៅឆ្នាំ ២០១៨ ខាងមុខនេះ។ ដោយឡែងនៅពេលថ្មីកន្លងមកនេះ លោក **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានអះអាងបញ្ជាក់ជាថ្មីថាចំនួនភ្ញៀវទេសចរបរទេស ដែលនឹងមកទស្សនានៅកម្ពុជាសម្រាប់ឆ្នាំ

---

[67] *Supra* note 10, at 38.

[68] *Tourism Statistic Reports*, the Ministry of Tourism, Kingdom of Cambodia, January 2014. *See also*, *Cambodia receives 2.54 mln foreign tourists in 7 months, up 4.5 pc*, Shanghai Daily, September 12, 2014, available at http://www.shanghaidaily.com/article/article_xinhua.aspx?id=240762, cited on 13 October 2014.

[69] "Tourism Statistic Annual Reports", the Ministry of Tourism, Kingdom of Cambodia, January 2013.

២០១៥ នឹងកើនឡើងដល់៥លាននាក់ ហើយសម្រាប់ឆ្នាំ២០២០ នឹងកើនឡើងដល់៨លាននាក់។[70] កំណើនចំនួនភ្ញៀវទេសចរចូលមកកម្ពុជាគឺជារឿងមួយល្អ ប៉ុន្តែការគ្រប់គ្រងចរិកាដែលបានមកពីការលក់សំបុត្រ ចូលទស្សនាប្រាសាទអង្គរ ឬតំបន់អង្គរ គឺជាបញ្ហានៅតែមានភាពចម្រូងចម្រាស់ដដែល។ បញ្ហាដទៃដែលកម្ពុជាត្រូវយកចិត្តទុកដាក់ផងដែរនោះ គឺការគ្រប់គ្រងតំលៃទំនិញលើទីផ្សារ និងសេវាកម្ម និងភាពយឺតយ៉ាវនៃសេវាកម្មអន្តោរប្រវេសន៍នៅតាមច្រកព្រំដែននីមួយៗ។ ភ្ញៀវទេសចរណ៍បរទេសជាច្រើនតែត្អូញត្អែរពីបញ្ហាទាំងអស់នេះ។ សម្រាប់តម្លៃទំនិញ និងសេវាកម្ម នៅកម្ពុជា គឺពិតជាមានតំលៃខ្ពស់ជាងប្រទេសជិតខាង។ ដោយឡែក ភាពយឺតយ៉ាវ ក្នុងការពិនិត្យលិខិតឆ្លងដែននៅតាមច្រកព្រំដែន គឺជាបញ្ហាគួរត្រូវពិចារណាដោះស្រាយ ដោយសារថា មានជនបរទេសជាច្រើនបានថុញទ្រាន់នឹងការបំពេញការងាររបស់មន្ត្រីអន្តោរប្រវេសន៍ ដែលត្រួតពិនិត្យលិខិតឆ្លងដែនរបស់ពួកគេ ដោយប្រើរយៈពេលយូរ និងត្រូវតំរង់ជួរវែង ប្រើពេលវេលាច្រើនទម្រាំតែបានចូលមកទឹកដីកម្ពុជា។

កំណើនភ្ញៀវទេសចរណ៍បរទេសដែលចូលមកកម្ពុជា ក៏នៅតែបន្តកើនឡើងជារៀងរាល់ខែនៃឆ្នាំ២០១៤នេះ ប៉ុន្តែអត្រាកំណើនហាក់ដូចជាមានការធ្លាក់ចុះច្រើន បើធៀបនឹងទូរលេខនៃកំណើនក្នុងឆ្នាំ២០១៣។ បើតាមរបាយការណ៍ខែវិច្ឆិកា នៃក្រសួងទេសចរណ៍ ចំនួនភ្ញៀវទេសចរបរទេសហាក់មានកំណើនតិចតួច គឺបានតែជាង៦ភាគរយប៉ុណ្ណោះ បើធៀបនឹងរយៈ១១ ខែដូចគ្នា។[71] ទូរលេខចុងក្រោយ ដែលបង្ហាញដោយមន្ត្រីក្រសួងទេសចរណ៍បានបង្ហាញថា ភ្ញៀវទេសចរបរទេសដែលមកទស្សនានៅមកម្ពុជា ពីគ្រប់មធ្យោបាយនៃការធ្វើដំណើរគឺមានចំនួន៤,៥ លាននាក់ក្នុងឆ្នាំ២០១៤។[72]

ជារួម បើវិភាគទៅលើទិន្នន័យនៃអត្រាកំណើន ដែលមានក្នុងរបាយការរបស់ក្រសួងទេសចរណ៍កម្ពុជានៃឆ្នាំនីមួយៗ យើងអាចប៉ាន់ប្រមាណបានថា កម្ពុជាសម្រេចបាននូវគោលនយោបាយលើវិស័យទេសចរណ៍ក្នុងចំនួនភ្ញៀវទេសចរណ៍ ៤,៥លាននាក់ សម្រាប់ឆ្នាំ២០១៥ ខាងមុខនេះបានយ៉ាងស្រួល ឬអាចលើសពីការគ្រោងទុក។ ស្ទើរតែមិនបាច់និយាយដល់ឆ្នាំ២០១៥ ក៏កម្ពុជាអាចនឹងសម្រេចគោល នយោបាយវិស័យទេសចរណ៍បានទៅហើយក្នុងឆ្នាំ២០១៤នេះ។ មួយវិញទៀត សម្រាប់ការកំណត់ទិសដៅឆ្នាំ២០១៨ ដែលកំណត់ថា នឹងមានចំនួនភ្ញៀវទេសចរបរទេសកើនឡើងរហូតដល់ ជាង៦លាននាក់ ក៏កម្ពុជាទំនងជាគ្មានឧបសគ្គឡើយ ក្នុងការសម្រេចទិសដៅបង្កើនកំណើនភ្ញៀវទេសចរបរទេសឲ្យចូលមកកាន់ទឹកដីកម្ពុជា។

## *១៤. បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ (ឃុំមួយ អនុវិទ្យាល័យមួយ) ដែលនៅមិនទាន់មានអនុវិទ្យាល័យ។*[73]

វិស័យអប់រំនៅកម្ពុជា មានការរីកចំរើនគួរឲ្យចាប់អារម្មណ៍ ក្នុងរយៈពេលជាងពីរទស្សវត្សកន្លង មកនេះ។ តាមរយៈរបាយការណ៍ សន្ទស្សន៍ការអភិវឌ្ឍមនុស្សជាតិ (Human Development Index) របស់អង្គការ UNPD ប្រចាំឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថា កម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់មធ្យម គឺស្ថិតក្នុងលេខរៀងទី១៣៨ ក្នុងចំណោមប្រទេស១៨៧។ ចំណាត់ថ្នាក់នេះ គឺដូចគ្នាទៅនឹងចំណាត់ របស់ប្រទេសឡាវ។[74]ចំនួនសិស្សានុសិស្ស

---

[70] កិច្ចសម្ភាសជាមួយទូរទស្សន៍ CNC

[71] *Id.*, *Tourism Statistic Annual Reports*, November 2014.

[72] George Styllis and Kang Sothear, Growth in Tourist Arrivals Slows to 5-Year Low, The Cambodia Daily, and January 27, 2015.

[73] *Supra* note 10, at 42.

[74] *The Rise of the South: Human Progress in a Diverse World*, Human Development Report 2013, Cambodia, The United Nations Development Programes (UNDP), at 2.

និស្សិត មានការកើនឡើងជារៀងរាល់ឆ្នាំ ប៉ុន្តែបញ្ហាគុណ ភាពអប់រំនៅតែជាបញ្ហាចោទនៅឡើយ។ ឆ្លងតាមលទ្ធផលនៃកំណែទម្រង់ក្នុងឆ្នាំ២០១៤ វិស័យអប់រំនៅថ្នាក់មធ្យមសិក្សា បានបញ្ជាក់ឲ្យឃើញថា គុណភាពអប់រំនៅកម្ពុជា គឺស្ថិតនៅក្នុងកំរិតទន់ខ្សោយខ្លាំង។ ក្រៅពីគុណភាពអប់រំ ហេដ្ឋារចនាសម្ព័ន្ធអប់រំក៏នៅមានកំរិតនៅឡើយ ដែលនេះជាឧបសគ្គដ៏ចំបងរបស់កម្ពុជាក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់អាស៊ាន ដែលនៅសល់រយៈពេលតែមិនដល់មួយឆ្នាំប៉ុណ្ណោះ សហគមន៍អាស៊ាននឹងបើកទ្វារជាផ្លូវការ។

ក្រោយពីការចូលសមាហរណកម្មអន្តរជាតិឆ្នាំ១៩៩៣ កម្ពុជាចាប់ផ្ដើមមានសន្តិភាពជាបណ្ដើរៗ រហូតបញ្ចប់បានសង្គ្រាមស៊ីវិលទាំងស្រុងនៅឆ្នាំ១៩៩៨។ អគ្គារសាលារៀនជាច្រើនពាន់ខ្នងត្រូវបានកសាងឡើងដោយមានការជួយឧបត្ថមពីអង្គការជាតិ អន្តរជាតិ ភ្នាក់ងារអភិវឌ្ឍអន្តរជាតិ ប្រទេសដៃគូអភិវឌ្ឍ ឬជាមិត្តសប្បុរសជន ក្នុងប្រទេស និងក្រៅប្រទេស។ល។

ចំនួនអគ្គារសាលារៀននៅកម្ពុជា បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរ។ ប៉ុន្តែទន្ទឹមគ្នានោះដែរ កង្វះអគ្គារសាលារៀន និងចំនួនគ្រូបន្ទុកថ្នាក់ ប្រាក់បៀវត្សគ្រូបង្រៀននៅតែជាបញ្ហាចោទធ្ងន់ធ្ងរនៅឡើយ។ រហូតមកដល់ដើមឆ្នាំ២០១៤នេះ កម្ពុជាមានអគ្គារសាលារៀនទូទាំងប្រទេសចំនួន ១១,៨៦៥ សាលារៀន ឬស្មើនឹង៨២.៦៩៥ ថ្នាក់រៀន, មានសិស្សានុសិស្សចំនួន ៣.០៣៦.០១៨ នាក់ ក្នុងនោះ១.៤៦៥.៤៩៦ នាក់ជាសិស្សស្រី ឬស្មើ៤៨,២៧% ភាគរយនៃចំនួនសិស្សទូទាំងប្រទេស។ សាលារៀនសម្រាប់ថ្នាក់មតេយ្យមានប្រមាណជា ៣.១៨៤សាលារៀន, អគ្គារសាលាបឋមសិក្សាមាន៦.៩៩៣ សាលារៀន។ នៅកំរិតមធ្យមសិក្សាបឋមភូមិ ឬហៅថាកំរិតអនុវិទ្យាល័យ (ថ្នាក់ទី ៧-៩) ១.២៤៤ សាលារៀន (ទីប្រជុំជន ១៣២សាលារៀន និង ១.១១២ សាលារៀន) មានសិស្សសរុប ៥៣៨.៦២៦នាក់, សិស្សស្រីចំនួន ២៦៧.៧៧៣ នាក់, នៅមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) ៤៤៤ សាលារៀន, មានសិស្សសរុប ២៦៦.២៩៣ នាក់, និង១២៧.០៣៧ នាក់ជាសិស្សស្រី។[75] កម្ពុជានៅខ្វះខាត អគ្គារសាលារៀនច្រើន សម្រាប់បំពេញតម្រូវ ការនៃកំណើនសិស្សានុសិស្សពីមួយឆ្នាំទៅមួយឆ្នាំ។

យោងតាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកដល់ឆ្នាំ២០១៤នេះ កម្ពុជាមាន ១.៦៣៣ ឃុំ/សង្កាត់ ចំណែកចំនួនសាលារៀនសម្រាប់ថ្នាក់អនុវិទ្យាល័យ រហូតមកដល់ឆ្នាំ២០១៤នេះ ទើបតែសាងសង់បានចំនួន ១.២៤៤ សាលារៀនប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការសន្យារបស់រាជរដ្ឋាភិបាល គឺសម្រាប់រយៈពេលមួយអាណត្តិនៃនីតិកាលទី៥។ ដូច្នេះ គោលនយោបាយនេះ យើងអាចវាយតំលៃបាន លុះត្រាតែអាណត្តិនៃរដ្ឋាភិបាលត្រូវបានបញ្ចប់នៅឆ្នាំ២០១៨ ឬយ៉ាងហោចណាស់ នៅមុនការបញ្ចប់អាណត្តិរដ្ឋាភិបាលរយៈពេលមួយឆ្នាំ។ ទោះជាយ៉ាងនេះក្ដី ចំនួន៣៨៩ សាលារៀន នៃថ្នាក់មធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) ជាចំនួនមិនតិចប៉ុន្មានឡើយ ក្នុងរយៈពេល៥ឆ្នាំនៃអាណត្តិទី៥នេះ រាជរដ្ឋាភិបាលប្រហែលជាពិបាកនឹងជំនះលើបេសកម្មនេះបន្តិច។

សរុបកមរាជរដ្ឋាភិបាលសម្រេចបានខ្លះនូវ គោលយោបាយបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ (*ឃុំមួយ អនុវិទ្យាល័យមួយ*) ដែលនៅមិនទាន់មានអនុវិទ្យាល័យ។

---

[75] *Education Statistics & Indicators 2013-2014*, Ministry of Education Youth and Sports, Cambodia, 17 April 2014, at 14; *Education Congress, the Education Youth and Sport Performance*: *in the Academic Year2012-13 and Goals for the Academic Year 2013-14*, Ministry of Education Youth and Sports, Cambodia, 20-21 March 2014, at 36; *see also, Education & Statistics and Indicators* 2013-2014, Ministry of Education Youth and Sport, April 17, 2014, at 1.

## *១៥. រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ច។*[76]

តាមព័ត៌មានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថាមកដល់ពេលនេះ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារក្នុងស្ថិតនៅក្នុងដំណើរការបង្កើត ហើយក្រសួងបានកំណត់ត្រឹមឆ្នាំចុង២០១៥ ដើម្បីឲ្យគោលនយោបាយនេះនឹងត្រូវបានបង្កើតឲ្យរួចរាល់។ ក្រសួងការងារបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាល និងបានទទួលសេចក្តីសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រីដើម្បី បង្កើតគណៈកម្មការអន្តរក្រសួងធ្វើការសិក្សាបង្កើតគោលនយោបាយនេះ ដែលគណៈកម្មការនោះ មានសភាពមកពីក្រសួង អង្គការសមាគម តំណាងសហជីព និយោជកដែលពាក់ព័ន្ធក្នុងវិស័យការងារ ដែលស្ថិតក្រោមច្បាប់ស្តីពីការងារ។

ជារួម ក្នុងការអនុវត្តន៍គោលនយោបាយក្នុងឆ្នាំទី១នេះ រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវការ រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍនៃសង្គម-សេដ្ឋកិច្ច។

## *១៦. ការដាក់ឲ្យដំណើរការរបបប្រាក់សោធន៍និវត្តន៍ សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន ឲ្យទទួលបានរបបប្រាក់សោធន៍ដូចមន្ត្រីរាជការដែរចាប់ពីឆ្នាំ ២០១៥។*[77]

រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តប្រព័ន្ធរបបសន្តិសុខសង្គម ក៏ប៉ុន្តែដំណើរការនេះនៅមានភាពស្មុគស្មាញ និងការផ្តល់សេវានៅមានភាពមិនច្បាស់លាស់។ នៅក្នុងនីតិកាលទី៤ គេឃើញមានការបង្កើតប្រព័ន្ធរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ប៉ុន្តែពុំទាន់ឃើញមានច្បាប់ច្បាស់លាស់នៅឡើយ បើទោះបីជាមានយន្តការអនុវត្តន៍ដោយឡែកតាមក្រសួងនីមួយៗដោយ។

ក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ បានចែងពីរបបសន្តិសុខសង្គមចំនួនពីរប្រភេទគឺ របបធានារ៉ាប់រងហានិភ័យការងារ និងរបបសោធននិវត្តន៍។ ដើម្បីអនុវត្តច្បាប់នេះ អនុក្រិត្យ ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមលេខ១៦អនក្រ-បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ការងារធានារ៉ាប់រងហានិភ័យការងារក៏ត្រូវបានបង្កើត ហើយគេឃើញមានដំណើរការអនុវត្តន៍របបធានារ៉ាប់រងហានិភ័យការងារផងដែរ។ ក្រៅពីរបបទាំងពីរនេះ គេឃើញមានរបបសន្តិសុខសង្គមមួយទៀតដែលត្រូវបានបញ្ញត្តិក្នុងច្បាប់ស្តីពីការងារ គឺរបបថែទាំសុខភាព។ រាជរដ្ឋាភិបាលនីតិកាលទី៥ បានសន្យាក្នុងគោលនយោបាយរបស់ខ្លួនថា នឹងដាក់ឲ្យដំណើរការរបបប្រាក់សោធន៍និវត្តន៍ សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន ឲ្យទទួលបានរបបប្រាក់សោធន៍នីវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥។ ប៉ុន្តែត្រឹមចុងឆ្នាំ២០១៤នេះ រាជរដ្ឋាភិបាលទើបតែបានធ្វើសេចក្តីព្រាងអនុក្រឹត្យនៃរបបថែទាំសុខភាពតែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលមិនទាន់រៀបចំឲ្យមានដំណើរការរបបប្រាក់សោធន៍និវត្តន៍ សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន។ ប៉ុន្តែលោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជាបានឲ្យដឹងថា រាជរដ្ឋាភិបាលទំនងជា អាចសម្រេចបាននូវគោលនយោបាយរបបសោធន៍និវត្តន៍សម្រាប់កម្មករនិយោជិតធ្វើការក្នុងវិស័យឯកជន ក្នុងឆ្នាំ២០១៥នេះ ព្រោះនៅឆ្នាំ២០១៤នេះ ក្រសួងការងារបានចាប់ផ្តើមគិតគូរគោលការណ៍នៃ របបប្រាក់សោធន៍និវត្តន៍សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនជាបណ្តើរៗហើយដែរ។

ជាសរុប រាជរដ្ឋាភិបាលមិនសម្រេចនូវការសន្យា ការដាក់ឲ្យដំណើរការរបបប្រាក់សោធន៍និវត្តន៍ សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន ឲ្យទទួលបានរបបប្រាក់សោធន៍ដូចមន្ត្រីរាជការដែរចាប់ពីឆ្នាំ ២០១៥ នោះទេ។

---

[76] *Supra* note 10, at 46.
[77] *Ibid.*

## 2. ការផ្ដល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់ (ករណីសិក្សា៖ រាជធានីភ្នំពេញ និងខេត្តសៀមរាប)

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅខេត្តសៀមរាប និងរាជធានីភ្នំពេញ ប្រមាណ ២៥០នាក់ បានវាយតម្លៃការបំពេញ/អនុវត្តន៍សម្រាប់រយៈពេលជាងមួយឆ្នាំ (ខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែធ្នូ ឆ្នាំ២០១៤) នៃការបំពេញ ឬអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដោយធ្វើការផ្ដល់ពិន្ទុលើគោលនយោបាយមិនមានសូចនាករច្បាស់លាស់ចំនួន៣៣ ចំណុច នៃវិស័យទាំងបួន។ លទ្ធផលនៃការផ្ដល់ពិន្ទុមានដូចខាងក្រោម ៖

### វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

| កម្រិតនៃការពេញចិត្ត | ភ្នំពេញ | | សៀមរាប | |
|---|---|---|---|---|
| | លើកទី១[78] | លើកទី២[79] | លើកទី១ | លើកទី២ |
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 60.4% | 74.6% | 46.3% | 64.2% |
| 2.ពេញចិត្តខ្លះ | 22.5% | 18.8% | 29.9% | 23.6% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល | 8.3% | 5.1% | 17.7% | 10.8% |
| 4.ពេញចិត្តច្រើន | 4.6% | 00% | 4.3% | 1.4% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 4.2% | 1.4% | 1.8% | 00% |

ឆ្លើយតបនឹងការពង្រឹងកិច្ចការពារអធិបតេយ្យជាតិ និងការពារសន្តិសុខជាតិតាមរយៈ គោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ការដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ របស់រាជរដ្ឋាភិបាល ទាំងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប មានការពេញចិត្តតិចតួចចំពោះការអនុវត្តន៍/បំពេញគោលនយោបាយនេះ។ បើគិតពីកម្រិតមធ្យមនៃការពេញចិត្ត សម្រាប់ការផ្ដល់ពិន្ទុលើកទី១ ប្រជារដ្ឋ មានការពេញចិត្តខ្លះ (Mean[80] = 1.7 នៅភ្នំពេញ, Mean = 1.9 នៅខេត្តសៀមរប) និងមានការពេញចិត្តតិចតួច សម្រាប់ផ្ដល់ពិន្ទុលើកទី២ (Mean = 1.3 នៅភ្នំពេញ, Mean =1.5 នៅខេត្តសៀមរាប)។

### វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ

| កម្រិតនៃការពេញចិត្ត | ភ្នំពេញ | | សៀមរាប | |
|---|---|---|---|---|
| | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ |
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 54% | 69.9% | 50.9% | 63.9% |
| 2.ពេញចិត្តខ្លះ | 27.8% | 21% | 24.9% | 19.1% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល | 9.1% | 7.2% | 12.7% | 12.9% |
| 4.ពេញចិត្តច្រើន | 5.0% | 0.4% | 10% | 3.4% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 4.1% | 1.4% | 1.5% | 0.7% |

[78] ប្រជពលរដ្ឋផ្ដល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[79] ប្រជពលរដ្ឋផ្ដល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[80] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.6 ដល់ 2.5: ពេញចិត្តខ្លះ, 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល, 3.6 ដល់ 4.5: ពេញចិត្តច្រើន, 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

ទិន្ន័យខាងលើ បង្ហាញថាប្រជាពលរដ្ឋភាគច្រើនមិនពេញចិត្តចំពោះការបំពេញ/អនុវត្តន៍ការ ពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឍការ និងវិសហមជ្ឍការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ។ សម្រាប់ការបោះឆ្នោតទាំងពីរលើកនៅរាជធនីភ្នំពេញ និងខេត្តសៀមរាប មានប្រជាពលរដ្ឋលើកពាក់កណ្តាលផ្តល់ពិន្ទុមិនពេញចិត្តទាល់តែសោះ ពេញចិត្តតិចតួចចំពោះការបំពេញ/នុវត្តន៍គោលនោបាយនេះ។ កម្រិតមធ្យមនៃការពេញចិត្ត សម្រាប់ការផ្តល់ពិន្ទុលើកទី១ គឺ ពេញចិត្តខ្លះ (Mean = 1.8 នៅភ្នំពេញ, Mean = 1.9 នៅខេត្តសៀមរប) ហើយសម្រាប់ការផ្តល់ពិន្ទុលើកទី២ គឺ ពេញចិត្តតិចតួចនៅភ្នំពេញ (Mean = 1.4) និង ពេញចិត្តខ្លះនៅសៀមរាប (Mean =1.6)។

## វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

| កម្រិតនៃការពេញចិត្ត | ភ្នំពេញ | | សៀមរាប | |
|---|---|---|---|---|
| | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ |
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 40.2% | 53.9% | 52.9% | 60.5% |
| 2.ពេញចិត្តខ្លះ | 28.5% | 26.3% | 24.2% | 20.2% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 15.3% | 11.2% | 12.3% | 12.6% |
| 4.ពេញចិត្តច្រើន | 6.6% | 3.1% | 6.8% | 4.4% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 9.5% | 5.6% | 3.9% | 2.4% |

ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ ដើម្បីអភិវឌ្ឍវិស័យជាច្រើនដូចជាកសិកម្ម ឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម ដីធ្លី សំណង់ រ៉ែ ឧស្ម័ន ថាមពល ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ទូរគមនាគមន៍ ទេសចរណ៍ បរិស្ថាន។ យោងតាមទិន្ន័យខាងលើប្រជាពលរដ្ឋទំនង ពេញចិត្តខ្លះ និង និងពេញចិត្តមធ្យម ចំពោះការបំពេញគោលនយោបាយនៃការអភិវឌ្ឍនវិស័យទាំងនោះរបស់ រាជរដ្ឋាភិបាល។ កម្រិតមធ្យមនៃការពេញចិត្ត គឺ ពេញចិត្តខ្លះ (សម្រាប់ការផ្តល់ពិន្ទុលើកទី១ Mean = 2.2 នៅភ្នំពេញ, Mean = 1.8 នៅខេត្តសៀមរប និងសម្រាប់ការផ្តល់ពិន្ទុលើកទី២ គឺ Mean = 1.8 នៅភ្នំពេញ និង Mean =1.7 នៅសៀមរាប)។

## វិស័យទី4៖ ការអភិវឌ្ឍនវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

| កម្រិតនៃការពេញចិត្ត | ភ្នំពេញ | | សៀមរាប | |
|---|---|---|---|---|
| | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ |
| 1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច | 40.2% | 53.9% | 46.2% | 56.8% |
| 2.ពេញចិត្តខ្លះ | 30.5% | 29.6% | 26.1% | 21.8% |
| 3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល | 12.5% | 9.3% | 14.6% | 11.4% |
| 4.ពេញចិត្តច្រើន | 5.1% | 2.7% | 8.1% | 4.9% |
| 5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | 11.6% | 4.5% | 5% | 5.1% |

សម្រាប់វិស័យទី៤នេះវិញ ប្រជាពលរដ្ឋធ្វើការផ្តល់ពិន្ទុហាក់ដូចជាមិខុសឆ្ងាយពីវិស័យទី៣ នោះទេ។ ប្រជាពលរដ្ឋដែលពេញចិត្តខ្លះ និង ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល មានចំនួនច្រើនជាងប្រជាពលរដ្ឋដែលមិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច។ មធ្យមភាគនៃការពេញចិត្តនោះគឺ ពេញចិត្តខ្លះ (សម្រាប់

ការផ្តល់ពិន្ទុលើកទី១ Mean = 2.2 នៅភ្នំពេញ, Mean = 2 នៅសៀមរាប រីឯសម្រាប់ការផ្តល់ពិន្ទុលើកទី២ Mean = 1.7 នៅភ្នំពេញ, Mean = 1.8 នៅសៀមរាប)។

## លទ្ធផលការផ្តល់ពិន្ទុលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងបួនវិស័យ នៅរាជធានីភ្នំពេញ និង ខេត្តសៀមរាប

- **រាជធានីភ្នំពេញ**




- **ខេត្តសៀមរាប**




ប្រជាពលរដ្ឋភាគច្រើនមិនពេញចិត្ត ឬពេញចិត្តតិចតួចលើការអនុវត្តន៍គោលនយោបាយរបស់ រាជរដ្ឋា ភិបាលនីតិកាលទី៥ ក្នុងរយៈពេលមួយ (០១) ឆ្នាំកន្លងមកនេះ ហើយប្រជាពលប្រមាណ មួយ ភាគ បីនៃអ្នកផ្តល់ពិន្ទុ មានការពេញចិត្តខ្លះ ខណៈដែលអ្នកពេញចិត្តច្រើន ឬស្ទើទាំងស្រុងមានចំនួនតិចតួច។ មធ្យមភាគការពេញចិត្តនៃការផ្តល់ផ្តល់ពិន្ទុដោយប្រជាពលរដ្ឋគឺ ពេញចិត្តខ្លះ(រាជធានីភ្នំពេញ Mean = 2 សម្រាប់ការផ្តល់ពិន្ទុទី១ និង Mean = 1.6 សម្រាប់ការផ្តល់ពិន្ទុលើកទី២ ខណៈដែល ខេត្តសៀមរាប Mean = 1.9 សម្រាប់ការផ្តល់ពិន្ទុទី១ និង Mean = 1.6 សម្រាប់ការផ្តល់ពិន្ទុលើកទី២)។

ប្រៀបធៀបការផ្ដល់ពិន្ទុលើកទី១ ការផ្ដល់ពិន្ទុកលើកទី២ធ្លាក់ចុះ គេឃើញថា ការផ្ដល់ពិន្ទុក្នុងកំរិតពេញចិត្តតិចតួច ពេញចិត្តខ្លះ និងពេញចិត្តច្រើន ឬស្មើទាំងស្រុង របស់ប្រជាពរដ្ឋនៃរាជធានី/ខេត្តទាំងពីរ គឺក្រោម៥០ភាគរយ។ ក្រោយពីទទួលបានព័ត៌មានពីវាគ្មិន នូវការបំពេញ/អនុវត្តន៍ គោលនយោបាយរបស់រាជរដ្ឋាភិបាលប្រជាពលរដ្ឋ ប្រែប្រួលការវាយតម្លៃរបស់ខ្លួនកាន់តែអវិជ្ជមានលើការ បំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១។ លទ្ធផលនេះបញ្ជាក់ថា ទោះបីជាមានព័ត៌មានបន្ថែម ក៏ប្រជាពលរដ្ឋ នៅតែមិនពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

**លទ្ធផលជាមធ្យមនៃការពេញចិត្ត និងមិនពេញចិត្តចំពោះការអនុវត្ត/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាលៈ**

ទិន្នន័យខាងក្រោមបង្ហាញពីកំរិតនៃការពេញចិត្ត ឬមិនពេញចិត្តចំពោះវិស័យនីមួយៗ នៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំទី១។ លទ្ធផលនេះជាតម្លៃមធ្យមនៃការផ្ដល់ពិន្ទុលើកទី១ និងទី២នៃ ខេត្តសៀមរាប និងរាជធានីភ្នំពេញ។ តម្លៃនៃការ**ពេញចិត្ត**ក្នុងតារាងខាងក្រោមគឺជាការបូកបញ្ចូល តម្លៃនៃការផ្ដល់ពិន្ទុអញ្ញតទី២(ពេញចិត្តខ្លះ), ទី៣(ពេញចិត្តមធ្យម ឬពាក់កណ្ដាល), ទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្មើទាំងស្រុង ឬទាំងស្រុង)។ ចំណែកឯតម្លៃនៃការ**មិនពេញចិត្ត**គឺជាតម្លៃនៃការផ្ដល់ពិន្ទុអញ្ញតទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)។

| ល.រ | **វិស័យនៃគោលនយោបាយ** | **ពេញចិត្ត**[81] | **មិនពេញចិត្ត** |
|---|---|---|---|
| ០១ | ការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ | 38.6% | 61.4% |
| ០២ | ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌និងការប្រឆាំងអំពើពុករលួយ | 40.3% | 59.7% |
| ០៣ | ការអភិវឌ្ឍន៍សេដ្ឋកិច្ច | 48.1% | 51.9% |
| ០៤ | ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច | 50.7% | 49.3% |
| ០៥ | គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ) | 44.4% | 55.6% |

ក្នុងចំណោមគោលនយោបាយទាំង០៤វិស័យ ការបំពេញ/អនុវត្តគោលនយោបាយការអភិវឌ្ឍនវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចត្រូវបានប្រជាពលរដ្ឋពេញចេញច្រើនជាងគេ (៥០,៧%) ប៉ុន្តែភាគច្រើនអ្នកទាំងនោះបានផ្ដល់ពិន្ទុពេញចិត្តខ្លះតែប៉ុណ្ណោះ ខណៈដែលការផ្ដល់ពិន្ទុមិនពេញចិត្តមាន ប្រជាពលរដ្ឋរហូតដល់ជាង៤៩% ដែលផ្ដល់ពិន្ទុមិនពេញចិត្តទាំងស្រុង ឬពេញចិត្តតិចតួច។ ការអនុវត្តន៍គោលនយោបាយការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈត្រូវបានប្រជាពលរដ្ឋមិនពេញចិត្តច្រើជាងគេ (៦១,៤%) ក្នុងចំណោមគោលនយោបាយទាំងអស់។

បើមើលថវិកាជាតិដែលគ្រោងនឹងចំណាយឆ្នាំ២០១៤ចំនួន៣៤០០លានដុល្លាសហរដ្ឋអាមេរិកវិញ រាជរដ្ឋាភិបាលគ្រោងចំណាយលើវិស័យសង្គមកិច្ច ចំនួន ២៣,៣%, វិស័យការពារជាតិ និងសន្តិសុខ ចំនួន ១៣,៨%, វិស័យសេដ្ឋកិច្ច ចំនួន ៨,៩% និងវិស័យរដ្ឋបាលទូទៅ ចំនួន ៨,២% នៃថវិកាជាតិសរុបដែលរួមបញ្ចូលទាំងថវិកាមិនទាន់បែងចែង។ ហើយការចំណាយលើវិស័យសង្គមកិច្ចគឺច្រើនជាងគេ បើធៀបនឹងវិស័យបីផ្សេងទៀត។ ថវិកាចំណាយលើវិស័យ សង្គមកិច្ចនេះ ភាគច្រើនត្រូវបានយកទៅអនុវត្តគោលនយោបាយវិស័យទី៤ ដោយសារថវិកានេះត្រូវបានបែង ចែកទៅក្រសួងពាក់ព័ន្ធដូចជាៈ ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជន និងកីឡា ក្រសួង

[81]លទ្ធផលមធ្យមនៃការផ្ដល់ពិន្ទុអញ្ញត ២, ៣, ៤, ៥ នៃការផ្ដល់ពិន្ទុលើកទី១ និងទី២ នៃខេត្តសៀមរាម និងរាជធានីភ្នំពេញ

វប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាដើម។

ចំណែកឯវិស័យផ្សេងមួយទៀត ដែលរាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាជាតិមានចំនួន១៣,៨% ច្រើនលំដាប់ទី២ គឺវិស័យការពារជាតិ និងសន្តិសុខ។ ថវិការត្រូវបានផ្តល់ទៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ។ លទ្ធផលនៃការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តន៍គោលនយបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺមិនល្អប្រសើរឡើយ បើធៀបនឹងការចំណាយថវិកាលើវិស័យនេះ។

បើពិនិត្យជារួម សម្រាប់ឆ្នាំទី១ រាជរដ្ឋាភិបាលទី៥ ដែលរដ្ឋសភាបានអនុម័តថវិកា ចំនួន ១៣ ៥៩៥ ៦២៧ លានរៀល (ប្រហែល ៣៤០០ លានដុល្លាសហរដ្ឋអាមេរិក) ដើម្បីអនុវត្តន៍គោលនយោបាយរបស់ខ្លួន មានប្រជាពលរដ្ឋចំនួន ៤៤,៤% ពេញចិត្តចំពោះការបំពេញ/អនុវត្តន៍គោលនយបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលភាគច្រើននៃប្រជាពលរដ្ឋទាំងនោះពេញចិត្តខ្លះតែប៉ុណ្ណោះ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់ ៥៥,៦% មិនពេញចិត្តនឹងការអនុវត្តគោលនយោបាយទាំងនោះក្នុងរយៈពេលមួយឆ្នាំកន្លងមក។

## VIII. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលមួយ (០១)ឆ្នាំដំបូង រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណៈបក្សប្រជាជនកម្ពុជា បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%) នៃ១៦ គោលនយោបាយដែលមានសូនាករច្បាស់លាស់ រួមមានដូចជា៖ កំណើនកំណើនសេដ្ឋកិច្ច ៧%ក្នុងមួយឆ្នាំ, ការកាត់បន្ថយភាពក្រីក្រុងអត្រា ០១%ក្នុងមួយឆ្នាំ, ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច, ការកែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាល ក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង, ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស។

ចំណែកឯគោលនយោបាយចំនួន០៧រួមមាន ការរក្សាផ្ទៃនៃសាទទឹកសាប, ការចុះបញ្ជីដីធ្លី, ការកសាងគោលនយោបាយជាតិស្តីពីសិទ្ធិលំនៅស្ថាន, ប្រជាជនទទួលសេវាទឹកស្អាត, ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ, បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានរាជរដ្ឋាភិបាលអនុវត្តន៍ ឬ/និងសម្រេចបានខ្លះ ខណៈដែលគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងបីនោះមានដូចជា គោលនយោបាយនាំចេញអង្ករឲ្យបាន ១លានតោន នៅឆ្នាំ២០១៥, ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធន៍និវត្តន៍សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន។

ចំណែកការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាលដោយប្រជាពលរដ្ឋនៅខេត្តសៀមរាប និងរាជធានីភ្នំពេញ លើវិស័យទាំង០៤រួមមាន៖ វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ វិស័យការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ច និង វិស័យការអភិវឌ្ឍនវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច បើធៀបការផ្តល់ពិន្ទុលើកទី១ កំរិតពេញចិត្តនៅក្នុងការផ្តល់ពិន្ទុកលើកទី២ធ្លាក់ចុះ។ ក្រោយពីទទួលបានព័ត៌មានពីវាគ្មិន នូវការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ ប្រែប្រួលការវាយតម្លៃរបស់ខ្លួនកាន់តែអវិជ្ជមានលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ឆ្នាំទី១។ លទ្ធផលនេះ បញ្ជាក់បានថា ទោះបីជាមានព័ត៌មាន ប្រជាពលរដ្ឋនៅតែមិនពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។គេ

ឃើញថា ការផ្តល់ពិន្ទុក្នុង កំរិតពេញចិត្ត ពេញចិត្តខ្លះ ពេញចិត្តច្រើន និងពេញចិត្តស្ទើទាំងស្រុង ឬទាំងស្រុង របស់ប្រជាពលរដ្ឋគឺក្រោម៥០% ។

គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងចំណាយថវិកាជាតិប្រមាណ ៣៤០០ លានដុល្លាសហរដ្ឋអាមេរិក ដើម្បីបំពេញ/អនុវត្តន៍ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ មានប្រជាពលរដ្ឋនៅខេត្តសៀមរាប និង រាជធានីភ្នំពេញចំនួន ៤៤,៤% ពេញចិត្តចំពោះលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយបាយទាំងនោះ ដែលភាគច្រើននៃប្រជាពលរដ្ឋទាំងនោះពេញចិត្តខ្លះតែប៉ុណ្ណោះ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់ ៥៥,៦% មិនពេញចិត្តនឹងលទ្ធផលនការបំពេញ/អនុវត្តគោលនយោបាយទាំងនោះ ។

## ឧបសម្ព័ន្ធ

1. សេចក្តីសង្ខេបគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ (គោលនយោបាយមានសូចនាករច្បាស់លាស់ និងគោលនយោបាយមិនមានសូចនាករច្បាស់លាស់)
2. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
3. ទម្រង់សំនួរផ្តល់ពិន្ទុលើលទ្ធផល នៃការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល
4. តារាងលទ្ធផលការផ្តល់ពិន្ទុ នៃការបំពេញ/អនុវត្តន៍គោលនយោបាយមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល សម្រាប់ខេត្តសៀមរាម និងរាជធានីភ្នំពេញ
5. បញ្ជីរាយនាមសមាសភាពរាជរដ្ឋាភិបាលនីតកាលទី៥នីតិកាលទី៥
6. រូបភាពសកម្មភាពវេទិកាម្ចាស់ឆ្នោត
7. អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍

# សេចក្តីសង្ខេប គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥

## 1. គោលនយោបាយមានសូចនាករច្បាស់លាស់

គោលនយោបាយដែលមានសូចនាករច្បាស់លាស់ គឺគោលនយោបាយដែលអាចឆ្លើយតបនឹងសំណួរមួយចំនួនក្នុងចំណោមសំណួរដូចជាៈ ធ្វើអ្វី? ធ្វើនៅកន្លែងណា? ធ្វើចំនួនប៉ុន្មាន? ធ្វើដោយរបៀបណា? និងសម្រេចបាននៅពេលណា? ធ្វើដោយនរណា? ក្នុងនីតិកាលទី៥នេះ គោលនយោបាយមានសូចនាករច្បាស់មានត្រឹមតែ១៦ចំណុច ក្នុងវិស័យចំនួនពីរគឺ (០២) គឺៈ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចនៃកម្មវិធីនយោបាលរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ៈ

### វិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចៈ

1. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។
2. សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។
3. បន្តខិតខំសម្រេចនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោននៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។
4. រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជនផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។
5. រក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋានធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។
6. បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។
7. សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាលជិត២លានហិចតា នៅរវាងដើមឆ្នាំ២០១៤ ក្នុងក្របខណ្ឌនៃការអនុវត្ត «នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។
8. កសាងគោលនយោបានជាតិ ស្តីពីសិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាជនក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។
9. កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំតាមស្តង់ដារឯកភាពជាតិមួយ។
10. រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹងជញ្ជូន។
11. ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំបានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។
12. ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិចំនួន៨០%នៃចំនួនភូមិទាំងអស់។

13. ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់។

**វិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច**

14. បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ ដែលនៅមិនទាន់មានអនុវិទ្យាល័យ។

15. រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ស្របទៅនឹងការវិវត្តន៍នៃសង្គម សេដ្ឋកិច្ច។

16. ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន ឲ្យទទួលបានរបបប្រាក់សោធន៍ដូចមន្ត្រីរាជការដែរចាប់ពីឆ្នាំ២០១៥។

## 2. គោលនយោបាយមិនមានសូចនាករច្បាស់លាស់

**វិស័យៈ ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

- **ការការពារជាតិ**

ពង្រឹងកិច្ចការពារអធិបតេយ្យជាតិ ដោយយកចិត្តទុកដាក់លើការកសាងផែនការយុទ្ធសាស្ត្រការពារជាតិ ពង្រឹងទីតាំងឈរជើងរបស់កងឯកភាពជួរមុខ កសាងទីតាំងបង្អែក ប្រព័ន្ធការពារ ប្រព័ន្ធទំនាក់ទំនងបញ្ជា ប្រព័ន្ធគាំទ្រផ្លូវគមនាគមន៍ ការតស៊ូតាមផ្លូវច្បាប់នៅតុលាការអន្តរជាតិ និងការលើកទឹកចិត្តប្រជាពលរដ្ឋតាំងទីលំនៅតំបន់នោះ។ បន្តការអនុវត្តការកែទម្រង់កងយុទ្ធពលខេមរភូមិន្ទឲ្យស្របទៅនឹងការរីកចម្រើនប្រទេសជាតិ និងពិភពលោក និងបន្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យការពារជាតិ។

- **សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ការពារសន្តិសុខជាតិ បង្ការដាច់ខាតមិនឲ្យកើតមានការគំរាម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ អាយុជីវិត ឬមហន្តរាយ ដែលបង្កឡើងដោយអំពើភេរវកម្ម។ បន្តពង្រឹងវិធានការគ្រប់គ្រងសង្គម ដោយគួបផ្សំនឹងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។ លើកកម្ពស់ចលនាមហាជនចូលរួមការពារសន្តិសុខ សុវត្ថិភាពនៅក្នុងមូលដ្ឋានឲ្យបានក្លៀវក្លា តាមរយៈការបន្តជម្រុញចលនានៃការអនុវត្តន៍គោលនយោបាយ «ភូមិ ឃុំមានសុវត្ថិភាព» ព្រមទាំងពង្រឹងវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដើម្បីបង្កភាពកក់ក្តៅក្នុងការរស់នៅ និងប្រកបមុខរបររបស់ប្រជាជន។ បន្តផ្តោតការយកចិត្តទុកដាក់លើការរៀបចំសណ្តាប់ធ្នាប់សាធារណៈឲ្យបានល្អប្រសើរ។ បន្តពង្រឹងការគ្រប់គ្រងជនបរទេស និងជម្រុញការដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ និងគ្រប់គ្រងឲ្យមានប្រសិទ្ធភាព។ បន្តលើកកម្ពស់សមត្ថភាពបំពេញភារកិច្ចរបស់កងកម្លាំងនគរបាលជាតិឲ្យកាន់តែមានវិជ្ជាជីវៈ ប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ សីលធម៌ គុណធម៌។

**វិស័យៈ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការព្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ**

- **ការពង្រឹងរដ្ឋបាលសាធារណៈ**

បន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីប្រែក្លាយទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។ បន្តផ្តោតលើការអនុវត្តន៍យុទ្ធសាស្ត្រទាំង៣នៃកម្មវិធីជាតិកែទម្រង់រដ្ឋបាល គឺៈ (១). ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២). ការអភិវឌ្ឍន៍សមត្ថភាព ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងគុណផលការងារ និង (៣). ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងការពង្រឹងក្របខ័ណ្ឌ និងការពង្រាយមន្ត្រីរាជការស៊ីវិល។

- **វិមជ្ឈការ និងវិសហមជ្ឈការ**

អនុវត្តឲ្យកាន់តែស៊ីជម្រៅនូវការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការពង្រឹងរដ្ឋបាល

ថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង បន្តអភិវឌ្ឍន៍ធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងប្រព័ន្ធថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ការកសាងសមត្ថភាព សំដៅធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារដោយមានការចូលរួម គណនេយ្យភាព តម្លាភាព។

- **ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌**

បន្តផ្តោតការយកចិត្តទុកដាក់អនុវត្តឲ្យកាន់តែស៊ីជម្រៅនូវការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឲ្យមានប្រសិទ្ធភាព ដោយពង្រឹងសមត្ថភាព ឯករាជ្យភាព និងភាពមិនលម្អៀងនៃស្ថាប័នតុលាការ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋទូទៅ តាមរយៈ (១). ការជម្រុញកសាងច្បាប់ថ្មីៗ តាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ ការពង្រឹងការអនុវត្តន៍ និងផ្សព្វផ្សាយការអប់រំ និងបណ្តុះបណ្តាលច្បាប់។ (២). ការជម្រុញ កសាងច្បាប់ពាក់ព័ន្ធ និងស្ថាប័នតុលាការ មានជាអាទិ៍ៈ ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សា។ បន្តជំរុញពង្រឹង ស្ថាប័នតុលាការ និងអយ្យការ តាមរយៈការបន្តខិតខំបង្កើនសមត្ថភាពរបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ព្រមទាំងការបង្កើតរដ្ឋបាលតុលាការ តាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ បន្តជម្រុញការកសាងអគារ និងបំពាក់សំភារៈសម្រាប់សាលាជម្រះក្តីឲ្យមានស្តង់ដារ និងបន្តជំរុញ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

- **ប្រឆាំងអំពើពុករលួយ**

បន្តប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការអប់រំដើម្បីឲ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ ការបង្ការទប់ស្កាត់ ដើម្បីម្នាក់ៗមិនអាចប្រព្រឹត្តអំពើពុករលួយ និងការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការដើម្បីឲ្យម្នាក់ៗ មិនហ៊ានប្រព្រឹត្តអំពើពុករលួយ។ បន្តអនុវត្តឲ្យបានសកម្ម និងមានលទ្ធផលខ្ពស់ ក្នុងការលុបបំបាត់ការយកកម្រៃសេវាខុសច្បាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្រសួងស្ថាប័ន មន្ទីរ និងការិយាល័យនានា។

**វិស័យៈ ការអភិវឌ្ឍន៍សេដ្ឋកិច្ច**

- **ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច**

បន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងបរិការណ៍អតិផរណាមានកម្រិតទាប និងអាចគ្រប់គ្រងបាន ហើយអត្រាប្តូរប្រាក់មានស្ថិរភាព។ ទន្ទឹមនេះ ការរីកចម្រើនខាងសេដ្ឋកិច្ច ត្រូវតែធានានូវកាលានុវត្តភាព ការចូលរួម និងការទទួលផលដោយសមធម៌សម្រាប់ប្រជាជនគ្រប់ស្រទាប់។

បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព។ បន្តជម្រុញការអនុវត្តន៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅធ្វើឲ្យប្រព័ន្ធនេះក្លាយជាឧបករណ៍អភិវឌ្ឍន៍មួយដ៏មានប្រសិទ្ធភាព។

- **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

បន្តខិតខំជម្រុញការប្រមូលថវិកាជាតិ ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ឲ្យមានកំណើនជារៀងរាល់ឆ្នាំ។ ខាងផ្នែកចំណាយ គឺបន្តផ្តល់អាទិភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដោយផ្សារភ្ជាប់ចំណាយសម្រាប់វិស័យនីមួយៗ ទៅនឹងគណនេយ្យភាពនៃសមិទ្ធកម្មនៅក្នុងវិស័យនោះ។ ការគ្រប់គ្រងការប្រមូលចំណូល និងការចាត់ចែងចំណាយ ត្រូវផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

- **ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**

បន្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលមានការគ្រប់គ្រង និងការត្រួតពិនិត្យសមស្រប មានលក្ខណៈប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងមានតម្លាភាព និងប្រសិទ្ធភាព ព្រមទាំងជម្រុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុជាមួយបណ្ដាប្រទេសក្នុងតំបន់អាស៊ាន។

បន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពទន់ភ្លន់ និងប្រុងប្រយ័ត្ន។ បន្តរក្សារបបអត្រាប្ដូរប្រាក់អណ្ដែតមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល និងជម្រុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយដុល្លារូបនីយកម្ម។

បន្តពង្រឹងប្រព័ន្ធធនាគារឲ្យកាន់តែមានប្រសិទ្ធភាព សមាហរណកម្ម និងការប្រកួតប្រជែង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការគ្រប់គ្រងហានិភ័យ សន្ទនីយភាព ហានិភ័យឥណទាន និងហានិភ័យទីផ្សារ ដោយអនុលោមតាមស្តង់ដារអន្តរជាតិ។ បន្តពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុឲ្យកាន់តែមានភាពរឹងមាំ មានប្រសិទ្ធភាព និងបម្រើផលប្រយោជន៍នៃស្រទាប់ប្រជាជនក្រីក្រ ជាមួយនឹងតម្លៃសេវាហិរញ្ញវត្ថុសមស្របដែលអាចទទួលយកបាន និងបន្តជម្រុញការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារដូចជា វិស័យធានារ៉ាប់រង វិស័យសោធន៍ វិស័យមូលបត្រ និងវិស័យអចលនទ្រព្យជាដើម។

- **ភាពជាដៃគូក្នុងការអភិវឌ្ឍន៍**

បន្តពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិលដោយឈរលើគោលការណ៍ជាមូលដ្ឋាន ដែលមានចរិតសកល និងធានាភាពជាម្ចាស់របស់រដ្ឋ ក្នុងការដឹកនាំការអភិវឌ្ឍន៍ប្រទេសជាតិ។

ពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការ ដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ ដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តន៍គោលនយោបាយផងដែរ។ បន្តពង្រឹងយន្តវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន និងវេទិការាជរដ្ឋាភិបាល ជាមួយអង្គការមិនមែនរដ្ឋាភិបាល។

- **កសិកម្ម**

បន្តអភិវឌ្ឍន៍វិស័យកសិកម្មឲ្យក្លាយជាផ្នែកនាំមុខមួយ នៃមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ពិសេសនៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព តាមរយៈការបញ្ចូលបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ទាំងការដាំដុះ និងការចិញ្ចឹម ការជម្រុញការចូលទីផ្សារអន្តរជាតិនៃផលិតផលកសិកម្មរបស់កម្ពុជា ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានជលផល និងការការពារ និងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព។

- **ដីធ្លី**

បន្តអនុវត្តការកែទម្រង់ដីធ្លី ដែលផ្ដោតលើការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដី និងនគរូបនីយកម្ម ការបែងចែកដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ ដើម្បីការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងដីរដ្ឋប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។ បន្តអនុវត្តគោលនយោបាយ មិនយកពន្ធលើដីធ្លីបង្កបង្កើនផលរបស់កសិករជាលក្ខណៈគ្រួសារ។

បន្តខិតខំកាត់បន្ថយ និងឈានទៅលុបបំបាត់ឲ្យបានភាពអនាធិបតេយ្យរំលោភកាន់កាប់ដីគ្រប់ប្រភេទ

ដោយខុសច្បាប់ ទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្ម និងដោះស្រាយទំនាស់ដីធ្លីប្រកបដោយតម្លាភាពនិងយុត្តិធម៌។ ជម្រុញការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកសាងយុទ្ធសាស្ត្រជាតិនៃការអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន និងតំបន់ឆ្នេរ។

បន្តបែងចែក និងប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈ ប្រកបដោយតម្លាភាព និងសមធម៌ ឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រ យុទ្ធជនពិការ គ្រួសារយុទ្ធជនពលី អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ខ្វះដី កម្មវិធីសម្បទានសង្គមកិច្ច និងការធ្វើប្រទានកម្ម និងការសម្រួលដល់ការវិនិយោគ និងទប់ស្កាត់ការកើតឡើងមានទៀត នូវភាពមិនប្រក្រតីនៃការទន្រ្ទានកាន់កាប់ដីរដ្ឋ។

- **សំណង់**

បន្តពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់ ដោយផ្តោតលើការជម្រុញវិនិយោគ ការកសាងច្បាប់ ការកំណត់ស្តង់ដារសំណង់ និងពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។

- **ឧស្សាហកម្ម និងសិប្បកម្ម**

បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាល សិប្បកម្មប្រកបដោយចីរភាព ដែលមានលក្ខណៈចម្រុះ, សម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែឆ្នៃកម្មន្តសាល ជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីជម្រុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែចង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ពង្រឹងភាពអំណោយផលិតផលនៃបរិស្ថានវិនិយោគ ការជម្រុញការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ច ពិសេសការលើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនតូច និងមធ្យម ការពង្រីកលទ្ធភាពទទួលបានបច្ចេកវិទ្យាជឿនលឿន ការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ ព្រមទាំងការលើកកម្ពស់ការងារស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងមាត្រាសាស្ត្រ។

- **ធនធានរ៉ែ**

អភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដោយលើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគលើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះ តាមច្បាប់ជាធរមានដោយយកចិត្តទុកដាក់សំខាន់លើសុវត្ថិភាព សុខមាលភាព ព្រមទាំងការការពារបរិស្ថាន និងសង្គម បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា។ ទន្ទឹមនេះ ចំណូលដែលបានមកពីធនធានរ៉ែទាំងនេះ ត្រូវបានគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

- **ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

**ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

បន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេសក្នុងតំបន់ និងពិភពលោក។ ចំពោះផ្លូវថ្នល់ បន្តពង្រឹងរាលវិធានការដ៏ម៉ឺងម៉ាត់ ដើម្បីធានាការគ្រប់គ្រងការងារថែទាំ ទន្ទឹមនឹងការបន្តស្តារ និងការអភិវឌ្ឍន៍ផ្លូវ។ បន្តលើកទឹកចិត្តជម្រុញការចូលរួមពីវិស័យឯកជន ក្នុងការវិនិយោគលើការអភិវឌ្ឍន៍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាដឹកជញ្ជូន។ បន្តស្តារឡើងវិញនូវបណ្តាញផ្លូវដែក គឺបណ្តាញពាយ័ព្យទិស និរតីទិស ដើម្បីពង្រឹងវិសាលភាពនៃការដឹកជញ្ជូនទំនិញ អ្នកដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងធ្វើសមាហរណកម្មផ្លូវដែកកម្ពុជា ទៅជាបប្រព័ន្ធផ្លូវដែកតំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ។ បន្តស្តារ និងអភិវឌ្ឍន៍អាកាសយានដ្ឋានជាតិ អន្តរជាតិ និងប្រព័ន្ធនាំផ្លូវអាកាស លើកកម្ពស់ការពង្រឹងសុវត្ថិភាព សន្តិសុខអាកាសចរណ៍

និងការពារបរិស្ថាន ធ្វើឲ្យមានសង្គតិភាពជាមួយគោលនយោបាយដឹកជញ្ជូនផ្លូវអាកាស ថ្នាក់ដឹកនាំតំបន់ អនុតំបន់ និងអន្តរជាតិ។ លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ឲ្យមានលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើចរាចរណ៍នៅលើផ្លូវសាធារណៈ។

**ធនធានទឹក**

បន្តលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់លទ្ធភាពដល់ជនគ្រប់រូបក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្រប។ ធានាការគ្រប់គ្រងបរិមាណ និងគុណភាពទឹកទាំងទឹកលើដី ទាំងទឹកក្រោមដី និងបែងចែកទឹកឲ្យមានសមភាពសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម, ឧស្សាហកម្ម សេវា។ ហើយកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះគំរាមដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋពីគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក។

បន្តផ្តល់អាទិភាពលើការស្តារ កសាង ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព រួមមានអាងស្តុកទឹក ប្រឡាយទឹកសំណង់ទ្វារទឹក លូទឹក ប្រឡាយនាំដីល្បាប់ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់ ការការពារទឹកប្រៃ និងស្ថានីយ៍បូមទឹក។

ពង្រឹងការគ្រប់គ្រងធនធានទឹក ដោយជម្រុញឲ្យមានការគោរពកិច្ចព្រមព្រៀងអន្តរប្រទេស លើការគ្រប់គ្រងទឹកទន្លេមេគង្គ និងចាត់ទុកទឹកជាទ្រព្យសម្បត្តិសាធារណៈ ដែលត្រូវគោរព និងការពារ។ ពង្រឹងការអនុវត្តន៍ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីទប់ស្កាត់រាល់សកម្មភាព ឬគម្រោងសាងសង់នានា ដែលអាចធ្វើឲ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី។ បន្តធ្វើសមាហរណកម្មកម្ពុជាជាមួយសហគមន៍អន្តរជាតិ ក្នុងវិស័យទឹក និងសហការពេញទំហឹងជាមួយបណ្តាប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់នឹងកម្ពុជា ព្រមទាំងជាមួយប្រទេសក្នុងតំបន់ ដើម្បីសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ ៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**ទឹកស្អាត**

ជម្រុញការអភិវឌ្ឍន៍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងផលិតកម្ម សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យ ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ទីប្រជុំជន ជាយក្រុង និងជនបទ។

**ថាមពល**

បន្តអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យ ការផ្តល់សេវានានាដល់សង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈ ១. ការបន្តសាងសង់ស្ថានីយផលិតអគ្គិសនីក្នុងស្រុក និងការអភិវឌ្ឍន៍បណ្តាញបញ្ជូនអនុស្ថានីយ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនី និង២. ធ្វើសមាហរណកម្មប្រព័ន្ធថាមពលកម្ពុជា ទៅក្នុងថាមពលរបស់តំបន់អាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ។ បន្តជម្រុញការធ្វើពិពិធកម្ម?ថាមពលក្នុងនោះរួមមានការបង្កើតប្រភពថាមពលស្អាត និងប្រភពថាមពលកកើតឡើងវិញ។ លើកទឹកចិត្តដល់ការចូលរួមរបស់

វិស័យឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មផ្តល់សេវាអគ្គិសនី ដែលគោរពតាមការកំណត់នៃច្បាប់ បទបញ្ញត្តិ ស្តង់ដារ និងនីតិវិធីជាធរមាន។

**បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍**

បន្តអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ឲ្យមានលក្ខណៈទំនើប មានគុណភាពខ្ពស់ស្របស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្រប ដណ្តប់នៅទូទាំងប្រទេស។

បន្តលើកទឹកចិត្តវិនិយោគឯកជនធ្វើទំនើបបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជំរុញការប្រកួត ប្រជែងដោយយុត្តិធម៌ ក្នុងទីផ្សារសេវាប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយផ្អែកលើច្បាប់ និងលិខិត បទដ្ឋាននានា ទប់ស្កាត់ការធ្វើអាជីវកម្មផ្តាច់មុខក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

បន្តអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលគ្រប់គ្រងអេឡិចត្រូនិច ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំង ជំរុញការបណ្តុះបណ្តាលមន្ត្រីរាជការ សិស្ស និស្សិតលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ បង្កើនវិសាលភាព និងគុណភាពនៃបណ្តាញផ្សព្វផ្សាយ ទាំងការផ្សាយក្នុងប្រទេស និងក្រៅប្រទេស។

**ការអភិវឌ្ឍន៍ជនបទ**

បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវ ជនបទ ការរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទ ជាពិសេសការកែលម្អផ្លូវ ជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។ បន្តអភិវឌ្ឍន៍សេដ្ឋកិច្ច ជនបទ តាមរយៈការជំរុញវិស័យឥណទានជនបទ ដើម្បីផ្តល់សេវាប្រាក់កម្ចី ដែលមានអត្រាការប្រាក់ សមរម្យជូនប្រជាជននៅជនបទ និងការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការជំរុញការអភិវ ឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញខ្នាតគ្រួសារ ខ្នាតតូច និងមធ្យម ដោយយកចិត្តទុកដាក់ផ្តល់ បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារសម្រាប់ផលិត ផលជនបទ។

បន្តអភិវឌ្ឍន៍តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិពេញលេញរបស់បងប្អូនជនជាតិដើមភាគតិច ក្នុងការចូលរួមធ្វើសេចក្តី សម្រេចនានា និងធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា។

**ពាណិជ្ជកម្ម**

បន្តជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើន ល្បឿនសមាហរណកម្ម ទៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ជាពិ សេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅធ្វើឲ្យសម្រេចសហគមន៍អាស៊ានឆ្នាំ ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។

បន្តពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទីផ្សារក្នុងប្រទេសជាមួយនឹងទីផ្សារ ក្រៅប្រទេស លើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពផលិត និងផ្គត់ផ្គង់ ជំរុញការវិនិយោគ និងការនាំចេញ ទំនិញ ដោយផ្តោតលើការបង្កើនគុណភាពផលិតផលក្នុងស្រុក ព្រមទាំងការបង្កើតបន្ថែមមុខរបរ

និងមុខទំនិញថ្មីៗ។

ផ្តោតការយកចិត្តទុកដាក់ជាប្រចាំលើការរក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ បន្តធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ពិសេសចំពោះបណ្តាមុខទំនិញជាយុទ្ធសាស្រ្តដូចជា ស្រូវ អង្ករ ប្រេងឥន្ធនៈ អគ្គិសនី ទឹក និងបណ្តាមុខទំនិញផ្សេងៗទៀត ដោយចាត់វិធានការរាំងខ្ទប់បាតុភាពស្តុកទំនិញលក់ដំឡើងថ្លៃ ឬការលក់បំប៉ោងថ្លៃ។ ខិតខំរក្សាទីផ្សារដែលមានស្រាប់ និងបន្តចរចាបើកច្រកទីផ្សារជាមួយប្រទេសជាដៃគូពាណិជ្ជកម្មនានា និងបន្តចូលរួមយ៉ាងសកម្មជាមួយបណ្តាប្រទេសនៃសមាគមអាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសធំៗ ក្នុងពិភពលោក ដើម្បីពង្រីកទីផ្សារឲ្យបានជាអតិបរមា។

ការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញា និងបន្តលើកស្ទួយផលិតផលសម្គាល់ភូមិសាស្រ្ត ផលិតផលដែលបង្ហាញនូវមរតកវប្បធម៌ប្រពៃណី ដែលជាស្នាដៃរបស់ផលិតករខ្មែរ។ ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ទប់ស្កាត់សកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ រាំងស្កាត់ការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព។ បន្តជំរុញចលនា «ភូមិមួយ-ផលិតផលមួយ»។

**ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញការវិនិយោគ**

បន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាព ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍន៍ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ។ បន្តកសាងអភិបាលកិច្ចសាជីវកម្មល្អ និងបន្តការខិតខំធ្វើឲ្យបរិស្ថានវិនិយោគ និងធុរកិច្ចនៅកម្ពុជាកាន់តែមានភាពអំណោយផល។

បន្តពង្រឹងអភិក្រមបើកចំហសម្រាប់ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញវិនិយោគ សំដៅពង្រីកច្រកចូលទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ។

ធានាបរិស្ថានវិនិយោគនិងធុរកិច្ច
ប្រកបដោយភាពអំណោយផលសម្រាប់ទទួលការវិនិយោគទាំងក្នុងប្រទេស និងពីក្រៅប្រទេស តាមរយៈការបន្តដាក់ចេញនូវបណ្តាវិធានការសំខាន់ៗសំដៅផ្តោតលើការធានាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធានាស្ថិរភាព និងភាពគត់មត់នៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការសម្រួលពាណិជ្ជកម្ម និងការសម្រួលធុរកិច្ចមាជាអាទិ៍ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍យន្តការ «ច្រកចេញ ចូលតែមួយ» ការលុបបំបាត់ចំណាយក្រៅផ្លូវការជាដើម។

បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តន៍វិធានការនានា សំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃអគ្គិសនី ព្រមទាំងបន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

**ទេសចរណ៍**

បន្តអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាពដោយប្រកាន់ខ្ជាប់នូវទស្សនៈ «ការអភិវឌ្ឍន៍បម្រើឲ្យការអភិរក្ស និងការអភិរក្សបម្រើការអភិវឌ្ឍ»។ យកចិត្តទុកដាក់ការគ្រប់គ្រង និងបន្តខិតខំថែរក្សាឲ្យបានល្អនូវរាល់គុណតម្លៃនៃសម្បត្តិ

មរតក ព្រមទាំងអភិវឌ្ឍន៍គោលដៅទេសចរណ៍សំខាន់ៗរបស់ជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងខិតខំជម្រុញការវិនិយោគ ក្នុងវិស័យទេសចរណ៍ និងបង្កើតផលិតផលទេសចរណ៍ថ្មីៗ ប្រកបដោយគុណភាពថែមទៀត។ កាត់បន្ថយការឆ្លុះឆ្លាយក្នុងវិស័យទេសចរណ៍ឲ្យកាន់តែតិចគឺត្រឹម១៥% នៅរយៈពេល៥ ឆ្នាំខាងមុខ។ ចូលរួមអនុវត្តទិសដៅនៃការអភិវឌ្ឍន៍បៃតងតាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីក្រុងបៃតង រមណីយដ្ឋានស្អាត រមណីយដ្ឋានបៃតង។

បង្កើនការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ទាំងរដ្ឋ ឯកជន ប្រជាជន និងដៃគូរអភិវឌ្ឍន៍ក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា ព្រមទាំងបន្តយកទុកដាក់ពង្រឹង និងពង្រីកបណ្តាលសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តប្រជាជនឲ្យចូលរួមអភិវឌ្ឍន៍វិស័យទេសចរណ៍ ការពារបរិស្ថាន ការពារធនធានវប្បធម៌ និងធម្មជាតិ។

**បរិស្ថាន**

បន្តការថែរក្សា ការពារជីវៈចម្រុះនិងប្រព័ន្ធអេកូឡូសី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចិរភាពទាំងនៅដែនគោកទាំងនៅដែនសមុទ្រ។ បន្តបង្កើនកិច្ចការពារគុណភាពបរិស្ថាន និងអភិរក្សធនធានធម្មជាតិឲ្យមានចិរភាពក្នុងប្រព័ន្ធអេកូឡូស៊ី។ បន្តពង្រឹងច្បាប់ស្តីពីបរិស្ថានសំដៅថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាននិងបញ្ចៀសគ្រោះមហន្តរាយនានាដោយយកចិត្តទុកដាក់វាយតម្លៃ និងត្រួតពិនិត្យឲ្យបានហ្មត់ចត់នូវប៉ះពាល់បរិស្ថានក្នុងការអនុវត្តន៍គម្រោងអភិវឌ្ឍន៍នានា។

**វិស័យ៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារវប្បធម៌ និងសង្គមកិច្ច**

- **អប់រំ**

បន្តកសាង និងអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់ផ្នែក រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃ ឆ្លើយតបទៅនឹងការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ដោយបន្តលើកកម្ពស់គោលការណ៍ «អប់រំសម្រាប់ទាំងអស់គ្នា» តាមរយៈការធានានូវលទ្ធភាពបានសេវាអប់រំប្រកបដោយសមធម៌ ដែលផ្តល់ឱកាសស្មើៗគ្នាទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ ការអនុវត្តន៍គោលការណ៍នេះ ត្រូវផ្សារភ្ជាប់ និងការអប់រំមនសិការស្នេហាជាតិការអប់រំអំពីប្រវត្តិសាស្ត្រ ការអប់រំវប្បធម៌សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម ការប្រឆាំងនឹងអំពើហិង្សា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន និងការរើងអើងគ្រប់រូបភាព។ បន្តជំរុញការកសាងសាលារៀនឲ្យដល់ភូមិ កាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស បង្កើនថវិកាចំណាយសម្រាប់គ្រឹះស្ថានសិក្សា ពង្រាយគ្រូបង្រៀនឲ្យដល់គ្រប់ទីកន្លែង ពង្រឹងអន្តេវាកសិដ្ឋាន បំផុសចលនាជាតិ និងពង្រីកការចូលរួមពីវិស័យឯកជនព្រមទាំងដៃគូរអភិវឌ្ឍន៍នានា។

បង្កើនគុណភាព និងប្រសិទ្ធភាព តាមរយៈការពង្រឹងការងារបណ្តុះបណ្តាល និងវិក្រិតការគ្រូបង្រៀន ការកែលំអកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀន ការពង្រឹងគុណភាពការប្រឡង ការសិក្សាភាសាបរទេស ការកែលម្អលក្ខខ័ណ្ឌនៃការសិក្សា

ការបង្កើនបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាជាដើម។

បន្តអភិវឌ្ឍន៍ស្ថាប័ន និងកសាងសមត្ថភាពរបស់មន្ត្រីអប់រំ ដោយបន្តការកសាងច្បាប់ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធវិស័យអប់រំ ពង្រឹងរចនាសម្ព័ន្ធការងារ និងបណ្តុះបណ្តាលជំនាញដល់មន្ត្រីអប់រំសំដៅអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់។

- **កីឡា**

បន្តអភិវឌ្ឍន៍វិស័យកីឡា រួមទាំងកីឡាជនពិការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានការរីកចម្រើនស្របជាមួយនឹងការរីកចម្រើននៃវិស័យកីឡាក្នុងតំបន់ ដោយពង្រឹងការអនុវត្តន៍គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡាឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អដើម្បីចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខដូចជា អាស៊ានហ្គេម ជាដើម។

- **សុខាភិបាល**

បន្តយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យសុខាភិបាល សំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវសុខភាពប្រជាជន តាមរយៈការផ្តល់សេវាសុខភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមានចិរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទ។

ការខិតខំកាត់បន្ថយឲ្យបានជាអតិបរមានូវការស្លាប់របស់មាតាទារក និងកុមារ កាត់បន្ថយការឈឺ និងស្លាប់ដោយសារជម្ងឺឆ្លង និងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ តាមរយៈជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់លើបណ្តាកម្មវិធីសំខាន់ៗរួមមានៈ (១). កម្មវិធីសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ អាហារូបត្ថម្ភ និងការអប់រំសុខភាព, (២). កម្មវិធិប្រយុទ្ធនឹងជម្ងឺ ឆ្លងជាពិសេសជម្ងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាមនិងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ ក្នុងនោះខិតខំលុបបំបាត់ជម្ងឺគ្រុនចាញ់ឲ្យបានទាំងស្រុងនៅត្រឹមឆ្នាំ ២០២៥ ព្រមទាំងយកចិត្តទុកដាក់ព្យាបាលអ្នកប្រើប្រាស់សារធាតុញៀន និង(៣). កម្មវិធីពង្រឹង និងពង្រីកប្រព័ន្ធសុខាភិបាលនៅគ្រប់ថ្នាក់ប្រកបដោយវិជ្ជាជីវៈ។

បន្តសាងសងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាការសង់អគារមន្ទីរពេទ្យបង្អែក មណ្ឌលសុខាភាព ប៉ុស្តិ៍សុខភាពនិងបង្កើតបន្ទប់រងចាំឲ្យបានច្រើនថែមទៀត
ពង្រីកសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិឃុំ ពង្រឹងយន្តការលើកលែងការបង់ថ្លៃសេវាពិនិត្យ និងព្យាបាលជម្ងឺសម្រាប់ប្រជាជនក្រីក្រ។

ពង្រឹងការផ្គត់ផ្គង់ឱសថឲ្យបានដល់គោលដៅតាមរបបកំណត់ និងឈានទៅដល់ការលុបបំបាត់ឱសថក្លែងក្លាយ សេវាឯកជនខុសច្បាប់ ព្រមទាំងបង្កើនការវិនិយោគលើឧបករណ៍បរិក្ខាពេទ្យ និងបច្ចេកវិទ្យាទំនើបនៅមន្ទីរបង្អែកថ្នាក់ជាតិ និងខេត្ត។ ពង្រឹងសមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីបុគ្គលិកសុខាភិបាល។

- **ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

បន្តអភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលតម្រងទិសលើការធ្វើឲ្យប្រជាជនមានការងារធ្វើ មានមុខរបរសមរម្យ ត្រឹមត្រូវ និងថ្លៃថ្នូរ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់

និយោគជក និងកម្មករ និយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈ ឲ្យរីកចម្រើន ស្របតាមបទដ្ឋានអន្តរជាតិ។ បន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យបាន កាន់តែប្រសើរឡើងដោយពង្រឹងការអនុវត្តច្បាប់ ស្តីពីការងារ បទដ្ឋានគតិយុទ្ធនានា និងអនុសញ្ញាអន្តរជាតិខាងការងារ។

បន្តពង្រឹងការអនុវត្តសេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ, ប្រឆាំងការរើសអើងសហជីព និងអង្គការវិជ្ជាជីវៈ ជំរុញការកសាងច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីការបង្កើតតុលាការងារ។ ពង្រីកសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និងនិយោជក ព្រមទាំងពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស និងគ្រឹះស្ថាននានាឲ្យបានល្អប្រសើរ។ បន្តការជំរុញតំឡើងប្រាក់ឈ្នួល ការផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់អត្ថប្រយោជន៍នានាដល់កម្មករ និយោជិត។

បង្កើនការការពារ និងគ្រប់គ្រងពលករខ្មែរ និងពលករបរទេស ដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ជាតិ និងគោលការណ៍ សមាហរណមកម្មរបស់សមាគមអាស៊ាន។ ជំរុញការកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននៅគ្រប់ខេត្តដែលអាចផ្តល់ការបណ្តុះបណ្តាលនៅតាមសហគមន៍ និងលើកទឹកចិត្តការចូលរួមនៃវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការពង្រីកកម្មវិធី បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសមស្របឲ្យកាន់តែមានវិសាលភាព ឆ្លើយតមទៅនឹងតម្រូវការសង្គម។

- **វប្បធម៌ ជំនឿ សាសនា**

បន្តការលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ ដើម្បីថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបីយ និងអរូបីយឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឲ្យបានកាន់តែច្រើន ហើយចូលរួមសកម្មភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជន ស្របតាមអត្តន័យ វប្បធម៌ជាសេដ្ឋកិច្ច។

បន្តផ្តោតលើសកម្មភាពសំខាន់ៗជាអាទិភាព គឺការថែរក្សា និងអភិវឌ្ឍម៍ទំនើបេតិកភណ្ឌ ឲ្យមាននិរន្តភាព ការថែទាំ និងការអភិរក្សប្រាសាទបុរាណនានា និងការខិតខំពង្រីកទីផ្សារវប្បធម៍។ បង្កើនការងប់រំ ពិសេសការអប់រំស្រទាប់យុវជន និងកុមារឲ្យចូលរួមថែរក្សា លើកតម្កើង អភិវឌ្ឍន៍វប្បធម៌ជាតិ និង កាត់បន្ថយឥទ្ធិពលវប្បធម៌វិជ្ជមានពីបរទេស។ ថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ល្អ និងភាសារបស់បងប្អូនជនជាតិដើមភាគតិច។ បន្តគោរពសេរីភាពខាងជំនឿ និងសាសនាដោយលើកស្ទួយព្រះពុទ្ធសាសនា និងគាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម និងទប់ស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម និងបង្កជាវិបត្តិសាសនា។

- **សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

បន្តអភិវឌ្ឍន៍វិស័យសង្គមកិច្ចអតីតយុទ្ធ និងយុវនីតិសម្បទាឲ្យកាន់តែមានវិសាលភាពទូលំទូលាយដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹង មាំនិងទូលំទូលាយសម្រាប់ធានារ៉ាប់រង ចំពោះហានិភ័យសង្គមជាយថាហេតុ។

ជំរុញការបង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយប្រជាជនក្រីក្រងាយរងគ្រោះ និងជួយជនរងគ្រោះ

មហន្តរាយផ្សេងៗ និងទប់ស្កាត់ទុរគតភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ ជំរុញការអនុម័តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ប្រជាជនកម្ពុជា។

លើកកម្ពស់ការអនុវត្តន៍ការងារយុវនីតិសម្បទា និងការអនុវត្តន៍កម្មវិធីយុត្តិធម៌អនិតិជន តាមរយៈការពង្រឹង និងការព្យាបាលស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះ។ បន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ ជំរុញកិច្ចការពារលើកកម្ពស់សុខុមាលភាពជនពិការ។ បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ ដោយយកចិត្តទុកដាក់ជំរុញអនុវត្តកម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឲ្យកាន់តែប្រសើរ ពង្រឹងសកម្មភាពសហគមន៍មនុស្សចាស់នៅតាមឃុំ សង្កាត់។ បន្តអនុវត្តគោលនយោបាយជាតិ ចំពោះអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តន៍គោលនយោបាយរដ្ឋទទួលបន្ទុកបង់ប្រាក់វិភាគទាន៦%នៃប្រាក់បៀវត្ស
ជូសមន្ត្រីរាជការស៊ីវិលសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងរដ្ឋបង់ប្រាក់វិភាគទាន តាមការកំណត់ជូសកងកម្លាំងប្រដាប់អាវុធសម្រាប់ទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន។

- **ស្ត្រី និងកុមារ**

បន្តពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅទៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឲ្យកាន់ទូលំទូលាយ និងខ្លាំងក្លាថែមទៀតនៅក្នុងការកសាងការពារមាតុភូមិ។ បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស និងផ្តល់កាលានុភាពដល់ស្ត្រីក្នុងពង្រឹងមុខរបរ បង្កើនចំណូល និងកសាងសហគ្រិនភាព បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឲ្យបានកាន់តែច្រើនឡើងក្នុងស្ថាប័នជាតិគ្រប់ជាន់ថ្នាក់។

ពង្រឹងការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសការអនុវត្តន៍ផែនការជាតិស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រី ដើម្បីលុបបំបាត់នូវឥរិយាបថអំពើហឹង្សាលើស្ត្រី។ ធានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ «សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ»។

- **យុវជន**

បន្តជំរុញការអភិវឌ្ឍន៍យុវជនឲ្យមានការរីកចម្រើនគ្រប់ផ្នែកទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាព កាយសម្បទាន និងមានសីលធម៌រស់នៅថ្លៃថ្នូរ តាមរយៈ (១)ការបន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកទេស និងកម្មវិធីបំណិនជីវិត (២).ការបង្កើនការអប់រំ ការថែទាំ និងផ្តល់សេវាសុខភាព ប្រកបដោយគុណភាព និងសមធម៌ដល់យុវជន ពង្រឹងសកម្មភាពសិល្បៈ កីឡា ការកម្សាន្តសម្រាប់យុវជន (៣). ការបន្តការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជន។ (៤). ការលើកទឹកចិត្តពង្រឹងចលនាស្មគ្រ័ចិត្តរបស់យុវជនចូលរួមក្នុងសកម្ម

ភាពកសាងយុត្តិធម៌ក្នុងសង្គម ការទប់ស្កាត់បាតុភាពអសកម្មតាមសហគមន៍ និងសកម្មផ្សេងៗទៀត (៥). ការជំរុញចលនាកាយរិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ (៦). ការជំរុញចលនាយុវជនកាកបាទក្រហម ដើម្បីពង្រឹង និងពង្រីកស្មារតីមនុស្សធម៌ ឲ្យបានទូលំទូលាយក្នុងមហាជន។

# ព្រះរាជក្រម

នស/រកម/១១១៣/០១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
| 14 | អភិវឌ្ឍវិស័យឧស្សាហកម្មកម្មន្តសាល (ដោយម៉ាស៊ីន) និងសិប្បកម្ម | 121 | 28.1 | 48.8 | 10.7 | 5.8 | 6.6 | 69 | 34.8 | 39.1 | 18.8 | 2.9 | 4.3 | 2.1 | 2.0 | -0.1 |
| 15 | អភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន | 120 | 81.7 | 12.5 | 1.7 | 0.8 | 3.3 | 69 | 94.2 | 4.3 | 0.0 | 0.0 | 1.4 | 1.3 | 1.1 | -0.2 |
| 16 | បង្កើនការស្តារ, ការសាងសង់ និងការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន.... | 120 | 25.8 | 30 | 27.5 | 7.5 | 9.2 | 69 | 33.3 | 40.6 | 13.0 | 4.3 | 8.7 | 2.4 | 2.1 | -0.3 |
| 17 | លើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹក និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី | 121 | 32.2 | 28.1 | 23.1 | 7.4 | 9.1 | 69 | 47.8 | 23.2 | 17.4 | 7.2 | 4.3 | 2.3 | 2.0 | -0.3 |
| 18 | ផ្គត់ផ្គង់ទឹកស្អាត ដោយបណ្តាញរដ្ឋ និងឯកជន | 120 | 10.8 | 25.8 | 27.5 | 18.3 | 17.5 | 69 | 30.4 | 31.9 | 14.5 | 13.0 | 10.1 | 3.1 | 2.4 | -0.7 |
| 19 | អភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានថ្លៃសមរម្យ | 121 | 46.3 | 31.4 | 9.9 | 6.6 | 5.8 | 69 | 52.2 | 34.8 | 10.1 | 0.0 | 2.9 | 1.9 | 1.7 | -0.2 |
| 20 | អភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | 118 | 22 | 33.1 | 22 | 7.6 | 15.3 | 69 | 55.1 | 21.7 | 13.0 | 0.0 | 10.1 | 2.6 | 1.9 | -0.7 |
| 21 | បន្តកសាងផ្លូវជនបទ ជំរុញវិស័យឥណទានការអភិវឌ្ឍសិប្បកម្ម សហគ្រាស និងមុខជំនាញគ្រួសារ ខ្នាតតូច និងមធ្យមព្រមទាំងពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ | 121 | 37.2 | 38.8 | 8.3 | 4.1 | 11.6 | 69 | 59.4 | 27.5 | 8.7 | 0.0 | 4.3 | 2.1 | 1.6 | -0.5 |
| 22 | អភិវឌ្ឍវិស័យពាណិជ្ជកម្ម តាមរយៈ ទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរ | 117 | 43.6 | 29.9 | 11.1 | 7.7 | 7.7 | 69 | 59.4 | 24.6 | 5.8 | 4.3 | 5.8 | 2.1 | 1.7 | -0.4 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ណកម្មទីផ្សារសេរីសំខាន់ៗ | | | | | | | | | | | | | | | |
| 23 | ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និង ជំរុញការវិនិយោគក្នុងស្រុក | 121 | 25.6 | 38 | 18.2 | 6.6 | 11.6 | 69 | 46.4 | 30.4 | 14.5 | 2.9 | 5.8 | 2.4 | 1.9 | -0.5 |
| 24 | អភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិ | 119 | 28.6 | 19.3 | 24.4 | 12.6 | 15.1 | 68 | 61.8 | 16.2 | 14.7 | 1.5 | 5.9 | 2.7 | 1.7 | -1.0 |
| 25 | ថែរក្សា ការពារជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ | 120 | 65 | 22.5 | 5.8 | 0.8 | 5.8 | 69 | 68.1 | 17.4 | 7.2 | 2.9 | 4.3 | 1.6 | 1.6 | 0.0 |
| **វិស័យៈ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច** | | | | | | | | | | | | | | | | |
| 26 | អភិវឌ្ឍន៍ធនធានមនុស្ស ទាំងខាងវិទ្យាសាស្ត្រ និងបច្ចេកទេស និងចំណេះធ្វើ | 120 | 33.3 | 30.8 | 20 | 5.8 | 10 | 68 | 52.9 | 30.9 | 11.8 | 0.0 | 4.4 | 2.3 | 1.7 | -0.6 |
| 27 | អភិវឌ្ឍន៍វិស័យកីឡា រួមទាំងកីឡាជន ពិការ | 118 | 22.9 | 37.3 | 17.8 | 7.6 | 14.4 | 69 | 50.7 | 27.5 | 14.5 | 4.3 | 2.9 | 2.5 | 1.8 | -0.7 |
| 28 | អភិវឌ្ឍន៍វិស័យសុខាភិបាល ចិត្តទុកដាក់ប្រជាជនក្រីក្រងាយរងគ្រោះ | 121 | 72.7 | 16.5 | 3.3 | 0.8 | 6.6 | 69 | 72.5 | 18.8 | 4.3 | 1.4 | 2.9 | 1.5 | 1.43 | -1.4 |
| 29 | អភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 115 | 24.3 | 43.5 | 7.8 | 7.8 | 16.5 | 69 | 39.1 | 37.7 | 8.7 | 4.3 | 10.1 | 2.5 | 2.1 | -0.4 |
| 30 | លើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ ធម្មជាតិ សេរីភាពខាងជំនឿ និងសាសនា | 122 | 36.9 | 26.2 | 16.4 | 5.7 | 14.8 | 69 | 50.7 | 34.8 | 7.2 | 2.9 | 4.3 | 2.4 | 1.8 | -0.6 |
| 31 | អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា | 122 | 53.3 | 30.3 | 5.7 | 3.3 | 7.4 | 69 | 63.8 | 23.2 | 7.2 | 1.4 | 4.3 | 1.8 | 1.6 | -0.2 |
| 32 | ពង្រឹងស្ថានភាព តួនាទី និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីក្នុងសង្គម និងឲ្យកុមារទទួលបាន សិទ្ធិជាមូលដ្ឋាន | 120 | 32.5 | 28.3 | 20.0 | 5 | 14.2 | 69 | 50.7 | 33.3 | 7.2 | 4.3 | 4.3 | 2.40 | 1.8 | -0.6 |
| 33 | អភិវឌ្ឍន៍យុវជនខាងចំណេះដឹង ចំណេះធ្វើ សុខភាព កាយសម្បទាន និងសីលធម៌ | 119 | 45.4 | 31.1 | 9.2 | 5.0 | 9.2 | 69 | 50.7 | 30.4 | 13.0 | 2.9 | 2.9 | 2.o | 1.8 | -0.2 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | រស់នៅថ្លៃថ្នូរ | | | | | | | | | | | | | | | |
| **លទ្ធផលការផ្តល់ពិន្ទុនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥** (**គិតជាមធ្យម**) | | | | | | | | | | | | | | | | |
| | ការបំពេញ/អនុវត្តន៍គោល នយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ | | 48.7 | 27.3 | 11.3 | 5.3 | 7.3 | | 63.1 | 23.9 | 8.2 | 1.5 | 3.3 | 2.0 | 1.6 | |

# លទ្ធផលផ្ដល់ពិន្ទុដោយប្រជាពលរដ្ឋនៅខេត្តសៀមរាប

| លេខរៀង | គោលនយោបាយរបស់ រាជរដ្ឋាភិបាល នីតិកាលទី៥ មិនមានសូចនាករច្បាស់លាស់ | លទ្ធផលលើកទី១ (គិតជា%) | | | | | | លទ្ធផលលើកទី២ (គិតជា%) | | | | | | លទ្ធផល មធ្យម[2] | | ការប្រែប្រួល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនអ្នកផ្ដល់ពិន្ទុ (នាក់) | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | ពេញចិត្តខ្លះ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល | ពេញចិត្តច្រើន | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | ចំនួនអ្នកផ្ដល់ពិន្ទុ (នាក់) | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច | ពេញចិត្តខ្លះ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល | ពេញចិត្តច្រើន | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង | លើកទី១ | លើកទី២ | |
| **វិស័យ៖ ការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ** | | | | | | | | | | | | | | | | |
| 01 | ពង្រឹងកិច្ចការពារអធិបតេយ្យជាតិ និងចាត់ចែងកងកំលាំងប្រដាប់អាវុធ | 82 | 41.5 | 26.8 | 23.2 | 6.1 | 2.4 | 74 | 59.5 | 24.3 | 14.9 | 1.4 | 0 | 2.0 | 1.6 | -0.4 |
| 02 | រក្សាសន្តិសុខជាតិ និងសង្គម និងដោះស្រាយបញ្ហាអន្តោប្រវេស៍ខុសច្បាប់ | 82 | 51.2 | 32.9 | 12.2 | 2.4 | 1.2 | 74 | 68.9 | 23 | 6.8 | 1.4 | 0 | 1.7 | 1.4 | -0.3 |
| **វិស័យ៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តធម៌ និងការប្រឆាំងអំពើពុករលួយ** | | | | | | | | | | | | | | | | |
| 03 | កែទម្រង់រដ្ឋបាលសាធារណៈ ឬសេវាកម្មរដ្ឋបាលសាធារណៈ | 82 | 43.9 | 28 | 18.3 | 8.5 | 1.2 | 73 | 54.8 | 23.3 | 16.4 | 5.5 | 0 | 2.0 | 1.7 | -0.2 |

[2] 1 ដល់ 1.5: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច 1.6 ដល់ 2.5: ពេញចិត្តខ្លះ 2.6 ដល់ 3.5: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល 3.6 ដល់ 4.5: ពេញចិត្តច្រើន 4.6 ដល់ 5: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង។

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 04 | កំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ | 82 | 41.5 | 30.5 | 12.2 | 14.6 | 1.2 | 74 | 63.5 | 18.9 | 14.9 | 1.4 | 1.4 | 2.0 | 1.6 | -0.5 |
| 05 | កែទម្រង់ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | 83 | 57.8 | 25.3 | 7.2 | 8.4 | 1.2 | 73 | 65.8 | 20.5 | 11 | 2.7 | 0 | 1.7 | 1.5 | -0.2 |
| 06 | ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ | 83 | 60.2 | 15.7 | 13.3 | 8.4 | 2.4 | 74 | 71.6 | 13.5 | 9.5 | 4.1 | 1.4 | 1.8 | 1.5 | -0.3 |
| **វិស័យៈ ការអភិវឌ្ឍន៍សេដ្ឋកិច្ច** | | | | | | | | | | | | | | | | |
| 07 | បន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនសេដ្ឋកិច្ចខ្ពស់... | 83 | 44.6 | 30.1 | 19.3 | 4.8 | 1.2 | 74 | 51.4 | 27 | 18.9 | 2 | 0 | 1.9 | 1.7 | -0.1 |
| 08 | ប្រមូលថវិកាជាតិ និងផ្តល់អាទិភាពចំណាយ | 83 | 45.8 | 28.9 | 15.7 | 7.2 | 2.4 | 74 | 63.5 | 17.6 | 14.9 | 2.7 | 1.4 | 1.9 | 1.6 | -0.3 |
| 09 | អភិវឌ្ឍវិស័យហិរញ្ញវត្ថុដោយ រក្សាស្ថិរភាពប្រាក់រៀល... | 83 | 63.9 | 18.1 | 10.8 | 2.4 | 4.8 | 73 | 64.4 | 12.3 | 8.2 | 8.2 | 6.8 | 1.7 | 1.8 | 0.1 |
| 10 | សហប្រត្តិការអភិវឌ្ឍន៍ រវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន សង្គមស៊ីវិល ឬអង្គការអន្តរជាតិ | 83 | 27.7 | 37.3 | 16.9 | 8.4 | 9.6 | 74 | 45.9 | 28.4 | 10.8 | 10.8 | 4.1 | 2.3 | 2.0 | -0.4 |
| 11 | អភិវឌ្ឍន៍វិស័យកសិកម្ម | 82 | 56.1 | 22 | 12.2 | 6.1 | 3.7 | 74 | 62.2 | 21.6 | 13.5 | 2.7 | 0 | 1.8 | 1.6 | -0.2 |
| 12 | កំណែទម្រង់ដីធ្លី និងការដោះស្រាយបញ្ហាដីធ្លី | 83 | 80.7 | 8.4 | 4.8 | 2.4 | 3.6 | 74 | 77 | 10.8 | 8.1 | 4.1 | 0 | 1.4 | 1.4 | 0.0 |
| 13 | គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យសំណង់ | 83 | 38.6 | 34.9 | 18.1 | 8.4 | 0 | 74 | 47.3 | 23 | 23 | 5.4 | 1.4 | 2.0 | 1.9 | -0.1 |
| 14 | អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាល (ដោយម៉ាស៊ីន) និងសិប្បកម្ម | 83 | 30.1 | 34.9 | 21.7 | 9.6 | 3.6 | 74 | 40.5 | 32.4 | 18.9 | 6.8 | 1.4 | 2.2 | 2.0 | -0.3 |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 15 | អភិវឌ្ឍន៍ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន | 83 | 85.5 | 6 | 6 | 0 | 2.4 | 74 | 82.4 | 6.8 | 9.5 | 0 | 1.4 | 1.3 | 1.3 | 0.0 |
| 16 | បង្កើនការស្តារ ការសាងសង់ និងការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន.... | 83 | 43.4 | 30.1 | 13.3 | 9.6 | 3.6 | 74 | 52.7 | 24.3 | 14.9 | 6.8 | 1.4 | 2.0 | 1.8 | -0.2 |
| 17 | លើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹក និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី | 83 | 73.5 | 18.1 | 3.6 | 2.4 | 2.4 | 73 | 67.1 | 20.5 | 8.2 | 2.7 | 1.4 | 1.4 | 1.5 | 0.1 |
| 18 | ផ្គត់ផ្គង់ទឹកស្អាត ដោយបណ្តាញរដ្ឋ និងឯកជន | 83 | 53 | 26.5 | 8.4 | 7.2 | 4.8 | 74 | 48.6 | 31.1 | 12.2 | 2.7 | 5.4 | 1.8 | 1.9 | 0.0 |
| 19 | អភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពល ដែលមានថ្លៃសមរម្យ | 81 | 53.1 | 25.9 | 11.1 | 7.4 | 2.5 | 73 | 64.4 | 21.9 | 8.2 | 2.7 | 2.7 | 1.8 | 1.6 | -0.2 |
| 20 | អភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ | 81 | 25.9 | 27.2 | 21 | 17.3 | 8.6 | 74 | 43.2 | 25.7 | 14.9 | 9.5 | 6.8 | 2.6 | 2.1 | -0.4 |
| 21 | បន្តកសាងផ្លូវជនបទ ជំរុញវិស័យឥណទាន ការអភិវឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញគ្រួសារ ខ្នាតតូច និងមធ្យម ព្រមទាំងពង្រីកទីផ្សារសម្រាប់ ផលិតផលជនបទ | 81 | 60.5 | 18.5 | 12.3 | 3.7 | 4.9 | 73 | 72.6 | 15.1 | 9.6 | 1.4 | 1.4 | 1.7 | 1.4 | -0.3 |
| 22 | អភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទីផ្សារសេរីសំខាន់ៗ | 81 | 58 | 27.2 | 6.2 | 8.6 | 0 | 73 | 65.8 | 20.5 | 9.6 | 2.7 | 1.4 | 1.7 | 1.5 | -0.1 |
| 23 | ទាក់ទាញការវិនិយោគផ្ទាល់ ពីបរទេស | 80 | 50 | 26.3 | 13.8 | 7.5 | 2.5 | 74 | 62.2 | 21.6 | 8.1 | 6.8 | 1.4 | 1.9 | 1.6 | -0.2 |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | និងជំរុញការវិនិយោគក្នុងស្រុក | | | | | | | | | | | | | |
| 24 | អភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជាជាទេសចរណ៍វប្បធម៌ និងធម្មជាតិ | 80 | 41.3 | 18.8 | 13.8 | 15 | 11.3 | 72 | 68.1 | 9.7 | 15.3 | 2.8 | 4.2 | 2.4 | 1.7 | -0.7 |
| 25 | ថែរក្សាការពារជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ | 81 | 74.1 | 19.8 | 4.9 | 0 | 1.2 | 74 | 70.3 | 13.5 | 12.2 | 1.4 | 2.7 | 1.3 | 1.5 | 0.2 |
| **វិស័យៈ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាលការងារ វប្បធម៌ និងសង្គមកិច្ច** | | | | | | | | | | | | | | |
| 26 | អភិវឌ្ឍធនធានមនុស្ស ទាំងខាងវិទ្យាសាស្ត្រ និងបច្ចេកទេស និងចំណេះធ្វើ | 80 | 38.8 | 27.5 | 22.5 | 10 | 1.3 | 74 | 50 | 25.7 | 20.3 | 2.7 | 1.4 | 2.1 | 1.8 | -0.3 |
| 27 | អភិវឌ្ឍវិស័យកីឡា រួមទាំងកីឡាជនពិការ... | 80 | 30 | 36.3 | 17.5 | 8.8 | 7.5 | 74 | 41.9 | 28.4 | 12.2 | 10.8 | 6.8 | 2.3 | 2.1 | -0.2 |
| 28 | អភិវឌ្ឍន៍វិស័យសុខាភិបាល ចិត្តទុកដាក់ប្រជាជនក្រីក្រងាយរងគ្រោះ | 80 | 77.5 | 17.5 | 2.5 | 1.3 | 1.3 | 73 | 83.6 | 11 | 4.1 | 0 | 1.4 | 1.3 | 1.2 | -0.1 |
| 29 | អភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 79 | 38 | 36.7 | 17.7 | 6.3 | 1.3 | 74 | 55.4 | 28.4 | 8.1 | 4.1 | 4.1 | 2.0 | 1.7 | -0.2 |
| 30 | លើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ សេរីភាពខាងជំនឿ និងសាសនា | 80 | 32.5 | 27.5 | 15 | 13.8 | 11.3 | 74 | 55.4 | 18.9 | 14.9 | 5.4 | 5.4 | 2.4 | 1.9 | -0.6 |
| 31 | អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា | 80 | 56.3 | 22.5 | 10 | 5 | 6.3 | 73 | 63 | 19.2 | 8.2 | 4.1 | 5.5 | 1.8 | 1.7 | -0.1 |
| 32 | ពង្រឹងស្ថានភាព តួនាទី និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីក្នុងសង្គម | 81 | 45.7 | 17.3 | 16 | 12.3 | 8.6 | 72 | 48.6 | 22.2 | 12.5 | 8.3 | 8.3 | 2.2 | 2.1 | -0.2 |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | និងឲ្យកុមារទទួលបានសិទ្ធិជាមូលដ្ឋាន | | | | | | | | | | | | | | | |
| 33 | អភិវឌ្ឍន៍យុវជនខាងចំណេះដឹងចំណេះធ្វើ សុខភាព កាយសម្បទាន និងសីលធម៌រស់នៅថ្លៃថ្នូរ | 82 | 51.2 | 23.2 | 15.9 | 7.3 | 2.4 | 73 | 56.2 | 20.5 | 11 | 4.1 | 8.2 | 1.9 | 1.9 | 0.0 |
| **លទ្ធផលការផ្តល់ពិន្ទុនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥** ( **គិតជាមធ្យម** ) | | | | | | | | | | | | | | | | |
| 34 | ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ | | 49.1 | 26.2 | 14.3 | 7.3 | 3.0 | | 61.3 | 21.2 | 11.9 | 3.5 | 2.0 | 1.9 | 1.6 | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
លេខ: ៤២១ រ.ស

# បញ្ជីរាយនាម
# សមាសភាពប្រធាន អនុប្រធានរដ្ឋសភា
# ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា
# និងសមាសភាពរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
# សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា

**យោង:** -សំណើរបស់គណបក្សប្រជាជនកម្ពុជា លេខ:៨៨៦ លគ.គក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣
-សំណើរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លេខ:៧៨២ លស. ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។

សមាសភាពប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំង៩ នៃរដ្ឋសភា និងសមាសភាពរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា មានដូចតទៅៈ

## I. ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំង៩ នៃរដ្ឋសភា

១- សម្តេចអគ្គមហាពញាចក្រី ហេង សំរិន — ប្រធានរដ្ឋសភា
២- ឯកឧត្តម ងួន ញ៉ិល — អនុប្រធានទី១ រដ្ឋសភា
៣- លោកជំទាវ ឃួន សុដារី — អនុប្រធានទី២ រដ្ឋសភា
៤- ឯកឧត្តម ញ៉ែម ថ្ការី — ប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា
៥- ឯកឧត្តម ជាម យៀប — ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៦- ឯកឧត្តម ម៉ុក ម៉ារ៉េត — ប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

៧- ឯកឧត្តម ហ៊ុន ណេង — ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

៨- ឯកឧត្តម ឈាង វុន — ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៩- ឯកឧត្តម ប៉ែន បញ្ញា — ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌

១០- ឯកឧត្តម ម៉ុម ជឹមហ៊ុយ — ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

១១- លោកជំទាវ ហូ ណូន — ប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

១២- លោកជំទាវ និន សាផុន — ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៣- ឯកឧត្តម សុខ ឥសាន — អនុប្រធានគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

១៤- ឯកឧត្តម អាយ ខន — អនុប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

១៥- ឯកឧត្តម ហ៊ួ ស្រ៊ី — អនុប្រធានគណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

១៦- ឯកឧត្តម កែប ជុតិមា — អនុប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ

១៧- ឯកឧត្តម សួស យ៉ារ៉ា — អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

១៨- ឯកឧត្តម ស៊ិក ប៊ុនហុក — អនុប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌

១៩- ឯកឧត្តម ហែម ខន អនុប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

២០- ឯកឧត្តម ប៉ាល់ សំអឿន អនុប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធ យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

២១- ឯកឧត្តម សោម ចិន អនុប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## II. សមាសភាពរាជរដ្ឋាភិបាល :

### នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

### ឧបនាយករដ្ឋមន្ត្រី

១- ឯកឧត្តម ស ខេង

២- ឯកឧត្តម សុខ អាន

៣- ឯកឧត្តម ទៀ បាញ់

៤- ឯកឧត្តម គាត ឈន់ ប្រចាំការ

៥- ឯកឧត្តម ហោ ណាំហុង

៦- លោកជំទាវ ម៉ែន សំអន

៧- ឯកឧត្តម ប៊ិន ឈិន

៨- ឯកឧត្តម យឹម ឆៃលី

៩- ឯកឧត្តម កែ គឹមយ៉ាន

### ទេសរដ្ឋមន្ត្រី

១- ឯកឧត្តម អ៊ឹម ឈុនលឹម

២- ឯកឧត្តម ឆាយ ថន

៣- ឯកឧត្តម ចម ប្រសិទ្ធ

៤- ឯកឧត្តម ញឹម វណ្ណដា ( ទទួលបន្ទុកបេសកកម្មពិសេស )

៥- ឯកឧត្តម យុន ហាំង ( ទទួលបន្ទុកបេសកកម្មពិសេស )
៦- ឯកឧត្តម លី ធុជ ( ទទួលបន្ទុកបេសកកម្មពិសេស )
៧- ឯកឧត្តម ច័ន្ទ សារុន ( ទទួលបន្ទុកបេសកកម្មពិសេស )
៨- ឯកឧត្តម ស៊ុន ចាន់ថុល
៩- ឯកឧត្តម ឱម យ៉ិនទៀង ( ទទួលបន្ទុកបេសកកម្មពិសេស )
១០-ឯកឧត្តម អៀង ម៉ូលី ( ទទួលបន្ទុកបេសកកម្មពិសេស )
១១-ឯកឧត្តម វ៉ា គឹមហុង ( ទទួលបន្ទុកបេសកកម្មពិសេស )
១២-ឯកឧត្តម យឹម ណុលឡា ( ទទួលបន្ទុកបេសកកម្មពិសេស )
១៣-ឯកឧត្តម សេរី កុសល ( ទទួលបន្ទុកបេសកកម្មពិសេស )
១៤-ឯកឧត្តម ហ៊ឹម ឆែម ( ទទួលបន្ទុកបេសកកម្មពិសេស )
១៥-ឯកឧត្តម ជិន ប៊ុនស៊ាន ( ទទួលបន្ទុកបេសកកម្មពិសេស )

## ក្រសួង-រដ្ឋលេខាធិការដ្ឋាន

### ១- ទីស្តីការគណៈរដ្ឋមន្ត្រី

| | |
|---|---|
| ១- ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ប៊ុន អ៊ុយ | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ស្វ ភិរិន្ទ | រដ្ឋលេខាធិការ |
| ៤- លោកជំទាវ ឆាយ វ៉ាន់នឿន | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ច័ន្ទ តានី | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ស្វាយ ស៊ីថា | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម សុក ផេង | រដ្ឋលេខាធិការ |
| ៨- ឯកឧត្តម យឹម បូរ | រដ្ឋលេខាធិការ |
| ៩- ឯកឧត្តម ជ្រា សុចិន្តា | រដ្ឋលេខាធិការ |
| ១០- ឯកឧត្តម ផៃ ស៊ីផាន | រដ្ឋលេខាធិការ |
| ១១- ឯកឧត្តម អ៊ីន វីរជាតិ | រដ្ឋលេខាធិការ |
| ១២- ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | រដ្ឋលេខាធិការ |
| ១៣- ឯកឧត្តម តឹកវ៉េត សំរេច | រដ្ឋលេខាធិការ |
| ១៤- ឯកឧត្តម កែវ រ៉េមី | រដ្ឋលេខាធិការ |

១៥- ឯកឧត្តម ប៊ុន សំបូរ រដ្ឋលេខាធិការ
១៦- ឯកឧត្តម ឃឹម រុស្សីដា រដ្ឋលេខាធិការ
១៧- ឯកឧត្តម ង៉ោ ហុងលី រដ្ឋលេខាធិការ

## ២- ក្រសួងមហាផ្ទៃ

១- ឯកឧត្តម ស ខេង រដ្ឋមន្ត្រី
២- ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការ
៣- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ
៤- ឯកឧត្តម នុត សាអាន រដ្ឋលេខាធិការ
៥- ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការ
៦- ឯកឧត្តម ងី ច័ន្ទ្រផល រដ្ឋលេខាធិការ
៧- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ
៨- ឯកឧត្តម ប៉ុល លឹម រដ្ឋលេខាធិការ
៩- ឯកឧត្តម តេង សាវង្ស រដ្ឋលេខាធិការ
១០- ឯកឧត្តម ឌុល គឿន រដ្ឋលេខាធិការ
១១- ឯកឧត្តម អ៊ុក គីមលេខ រដ្ឋលេខាធិការ

## ៣- ក្រសួងការពារជាតិ

១- ឯកឧត្តម ទៀ បាញ់ រដ្ឋមន្ត្រី
២- ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការ
៣- ឯកឧត្តម ម៉ឹង សំផន រដ្ឋលេខាធិការ
៤- ឯកឧត្តម នាង ផាត រដ្ឋលេខាធិការ
៥- ឯកឧត្តម ឯល វ៉ាន់សារ៉ាត រដ្ឋលេខាធិការ
៦- លោកជំទាវ ដាំ ដារីនី រដ្ឋលេខាធិការ

## ៤- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១- ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រី
២- ឯកឧត្តម ឡុង វិសាលោ រដ្ឋលេខាធិការ

| | |
|---|---|
| ៣- ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម ពូ សុធីរៈ | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម អ៊ុង ស៊ាន | រដ្ឋលេខាធិការ |
| ៦- លោកជំទាវ សៀង រដ្ឋចារី | រដ្ឋលេខាធិការ |

### ៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | |
|---|---|
| ១- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម វង្សី វិស្សុត | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ជូ វិជិត្ត | រដ្ឋលេខាធិការ |
| ៤- លោកជំទាវ ងួន សុខា | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ហ៊ាន សាហ៊ីប | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ងី តាឃី | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម ជូ គឹមឡេង | រដ្ឋលេខាធិការ |

### ៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| ១- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម យុទ្ធ ភូថង | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ឌិម គឹមស៊ា | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម ទី សុគន្ធ | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ម៉ម អំណាត់ | រដ្ឋលេខាធិការ |
| ៦- លោកជំទាវ ហោ ម៉ាលីន | រដ្ឋលេខាធិការ |

### ៧- ក្រសួងអភិវឌ្ឍន៍ជនបទ

| | |
|---|---|
| ១- ឯកឧត្តម ជា សុផារ៉ា | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម សួស គង់ | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម អ៊ិន ចន្ទា | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម សៅ ជីវ័ន្ត | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ទ្រី មេង | រដ្ឋលេខាធិការ |
| ៦- លោកជំទាវ ម៉ាត់ ម៉ារ៉ា | រដ្ឋលេខាធិការ |

## ៨- ក្រសួងពាណិជ្ជកម្ម

| | |
|---|---|
| ១- ឯកឧត្តម ស៊ុន ចាន់ថុល | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម គឹម ស៊ីថន | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ប៉ាន សូរស័ក្តិ | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម ឱក ប៊ុង | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ម៉ៅ ថូរ៉ា | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ឈួន ដារ៉ា | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម ឱត ទីណា | រដ្ឋលេខាធិការ |
| ៨- លោកជំទាវ តឹក វ៉េត កំរង | រដ្ឋលេខាធិការ |

## ៩- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

| | |
|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម ភោគ សុវណ្ណរិទ្ធ | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ឯក សុនចាន់ | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម ហេង សុខគង់ | រដ្ឋលេខាធិការ |
| ៧- លោកជំទាវ ឡាយ ណារីន | រដ្ឋលេខាធិការ |
| ៨- ឯកឧត្តម គឹម ទូច | រដ្ឋលេខាធិការ |

## ១០- ក្រសួងផែនការ

| | |
|---|---|
| ១- ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ហ៊ូ តាំងអេង | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម រិន វីរៈ | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម សន ស៊ីថន | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ទូន ថាវរៈ | រដ្ឋលេខាធិការ |
| ៦- លោកជំទាវ ប៉ែន សុបភា | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម ប៉ាន ប៊ុនធឿន | រដ្ឋលេខាធិការ |

## ១១- ក្រសួងអប់រំ យុវជន និងកីឡា

| | |
|---|---|
| ១- ឯកឧត្តម ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ពិត ចំណាន | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម ណាត ប៊ុនរឿន | រដ្ឋលេខាធិការ |
| ៤- លោកជំទាវ តឹម សេដ្ឋានី | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម ស៊ាន បូរ៉ាត | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម អ៊ុំ កុច | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម យក់ ង៉ុយ | រដ្ឋលេខាធិការ |

## ១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

| | |
|---|---|
| ១- ឯកឧត្តម វង សូត | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម នឹម ចូត | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម យី យ៉ូន | រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម សយ ស៊ីផុន | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម មុត ខៀវ | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម សែម សុខា | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា | រដ្ឋលេខាធិការ |
| ៨- ឯកឧត្តម យូន រ៉ានីន | រដ្ឋលេខាធិការ |
| ៩- លោកជំទាវ ខៀវ បូរី | រដ្ឋលេខាធិការ |

## ១៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| | |
|---|---|
| ១- ឯកឧត្តម អ៊ឹម ឈុនលឹម | រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម លឹម វ៉ាន់ | រដ្ឋលេខាធិការ |
| ៤- លោកជំទាវ អ៊ូ រ៉ានី | រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម កឿង សុភ័ណ្ឌ | រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម សរ សុវណ្ណ | រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម ប៉ែន សុផល | រដ្ឋលេខាធិការ |

## ១៤- ក្រសួងបរិស្ថាន

១- ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី
២- ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការ
៣- ឯកឧត្តម យិន គិមស៊ាន រដ្ឋលេខាធិការ
៤- ឯកឧត្តម សាបូ អូហ្សាណ្ណ រដ្ឋលេខាធិការ
៥- លោកជំទាវ យុន លក្ស៊ី រដ្ឋលេខាធិការ

## ១៥- ក្រសួងធនធានទឹក និងឧតុនិយម

១- ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រី
២- ឯកឧត្តម វេង សាខុន រដ្ឋលេខាធិការ
៣- ឯកឧត្តម តន់ វ៉ាន់ថារ៉ា រដ្ឋលេខាធិការ
៤- ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការ
៥- លោកជំទាវ សេង វណ្ណសាយ រដ្ឋលេខាធិការ
៦- ឯកឧត្តម ថោ ជេដ្ឋា រដ្ឋលេខាធិការ

## ១៦- ក្រសួងព័ត៌មាន

១- ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី
២- ឯកឧត្តម អ៊ុក ប្រាថ្នា រដ្ឋលេខាធិការ
៣- ឯកឧត្តម មៅ អាយុទ្ធ រដ្ឋលេខាធិការ
៤- ឯកឧត្តម ថាច់ ផែន រដ្ឋលេខាធិការ
៥- ឯកឧត្តម នូវ សុវត្ថិ៍ រដ្ឋលេខាធិការ
៦- ឯកឧត្តម ហោ សុភាព រដ្ឋលេខាធិការ
៧- ឯកឧត្តម ជា ចាន់បរិបូណ៌ រដ្ឋលេខាធិការ
៨- លោកជំទាវ ច័ន្ទ ធី រដ្ឋលេខាធិការ

## ១៧- ក្រសួងយុត្តិធម៌

១- ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រី
២- ឯកឧត្តម ហ៊ី សោភា រដ្ឋលេខាធិការ

៣- លោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការ

៤- ឯកឧត្តម ង៉ោ សុវណ្ណ រដ្ឋលេខាធិការ

៥- ឯកឧត្តម ព្រហ្ម សិទ្ធត្រា រដ្ឋលេខាធិការ

៦- ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការ

## ១៨- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

១- លោកជំទាវ ម៉ែន សំអន រដ្ឋមន្ត្រី

២- ឯកឧត្តម ឆេង សារឿន រដ្ឋលេខាធិការ

៣- ឯកឧត្តម កង ណៃម រដ្ឋលេខាធិការ

៤- ឯកឧត្តម ថាច់ យន រដ្ឋលេខាធិការ

៥- ឯកឧត្តម ឌុច សុវណ្ណារី រដ្ឋលេខាធិការ

៦- លោកជំទាវ សុភ័ក្ត ថាវី រដ្ឋលេខាធិការ

៧- លោកជំទាវ សុខ វិឡាយ រដ្ឋលេខាធិការ

## ១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១- ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រី

២- ឯកឧត្តម សារ៉ាក់ ខាន់ រដ្ឋលេខាធិការ

៣- ឯកឧត្តម ខាយ ឃុនហេង រដ្ឋលេខាធិការ

៤- ឯកឧត្តម ឯក វណ្ណឌី រដ្ឋលេខាធិការ

៥- លោកជំទាវ រស់ សូរក្ខា រដ្ឋលេខាធិការ

៦- ឯកឧត្តម កាន ច័ន្ទមេត្តា រដ្ឋលេខាធិការ

៧- លោកជំទាវ ប្រាក់ ច័ន្ទណាយ រដ្ឋលេខាធិការ

## ២០- ក្រសួងសុខាភិបាល

១- ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រី

២- ឯកឧត្តម ហេង តៃគ្រី រដ្ឋលេខាធិការ

៣- ឯកឧត្តម អ៊ឹង ភិរុន រដ្ឋលេខាធិការ

៤- ឯកឧត្តម អេង ហួត រដ្ឋលេខាធិការ

៥- ឯកឧត្តម សុខ ផេង រដ្ឋលេខាធិការ

៦- លោកជំទាវ តាន់ វូចឆេង រដ្ឋលេខាធិការ

៧- ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការ

៨- ឯកឧត្តម ជូ យិនស៊ឹម រដ្ឋលេខាធិការ

៩- ឯកឧត្តម ជា គ្រុយ រដ្ឋលេខាធិការ

## ២១- ក្រសួងសាធារណការ និងដឹកជញ្ជូន

១- ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រី

២- ឯកឧត្តម តូច ចាន់កុសល រដ្ឋលេខាធិការ

៣- ឯកឧត្តម សួង ហេង រដ្ឋលេខាធិការ

៤- ឯកឧត្តម សួន រចនា រដ្ឋលេខាធិការ

៥- ឯកឧត្តម លឹម ស៊ីដេនីន រដ្ឋលេខាធិការ

៦- ឯកឧត្តម នូ សុវត្ថិ រដ្ឋលេខាធិការ

៧- ឯកឧត្តម សុខុម ភគវន្តមុនី រដ្ឋលេខាធិការ

៨- លោកជំទាវ មឹន មាណវី រដ្ឋលេខាធិការ

## ២២- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១- លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រី

២- ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការ

៣- ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ

៤- លោកជំទាវ ម៉ិញ កុសនី រដ្ឋលេខាធិការ

៥- ឯកឧត្តម អ៊ុក សុជាតិ រដ្ឋលេខាធិការ

៦- ឯកឧត្តម សោម សុគន្ធ រដ្ឋលេខាធិការ

៧- ឯកឧត្តម ថៃ នរៈសត្យា រដ្ឋលេខាធិការ

៨- ឯកឧត្តម សំរាំង កំសាន្ត រដ្ឋលេខាធិការ

## ២៣- ក្រសួងទេសចរណ៍

១- ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រី

២- ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការ

៣- ឯកឧត្តម លី ប៊ុនធឿន រដ្ឋលេខាធិការ

៤- ឯកឧត្តម គោស៊ុំ សារឿត រដ្ឋលេខាធិការ

៥- លោកជំទាវ សម មុន្នីកា រដ្ឋលេខាធិការ

៦- ឯកឧត្តម ទិត ចន្ថា រដ្ឋលេខាធិការ

៧- ឯកឧត្តម ជា បូរ៉ា រដ្ឋលេខាធិការ

## ២៤- ក្រសួងធម្មការ និងសាសនា

១- ឯកឧត្តម មិន ឃិន រដ្ឋមន្ត្រី

២- ឯកឧត្តម ផ្លោក ផន រដ្ឋលេខាធិការ

៣- ឯកឧត្តម សុះ មុះសិន រដ្ឋលេខាធិការ

៤- ឯកឧត្តម នរ: រតនវឌ្ឍនោ រដ្ឋលេខាធិការ

៥- លោកជំទាវ ទូច សារ៉ុម រដ្ឋលេខាធិការ

## ២៥- ក្រសួងកិច្ចការនារី

១- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី

២- លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការ

៣- លោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ

៤- លោកជំទាវ ច័ន្ទ សូរីយ៍ រដ្ឋលេខាធិការ

៥- លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការ

៦- លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការ

៧- លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការ

៨- លោកជំទាវ កុប ម៉ារីយ៉ាស រដ្ឋលេខាធិការ

៩- លោកជំទាវ ហ៊្វ សាមិត្ត រដ្ឋលេខាធិការ

## ២៦- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី

២- ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិការ

៣- ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋលេខាធិការ

៤- ឯកឧត្តម កាន់ ម៉ន រដ្ឋលេខាធិការ

៥- លោកជំទាវ ស៊ើង សរសុចិត្តា  រដ្ឋលេខាធិការ

៦- ឯកឧត្តម អ៊ុំ មាន  រដ្ឋលេខាធិការ

៧- ឯកឧត្តម ហ៊ុយ ហានសុង  រដ្ឋលេខាធិការ

៨- ឯកឧត្តម ម៉ម វណ្ណៈ  រដ្ឋលេខាធិការ

## ២៧- ក្រសួងមុខងារសាធារណៈ

១- ឯកឧត្តម ពេជ្រ ប៊ុនធិន  រដ្ឋមន្ត្រី

២- ឯកឧត្តម យូ ស៊ុនឡុង  រដ្ឋលេខាធិការ

៣- ឯកឧត្តម អៀម សារុំ  រដ្ឋលេខាធិការ

៤- ឯកឧត្តម រស់ សូផាន់  រដ្ឋលេខាធិការ

៥- លោកជំទាវ វ៉ាន់ ម៉ារា  រដ្ឋលេខាធិការ

៦- ឯកឧត្តម ប៉ូល ពីខូ  រដ្ឋលេខាធិការ

៧- ឯកឧត្តម យក់ ប៊ុនណា  រដ្ឋលេខាធិការ

## ២៨- រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

១- ឯកឧត្តម ហូ សិទ្ធី

២- ឯកឧត្តម សុខ ចិន្តាសោភា

៣- ឯកឧត្តម ម៉ម សារិន

៤- ឯកឧត្តម ស្រី ថាមរុង្គ

៥- ឯកឧត្តម ង៉ោ សុវណ្ណ

៦- ឯកឧត្តម ឈៀង យ៉ាណារ៉ា

៧- ឯកឧត្តម ឌុល គឿន

៨- ឯកឧត្តម យូ ស៊ុនឡុង

៩- ឯកឧត្តម អូស្មាន ហាស្សាន់

១០- ឯកឧត្តម សោម សឿន

១១- ឯកឧត្តម សុន គន្ធរ

១២- ឯកឧត្តម ហ្សាការីយ៉ា អាដាម

១៣- ឯកឧត្តម កៅ គីមហួន

**រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៣

**ប្រធានសមាជិករដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

នស/រកត/១២១៣/១៣៩៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :**

ត្រូវបានបញ្ចប់តំណែងរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ និងត្រូវបានកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា÷

**ក-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

| | |
|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រី |
| ២-ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការ |
| ៣-ឯកឧត្តម ភោគ សុវណ្ណរិទ្ធ | រដ្ឋលេខាធិការ |
| ៤-ឯកឧត្តម ឯក សុនចាន់ | រដ្ឋលេខាធិការ |
| ៥-ឯកឧត្តម ហេង សុខគង់ | រដ្ឋលេខាធិការ |
| ៦-លោកជំទាវ ឡាយ ណារីន | រដ្ឋលេខាធិការ |
| ៧-ឯកឧត្តម គីម ទូច | រដ្ឋលេខាធិការ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**ខ-ក្រសួងរ៉ែ និងថាមពល**

១- ឯកឧត្តម ស៊ុយ សែម — រដ្ឋមន្ត្រី

២-ឯកឧត្តម អ៊ិត ប្រាំង — រដ្ឋលេខាធិការ

៣-ឯកឧត្តម ហូ វិចិត្រ — រដ្ឋលេខាធិការ

៤-ឯកឧត្តម ឌិត ទីណា — រដ្ឋលេខាធិការ

៥-ឯកឧត្តម សុខ ខាវ៉ាន់ — រដ្ឋលេខាធិការ

៦-ឯកឧត្តម ម៉េង សក្តិធារ៉ា — រដ្ឋលេខាធិការ

៧-លោកជំទាវ ប៉ែន ឆដា — រដ្ឋលេខាធិការ

**គ-ក្រសួងពាណិជ្ជកម្ម**

-ឯកឧត្តម អ៊ុក ប្រជា — រដ្ឋលេខាធិការ

**ឃ-ក្រសួងទេសចរណ៍**

-ឯកឧត្តម ប៉ាក់ សុខុម — រដ្ឋលេខាធិការ

**ង-ក្រសួងកិច្ចការនារី**

-លោកជំទាវ ស៊ីវណ្ណ បុទុម — រដ្ឋលេខាធិការ

**ច-រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

-ឯកឧត្តម អ៊ុជ គីមអន

**មាត្រា ២:**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរ. ១៣១២. ១៤១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣*

លេខ:១៣៧៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ខែ ធ្នូ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# សកម្មភាព

# វេទិកាម្ចាស់ស្តីពី ការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ

# របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១




វាគ្មិន និងឯកឧត្តម **អ៉ំ សំអាន** តំណាងរាស្ត្រគណសង្គ្រោះជាតិ ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល





ប្រជាពលរដ្ឋលើកសំណួរ និងយោបល់ទៅកាន់វាគ្មិន និងតំណាងរាស្ត្រ



# អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍

- **Comfrel ៖ រយៈពេល១ឆ្នាំ រដ្ឋាភិបាលសម្រេចនយោបាយ ៦ចំណុច ចំណោម ១៦ចំណុច**

ប្រភព៖ http://thmeythmey.com/?page=detail&ctype=article&id=23650&lg=kh

ភ្នំពេញ៖ នៅក្នុងរយៈពេលមួយឆ្នាំដំបូង រដ្ឋាភិបាល នីតិកាលទី៥ ដែលដឹកនាំដោយគណបក្ស ប្រជាជនកម្ពុជា បានសម្រេចពេញលេញក្នុងការអនុវត្តគោលនយោបាយចំនួន ៦ចំណុច ក្នុងចំណោមគោលនយោបាយ ១៦ ចំណុច ស្មើនឹងជាង ៣៧ភាគរយ។ នេះបើយោង តាមរបាយការណ៍ស្តីពី ការឃ្លាំមើល និងការផ្តល់ពិន្ទុរបស់អង្គការ Comfrel។

រដ្ឋាភិបាល នីតិកាលទី៥ បានអនុវត្តន៍សម្រេចគោលនយោបាយចំនួន៦ ក្នុងចំណោម ១៦ ចំណុច ដែលជាគោលនយោបាយមានសូចនាករច្បាស់លាស់។ គោលនយោបាយដែលមាន សូចនាករច្បាស់លាស់ទាំងនោះ រួមមាន កំណើនសេដ្ឋកិច្ចចំនួន ៧ភាគរយក្នុងមួយឆ្នាំ ការ កាត់បន្ថយភាពក្រីក្រក្នុងអត្រា ១ភាគរយក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការកែលម្អផ្លូវលំជនបទជាជំហានៗពីផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវ ក្រាលកៅស៊ូ ឬផ្លូវបេតុង ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅទាក់ទាញទេសចរណ៍បរទេស។

ជាមួយគ្នានេះដែរ អង្គការ ខុមហ្វ្រែល (Comfrel) ក៏បានធ្វើការស្រង់មតិដាក់ពិន្ទុលើគោល នយោបាយរបស់រដ្ឋាភិបាលពីសាធារណជនជាង ៣០០នាក់ ដែលរស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាបផងដែរ។ នៅក្នុងរបាយការណ៍ស្តីពី ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការ បំពេញ ឬអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី១នោះ បានបង្ហាញថា ពលរដ្ឋជាង ៤០ភាគរយ បានពេញចិត្ត និងជាង ៦០ភាគរយ មិនពេញចិត្តទៅនឹងការអនុវត្តន៍ គោលនយោបាយ ៣៣ចំណុចរបស់រដ្ឋាភិបាល ក្នុងរយៈពេលមួយឆ្នាំកន្លងមក។ ខុមហ្វ្រែល បង្ហាញថា គោលនយោបាយអភិវឌ្ឍន៍លើវិស័យអប់រំ វិស័យសុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច ត្រូវបានប្រជាពលរដ្ឋពេញចិត្តជាង ៥០ភាគរយ ។ ចំណែក ពលរដ្ឋជាង ៥០ភាគរយទៀត ខុមហ្វ្រែល បានបង្ហាញឲ្យឃើញថា ពលរដ្ឋបានដាក់ពិន្ទុមិនពេញចិត្តទៅ នឹងការចំណាយថវិកាជាតិដែលគ្រោងចំណាយឆ្នាំ ២០១៤ ជាង ៣ ពាន់លានដុល្លារអាមេរិក លើវិស័យសង្គមកិច្ច វិស័យការពារជាតិ និងសន្តិសុខ វិស័យសេដ្ឋកិច្ច និងវិស័យរដ្ឋបាលទូទៅ។

ជុំវិញរបាយការណ៍ដាក់ពិន្ទុនេះ លោក សៀន ប៊ុនរិទ្ធ មន្រ្តីផ្នែកអង្កេតរបស់អង្គការខុមហ្វ្រែល បានឲ្យដឹងថា របាយការណ៍ការឃ្លាំមើល និងការដាក់ពិន្ទុលើគោលនយោបាយរបស់ រដ្ឋាភិបាលនីតិកាលទី ៥ ឆ្នាំទី១ នេះ ផ្អែកលើការវិភាគព័ត៌មាន ឬទិន្នន័យដែលមានស្រាប់ មកពីប្រព័ន្ធផ្សព្វផ្សាយ របាការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ និងតាមរយៈវេទិកា ម្ចាស់ឆ្នោតដែលរៀបចំឡើងដោយអង្គការខុមហ្វ្រែល កាលពីចុងឆ្នាំ២០១៤ ៕

- [សង្គមស៊ីវិលរកឃើញថារដ្ឋាភិបាលសម្រេចគោលនយោបាយបានតែ៦ចំណុចក្នុង១៦ចំណុច]()

ប្រភព៖ vodhotnews.com/27586

**ដោយ៖ ជន ស្រីណុច | ថ្ងៃចន្ទ ទី23 កុម្ភៈ 2015, 06:17 PM**

ក្រុមអង្គការសង្គមស៊ីវិលរកឃើញថា ក្នុងរយៈពេលមួយឆ្នាំដំបូងនៃរដ្ឋាភិបាលនីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា សម្រេចបានពេញលេញនូវការបំពេញនិងអនុវត្តន៍គោលនយោបាយ៦ចំណុចស្មើនឹង ៣៧,៥ ភាគរយ នៃគោលនយោបាយដែលមានសូចនាករច្បាស់លាស់១៦ចំណុច ។

ការបង្ហាញនេះធ្វើឡើងក្នុងសន្និសីទសារព័ត៌មានមួយ ចែកចេញជារបាយការណ៍ដែលរកឃើញដោយគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយ សេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) នារសៀលថ្ងៃទី២៣ ខែកុម្ភៈនេះ ។

នៅក្នុងរបាយការណ៍បង្ហាញថា ការសម្រេចរបស់រដ្ឋាភិបាលក្នុងគោលនយោបាយ៦ចំណុចនោះមាន ៣៧,៥ភាគរយនៃ១៦ចំណុចនៃគោលនយោបាយមានសូនាករច្បាស់លាស់ រួមមានកំណើនសេដ្ឋកិច្ច៧ភាគរយក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអាត្រា១ភាគរយក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្ដល់ដីសម្បទានសេដ្ឋកិច្ច ការកែលម្អផ្លូវលំជនបទជាជំហានៗពីផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវ ក្រាលកៅស៊ូ ឬផ្លូវបេតុង ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅនៃចំនួនទេសចរក្រៅប្រទេស ។

អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីអង្គការខុមហ្វ្រែលលោក គឹម ឈន មានប្រសាសន៍ថា ការដែលរដ្ឋាភិបាលសម្រេចបានគោលដៅនៃគោលនយោបាយ និងការអភិវឌ្ឍនេះ ដោយសារតែការដាក់គោលនយោបាយមានភាពមិនច្បាស់លាស់ច្រើនពេក ។

មន្ត្រីផ្នែកអង្កេតនៃអង្គការខុមហ្វ្រែលលោក សៀម ប៊ុនរិទ្ធិ មានប្រសាសន៍ថា ក្នុងនាមខ្លួនជាអង្គការសង្គមស៊ីវិល ជំរុញឲ្យរដ្ឋាភិបាលធ្វើឲ្យបាននូវគោលនយោបាយដែលខ្លួនបានដាក់មក ហើយថាប្រជាពលរដ្ឋចង់បានគោលនយោបាយដែលមានលក្ខណៈច្បាស់លាស់ក្នុងការ យកមកអនុវត្ត ។

អ្នកនាំពាក្យអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី លោក ទិត្យ សុធា យល់ថារបាយការណ៍របស់អង្គការខុមហ្វ្រែលមានចេតនារិះគន់ថា រដ្ឋាភិបាលមានភាពយឺតយ៉ាវក្នុងការបំពេញគោលនយោបាយរបស់ខ្លួន ខណៈរដ្ឋាភិបាលត្រូវការពេលវេលាក្នុងការអនុវត្តគោលនយោបាយបម្រើ ប្រជាពលរដ្ឋ ។

ចំពោះការផ្ដល់ពិន្ទុសម្រាប់ឆ្នាំទី១នៃការដឹកនាំរបស់ រដ្ឋាភិបាលអាណត្តិទី៥ ដែលធ្វើឡើងដោយអង្គការខុមហ្វ្រែ មានការសម្ភាសន៍ពលរដ្ឋនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ក្នុងនោះមានប្រជាពលរដ្ឋចំនួនភាគច្រើននៃ ៤៤,៤ភាគរយ ពេញចិត្តខ្លះចំពោះការបំពេញ និងអនុវត្តន៍គោលនយោបាយ៣៣ចំណុច ដែលមិនមានសូចនាកររបស់រដ្ឋាភិបាលនីតិកាលទី៥ ប៉ុន្តែប្រជាពលរដ្ឋ៥៥,៦ភាគរយ មិនពេញចិត្តនឹងការអនុវត្តគោលនយោបាយទាំងនោះក្នុងរយៈពេលមួយឆ្នាំ កន្លងមក ៕

- **ខុមហ្វ្រែល៖ ពលរដ្ឋភាគច្រើនមិនពេញចិត្តការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល**

ប្រភព៖ http://www.rfa.org/khmer/news/politics/comfrel-conference-02232015080516.html

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល (Comfrel) ចេញសេចក្ដីប្រកាសព័ត៌មានមួយនៅថ្ងៃទី២៣ កុម្ភៈ ស្ដីពីការឃ្លាំមើលនិងការផ្ដល់ពិន្ទុលើលទ្ធផលនៃការបំពេញ និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំដំបូងនៃនីតិកាល ទី៥។

របាយការណ៍ដែលមានកម្រាស់ជាង ១០០ទំព័រ រកឃើញថា គោលនយោបាយរដ្ឋាភិបាលនីតិកាលទី៥ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដែលចំណាយថវិកាជាតិប្រមាណ ៣.៤០០ដុល្លារ ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ មានពលរដ្ឋភាគច្រើនមិនពេញចិត្តនូវលទ្ធផលនៃការអនុវត្តនោះ។ រីឯមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលគិតថា របាយការណ៍អង្គការខុមហ្វ្រែល មិនបានវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ ហើយធ្វើឡើងក្នុងចេតនាគាំទ្រគណបក្សប្រឆាំង។

អង្គការខុមហ្វ្រែល រកឃើញថា រាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់បំពេញចិត្តពលរដ្ឋជាម្ចាស់ឆ្នោតឲ្យបាន ១០០ភាគរយនៅឡើយទេ ក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន។

មួយឆ្នាំមកហើយដែលរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានខិតខំបំពេញនិងអនុវត្តគោលនយោបាយរបស់ខ្លួនក្នុងនីតិកាលទី៥។ ប៉ុន្តែពលរដ្ឋបានផ្ដល់ពិន្ទុមិនពេញចិត្តក្នុងការអនុវត្ត គោលនយោបាយរបស់រដ្ឋាភិបាលដែលមិនមានសូចនាករ ឬកំណត់ច្បាស់លាស់។

រដ្ឋាភិបាលនីតិកាលទី៥ បានដាក់ចេញនិងប្រកាសគោលនយោបាយ៤វិស័យធំៗ គឺទី១ ការការពារសន្តិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ។ ទី២ ពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ។ ទី៣ ការអភិវឌ្ឍសេដ្ឋកិច្ច និងទី៤ ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។ ក្នុងការសិក្សាវិស័យទាំង៤នោះ អង្គការខុមហ្វ្រែល បែកចែកជា ២ គឺទី១ គោលនយោបាយមានសូចនាករច្បាស់លាស់មានចំនួន ១៦ចំណុច និងទី២ គោលនយោបាយគ្មានសូចនាករច្បាស់លាស់មានចំនួន ៣៣ចំណុច។

គោលនយោបាយគ្មានសូចនាករច្បាស់លាស់ទាំង ៣៣ចំណុចនោះ ត្រូវពលរដ្ឋមកពីរាជធានីភ្នំពេញ និងខេត្តសៀមរាប ចំនួន ២៥០នាក់ដាក់ពិន្ទុ។ លទ្ធផលបញ្ជាក់ថា ពលរដ្ឋរហូតជិត ៥៦ភាគរយ (៥៥,៦) មិនពេញចិត្តនឹងការអនុវត្តគោលនយោបាយក្នុងរយៈពេល ១ឆ្នាំកន្លងមក។ រីឯពលរដ្ឋជាង ៤៤ភាគរយ (៤៤,៤) ពេញចិត្តខ្លះៗចំពោះការអនុវត្តគោលនយោបាយទាំងនោះ។

សមាជិកគណៈកម្មាធិការនាយកនៃអង្គការខុមហ្វ្រែល លោក យង់ គិមអេង និងជាប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព ថ្លែងនៅក្នុងសន្និសីទកាសែតនៅថ្ងៃទី២៣ កុម្ភៈ ថា ការទទួលព័ត៌មានរបស់ពលរដ្ឋពីគោលនយោបាយរបស់រដ្ឋាភិបាលនៅមានកម្រិត ពិសេសការមិនកំណត់សូចនាករច្បាស់លាស់នៃគោលនយោបាយទាំងនោះ អាចជាមូលហេតុមួយធ្វើឲ្យរដ្ឋាភិបាលមិនសូវយកចិត្តទុកដាក់បំពេញ និងអនុវត្តឲ្យបានពេញលេញ ដែលធ្វើឲ្យពលរដ្ឋជួបការលំបាកពាក់ព័ន្ធនឹងការទទួលសេវាសាធារណៈ ការចុះបញ្ជីដីធ្លីជាដើម៖ *«តើពលរដ្ឋប៉ុន្មាននាក់ដែលមិនដឹងថា ពេលទៅរកសេវាសាធារណៈត្រូវចំណាយលុយ? អ៊ីចឹងគាត់អាចវាយតម្លៃបាន អ៊ីចឹងហើយបានអាចធ្វើឲ្យពិន្ទុក្នុងការបំពេញការងាររបស់ រដ្ឋាភិបាលមិនបានពិន្ទុលើមធ្យមភាគ ឬដល់មធ្យមភាគ»*។

ទោះបីបែបនេះក្តី ក្នុងរយៈពេលមួយឆ្នាំដំបូងនៃរដ្ឋសភានីតិកាលទី៥ រាជរដ្ឋាភិបាលបានសម្រេចពេញលេញនូវការបំពេញ និងអនុវត្តគោលនយោបាយចំនួន ៦ចំណុចក្នុងចំណោម ១៦ចំណុចនៃគោលនយោបាយដែលមានសូចនាករច្បាស់លាស់ រួមមានកំណើនសេដ្ឋកិច្ច ៧ភាគរយក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា ១ភាគរយក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការកែលម្អផ្លូវលំជនបទជាជំហានៗពីផ្លូវក្រាសក្រួសក្រហមទៅជា ផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុងនិងគោលដៅនៃចំនួនទេសចរណ៍ពី ក្រៅប្រទេស។

រីឯគោលនយោបាយ ៧ទៀត រួមមានការរក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិស្តីពីសិទ្ធិលំនៅឋាន ការទទួលសេវាទឹកស្អាត ការពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានរដ្ឋាភិបាលអនុវត្តសម្រេចបានខ្លះៗ។ ដោយឡែកគោលនយោបាយចំនួន ៣ទៀត ដែលរដ្ឋាភិបាលអនុវត្តតែមិនអាចសម្រេចតាមការសន្យាបាន រួមមាន គោលនយោបាយនាំចេញអង្ករឲ្យបាន ១លានតោននៅឆ្នាំ២០១៥ ការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

យ៉ាងណារបាយការណ៍របស់អង្គការខុមហ្វ្រែលនោះ ត្រូវអនុប្រធាន និងជាអ្នកនាំពាក្យអង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្តីការ គណៈរដ្ឋមន្ត្រី លោក ទិត សុធា គិតថា ជារបាយការណ៍មួយដែលធ្វើឡើងដោយមិនបានវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ ហើយធ្វើឡើងក្នុងចេតនាគាំទ្រគណបក្សប្រឆាំង៖ *«កិច្ចខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល គឺជាជំហានឆ្ពោះទៅមុខក្នុងការកែទម្រង់ ដូច្នេះយើងធ្វើជាជំហានៗ មិនអាចក្នុងរយៈពេលដ៏ខ្លីយើងធ្វើបានតាមសំណូមពរទាំងស្រុងរបស់ ប្រជាពលរដ្ឋ ឬក៏សម្រេចគោលនយោបាយរបស់ខ្លួនបានទាំងស្រុងនោះទេ»*។

ពាក់ព័ន្ធនឹងសុក្រឹតភាពក្នុងរបាយការណ៍ដែលរកឃើញដោយអង្គការ ខុមហ្វ្រែលនេះ លោក យង់ គិមអេង សមាជិកគណៈកម្មាធិការនាយកអង្គការខុមហ្វ្រែល បញ្ជាក់ថា ធ្វើឡើងត្រឹមត្រូវហើយ គ្មានភាពលំអៀង។ យ៉ាងណារបាយការណ៍នោះគឺជាគំរូ ឬការសិក្សាមួយដែលអាចផ្សារភ្ជាប់ការយល់ដឹងរបស់ពលរដ្ឋជាមួយ គោលនយោបាយថ្នាក់ជាតិ និងលើកទឹកចិត្តឲ្យពលរដ្ឋរៀនតាមដានពីគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីឲ្យក្លាយជាម្ចាស់ឆ្នោតពិតប្រាកដដែលមានឥទ្ធិពលក្នុងការ ដាក់សម្ពាធទៅលើអ្នកនយោបាយ ដើម្បីឲ្យអ្នកនយោបាយធ្វើការទៅតាមឆន្ទៈរបស់ពលរដ្ឋ៕

- **Gov't Fulfills Six of 16 Policy Pledges: Comfrel**

Source: https://www.cambodiadaily.com/news/govt-fulfills-six-of-16-policy-pledges-comfrel-78569/

By Aun Pheap | February 24, 2015

The Committee for Free and Fair Elections in Cambodia (Comfrel) on Monday released its first annual assessment of the CPP government's 16-plank policy platform for the current electoral term, marking only six planks as "fully fulfilled" in 2014.

At a press conference at the election-monitoring organization's offices in Phnom Penh, Yang Kim Eng, a member of Comfrel's board of directors, said that an analysis had found that the majority of the government's pledges had not been met in its first year in office.

"We found that some precise indicators that the government promised to achieve in their main sectors were not fully fulfilled as they had fixed in their political platform," he said. "Most of the main sectors were not fulfilled."

The policies fulfilled in 2014, Mr. Kim Eng said, were economic growth of 7 percent, a 1 percent reduction in poverty, the halting of land concessions, improvement of rural roads, creation of a transport policy and an increase in tourists.

Among the seven other planks only "partly fulfilled" by the CPP government, Mr. Kim Eng said, were increases in land title registration, the creation of a national housing supply policy, and the construction of secondary schools in all communes.

Comfrel said that three of the government's pledges—to increase milled rice exports to 1 million tons by 2015, keep forest cover steady, and implement "retirement allowances in the private sector"—have remained outright unfulfilled.

"We have already calculated it and found that the government will not be able to export 1 million tons of rice this year because the export figure last year was too low," Mr. Kim Eng said.

Council of Ministers spokesman Phay Siphan rejected the mostly dim assessment from Comfrel, saying the government was working toward achieving its promises over the entire five-year term.

"Comfrel is an NGO opposed to the government, which insults the government," he said. "The government is working hard to attend to what it has earmarked in its five-year plan.

"This commitment is over five years," he said.

ប្រភព៖ http://www.akp.gov.kh/kh/?p=103320

**បទអត្ថាធិប្បាយ**

## ការស្ទង់មតិ ដែលមិនឆ្លុះបញ្ចាំងពីការពិត របស់ ខុមហ្វ្រែល

នរណាក៏ដឹងដែរថា អង្គការខុមហ្វ្រែល គឺជាសម្ព័ន្ធមិត្តដ៏ជិតស្និទរបស់គណបក្សសង្គ្រោះជាតិ ដូច្នេះ រាល់កម្មវិធីដែលរៀបចំដោយអង្គការមួយនេះ គឺមានគោលដៅបម្រើនយោបាយឲ្យបក្សប្រឆាំងយ៉ាងពិតប្រាកដ។ នៅក្នុងវេទិកា ដែលពួកគេឲ្យឈ្មោះថាជា វេទិកាម្ចាស់ឆ្នោតនោះ តាមពិតវាគឺជារឿងល្បែងនយោបាយ តាមបែបប្រជាធិបតេយ្យសុទ្ធសាធ របស់ក្រុមប្រឆាំងនឹងរដ្ឋាភិបាល ដែលពួកគេបានលើកឡើងពីការស្ទង់មតិរបៀបកំប៉ិកកំប៉ុក ទៅលើមនុស្សរបស់គេប្រមាណពី៥០ទៅ៦០នាក់ នៅក្នុងវេទិកានោះ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ហើយនិយាយថា ជាង៥០%នៃអ្នកចូលរួមមិនពេញចិត្តចំពោះរដ្ឋាភិបាល។

បើពិនិត្យទៅលើសមាសភាពអ្នកចូលរួម គឺសុទ្ធតែជាសកម្មជនរបស់គណបក្សសង្គ្រោះជាតិស្ទើរទាំងអស់ ក្នុងនោះមានដូចជា លោក **យ៉ែម បុញ្ញឫទ្ធិ** លោក **ឡុង បូរិទ្ធ** ជាដើម។ ចំណែកលោក **គល់ បញ្ញា** លោកគឺជាម្ចាស់កម្មវិធីនេះស្រាប់ហើយ ហើយសកម្មភាពរបស់លោក ជាមួយនឹងគណបក្សសង្គ្រោះជាតិកន្លងមកអ្នកតាមដានស្ថានការណ៍នយោបាយក៏គេបានដឹងយ៉ាងច្បាស់ដែរ។ ដូច្នេះ គ្មានអ្វីដែលឆ្ងល់នោះទេ ដែលលទ្ធផលនៃការស្ទង់មតិនេះ គឺវាពិតជាអាក្រក់បាត់ទៅហើយ។ ម្យ៉ាងទៀតតួនាទីរបស់សង្គមស៊ីវិល ដែលមាននិន្នាការប្រឆាំង បើមិននិយាយអាក្រក់ពីសកម្មភាពរបស់រដ្ឋាភិបាល ធ្វើម៉េចនឹងម្ចាស់ជំនួយផ្តល់លុយឧបត្ថម្ភបន្តទៀត?

និយាយឲ្យចំ វេទិកាស្ទង់មតិនេះគឺមិនមានការចូលរួមសម្តែងមតិពីតំណាងប្រជាពលរដ្ឋ ឬសកម្មជនរបស់គណបក្សប្រជាជនកម្ពុជានោះទេ គឺអង្គការខុមហ្វ្រែល មិនបានធ្វើការប្រកាសឲ្យមានការចូលរួមជាចំហរឡើយ សូម្បីតែតំណាងរាជរដ្ឋាភិបាល ក៏មិនមានការចូលរួមដែរ។ ដូច្នេះ លទ្ធផលនៃការស្ទង់មតិនេះ គឺមិនបង្ហាញអំពីទស្សនៈជាទូទៅ ឬយកជាផ្លូវការឡើយ។

ម្យ៉ាងទៀត ការអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងអាណត្តិនីមួយៗ គឺមិនអាចសម្រេចធ្វើបានតែមួយខែ ឬមួយឆ្នាំរួចនោះទេ គឺមាននីតិវិធីអនុវត្តជាជំហានៗ ទៅតាមដំណាក់កាលនីមួយៗ និងមានសូចនាករតាមដានលទ្ធផល ជាបន្តបន្ទាប់ពីបណ្តាប្រទេសផ្តល់ជំនួយនានា ដែលជាដៃគូអភិវឌ្ឍ។

តាមពិត ការវាយតម្លៃជាទូទៅ ទៅលើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានពិភពលោកវាយតម្លៃថា ជាប្រទេសទី១១លើពិភពលោក ដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ និងជាប្រទេសទី៥ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១នៅអាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពល្អ ក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ចពិសេសការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុង១ឆ្នាំ ដែលបច្ចុប្បន្នអត្រានៃភាពក្រីក្រនៅកម្ពុជាថិតនៅក្រោម១៨% ប៉ុណ្ណោះ។